**សាកលវិទ្យាល័យភូមិន្ទ**
**នីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**សារណាបញ្ចប់ការសិក្សា**

# ការយល់ព្រម និងការបោះបង់សន្តតិកម្ម

ស្រាវជ្រាវពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៧ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៧

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ៖ លោក **គីម ខឌ្ឍនៈ**

លោក **សែម ស៊ីនរិទ្ធ**

សាស្ត្រាចារ្យណែនាំ៖

លោកសាស្ត្រាចារ្យ **គង់ សុភ័ក្ត្រ**

ថ្នាក់៖ **បរិញ្ញាបត្រនីតិសាស្ត្រ**

ជំនាន់ទី ១៧

ឆ្នាំសិក្សាចូលសិក្សា៖ **២០១៣**

ឆ្នាំសរសេរសារណា៖ **២០១៧**

# អារម្ភកថា

ក្នុងនាមយើងខ្ញុំជានិស្សិតរៀនផ្នែកនីតិសាស្ត្រនៃសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច យើងខ្ញុំបានខិតខំស្វែងយល់នូវក្រម និងសៀវភៅមួយចំនួនដើម្បីចងក្រង អត្ថបទសិក្សានេះឡើង ក្នុងគោលបំណងផ្តល់ចំណេះដឹងទៅដល់អ្នកអានឲ្យកាន់តែយល់ច្បាស់ទៅ លើប្រធានបទការយល់ព្រម និងបោះបង់សន្តតិកម្ម។

គោលបំណងនៃការសិក្សាស្រាវជ្រាវរបស់ពួកយើងនេះ គឺចង់ពន្យល់ទៅដល់អ្នកអានទាំង អស់ឲ្យយល់ពីសារៈសំខាន់នៃសន្តតិកម្ម ជាពិសេសពាក់ព័ន្ធទៅនឹងការទទួលយក និងបោះបង់នៅ ពេលដែលសន្តតិកម្មបានចាប់ផ្តើម។ មូលហេតុដែលយើងខ្ញុំផ្តោតសំខាន់ទៅលើការយល់ព្រម និង បោះបង់សន្តតិកម្មនោះ ព្រោះថាការបែងចែកមតិកមានសារៈសំខាន់ណាស់ចំពោះមនុស្សម្នាក់ៗ ដើម្បីជៀសវាងពីការមានជំលាស់ក្នុងគ្រួសារ ដែលជាហេតុតម្រូវឲ្យមនុស្សគ្រប់រូបយល់ឲ្យច្បាស់នូវ សិទ្ធិ និងករណីកិច្ចរបស់គេមុនពេលដែលសន្តតិជនយល់ព្រមទទួល ឬបោះបង់សន្តតិកម្មនោះ ដើម្បីកុំឲ្យមានការប្រកែកគ្នានៅពេលដែលមានការចែកទ្រព្យសម្បត្តិ។ ហេតុដូច្នេះក្រោយពីគេបាន យល់ច្បាស់នូវសិទ្ធិ និងករណីកិច្ចរបស់គេហើយនោះ គេអាចធ្វើការបែងចែកមតិករបស់គេដោយ ស្របតាមច្បាប់ និងមិនមានជំលាស់ ហើយក៏អាចការពារសិទ្ធិរបស់គេពីការបំពាននៅពេលធ្វើ សន្តតិកម្មបានដែរ។

យើងខ្ញុំសង្ឃឹមថាកម្រងអត្ថបទសិក្សានេះ អាចចូលរួមចំណែកផ្តល់នូវពុទ្ធិដល់អ្នកអានគ្រប់ រូបដើម្បីឲ្យពួកគេយល់ដឹងច្បាស់ពីបញ្ហាទាំងនេះ។

ជាទីបញ្ចប់ យើងខ្ញុំសូមអធ្យាស្រ័យនូវរាល់កំហុសដោយអចេតនាដែលអាចនឹងកើតមាន ក្នុងអត្ថបទសិក្សារបស់យើងខ្ញុំ ដូច្នេះយើងខ្ញុំក៏សូមទទួលនូវមតិ និង សេចក្តីណែនាំទាំងអស់ពី សំណាក់ សម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា អស់លោក លោកស្រី លោកគ្រូ អ្នកគ្រូ អ្នកនាងកញ្ញា សិស្ស និស្សិតទាំងអស់ដោយសេចក្តីរីករាយដើម្បីជួយកែលំអឯកសារនេះអោយបាន ល្អជាងនេះ ដើម្បីផ្តល់នូវគំនិតល្អៗដល់មនុស្សជំនាន់ក្រោយ។

# **សេចក្តីថ្លែងអំណរគុណ**

យើងខ្ញុំមានឈ្មោះ **ភឹម ខន្ធរ:** និងឈ្មោះ **សែម ស៊ីនរិទ្ធ** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ជំនាន់ទី ១៧ ឆ្នាំសិក្សា ២០១៦-២០១៧ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

## **សូមថ្លែងអំណរគុណយ៉ាងជ្រៀលជ្រៅចំពោះ**

លោកឪពុក និងអ្នកម្តាយរបស់យើងទាំងពីរអ្នក ដែលបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សាពួកយើងយ៉ាងយកចិត្តទុកដាក់។ មិនតែប៉ុណ្ណោះពួកគាត់តែងតែអប់រំ ទូន្មាន ប្រដៅ និងលើកទឹកចិត្តពួកយើងជានិច្ច ដែលពួកគាត់គឺជាមនុស្សដ៏សំខាន់នៅក្នុងជិវិតពួកយើង។ ម្យ៉ាងវិញទៀតពួកគាត់បានផ្គត់ផ្គង់ការសិក្សាពួកយើងដែលអាចផ្តល់ឱកាសដល់យើងទាំងពីរនាក់បាន សិក្សារៀនសូត្ររហូតដល់បានបញ្ចប់ថ្នាក់បរិញ្ញាប័ត្រនេះ។

លោកគ្រូ និងអ្នកគ្រូទាំងអស់ដែលបានខិតខំអប់រំ និងផ្តល់ចំណេះដឹងដល់ពួកយើងរហូតមកដល់សព្វថ្ងៃនេះ។

លោកសាស្ត្រាចារ្យ **គង់ សុភ័ក្រ** ដែលបានចំណាយពេលវេលា និងកម្លាំងកាយចិត្តដ៏មានតម្លៃរបស់គាត់ដើម្បីធ្វើការណែនាំ និងផ្តល់យោបល់ល្អៗ និងជួយកែតម្រូវកំហុសរបស់ពួកយើង ដែលនាំអោយសារណារបស់ពួកយើងទាំងពីរនាក់ទទួលបានជោគជ័យ និងសម្រេចជាស្ថាពរ។

ជាទីបញ្ចប់យើងខ្ញុំសូមជូនពរដល់ លោកឪពុក និងអ្នកម្តាយ ឯកឧត្តម លោក លោកស្រី អ្នកនាងកញ្ញាទាំងអស់ឲ្យជួបតែភាពជោគជ័យនៅថ្ងៃអនាគត។

រាជធានីភ្នំពេញ, ថ្ងៃទី.........ខែ.................ឆ្នាំ ២០១៧

**ហត្ថលេខា**

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ..... ១

**ជំពូកទី ១**

**សញ្ញាណនៃសន្តតិកម្ម**

**១.១. និយមន័យ និងការចាប់ផ្តើម** ..... ៦

**១.២. សន្តតិជន** ..... ៦

១.២.១. លក្ខណៈសម្បត្តិនៃសន្តតិជន ..... ៧

១.២.២.លំដាប់នៃសន្តតិជន ..... ៧

**១.៣. ប្រភេទទូទៅនៃសន្តតិកម្ម** ..... ៨

១.៣.១. សន្តតិកម្មតាមច្បាប់ ..... ៩

១.៣.២ មតកសាសន៍ ..... ១០

**ជំពូកទី ២**

**ការយល់ព្រមចំពោះសន្តតិកម្ម**

**២.១. គោលគំនិតទូទៅ** ..... ១៦

**២.២.ការយល់ព្រមទាំងស្រុងចំពោះសន្តតិកម្ម** ..... ១៦

២.២.១ នីតិវិធីនៃការយល់ព្រមទាំងស្រុង ..... ១៧

២.២.២ អានុភាពនៃការយល់ព្រមទាំងស្រុង ..... ១៩

**២.៣ ការយល់ព្រមដោយមានកម្រិត** ..... ១៩

២.៣.១. នីតិវិធីនៃការយល់ព្រមដោយមានកម្រិត ..... ២០

២.៣.២ អានុភាពនៃការយល់ព្រមដោយមានកម្រិត ..... ២២

**ជំពូកទី ៣**

**ការបោះបង់សន្តតិកម្ម**

**៣.១. គោលគំនិតទូទៅ** ..... ២៥

**៣.២. ប្រភេទនៃការបោះបង់សន្តតិកម្ម** ..... ២៥

៣.២.១ ការបោះបង់លក្ខណៈទូទៅ.....២៦

៣.២.២. ការបោះបង់អច្ច័យទាន.....២៦

**៣.៣. នីតិវិធី និងអានុភាពនៃការបោះបង់សន្តតិកម្ម**.....២៩

៣.៣.១. នីតិវិធីនៃការបោះបង់សន្តតិកម្ម.....២៩

៣.៣.២ អានុភាពនៃការបោះបង់សន្តតិកម្ម.....៣០

**ជំពូកទី ៤**

**អំឡុងពេល និងការលុបចោលនៃការយល់ព្រម ឬបោះបង់សន្តតិកម្ម**

**ផ្នែកទី ១៖ អំឡុងពេលនៃការយល់ព្រម ឬបោះបង់សន្តតិកម្ម**.....៣៣

១.១ អំឡុងពេលធម្មតា.....៣៣

១.២. អំឡុងពេលក្នុងករណីពិសេស.....៣៤

**ផ្នែកទី ២៖ ការលុបចោលការយល់ព្រម ឬ ការបោះបង់សន្តតិកម្ម**.....៣៨

២.១ មូលហេតុនៃការលុបចោលការយល់ព្រម ឬ ការបោះបង់សន្តតិកម្ម.....៣៨

២.២.អំឡុងពេលដែលអាចលុបចោលការយល់ព្រម ឬ ការបោះបង់សន្តតិកម្ម.....៣៩

**សេចក្តីសន្និដ្ឋាន**.....៤១

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ជាទូទៅ នៅពេលដែលយើងនិយាយអំពីប្រធានបទ សន្តតិកម្ម គឺតែងតែរមែងមានការភាន់ច្រឡំ ឬក៏មានផ្នត់គំនិតមួយដែលរៀបរាប់អំពីរបបសន្តតិកម្មថា ជាការទទួលយកបន្ទុកនៃសន្តតិកម្មពីជំនាន់មុនដែលជាទូទៅត្រូវបានគេហៅគំនិតនេះថា "បំណុលឪពុក កូនសង"។ គោលគំនិតនេះត្រូវបានគេអនុវត្តនៅសម័យមុន ដែលនាពេលនោះរបបសន្តតិកម្មជាគំនិតថ្មីនៅឡើយ និងមិនទាន់បានជួបប្រទះនឹងផលពិបាកនៅពេលអនុវត្ត ដែលនាំឲ្យឈានទៅដល់ការកែសម្រួលជាច្រើនចំណុច ដូចជាការបើកសិទ្ធិឲ្យសន្តតិជនមានសិទ្ធិក្នុងការយល់ព្រម ឬបោះបង់សន្តតិកម្មជាដើម។

ចំណុចពិសេសនៃប្រធានបទនេះ អាចនិយាយបានថាជាភាពសាមញ្ញ និងភាពជាក់លាក់នៃដែនកំណត់លើការស្រាវជ្រាវ។ ជាទូទៅ សំណេរដែលបានបោះពុម្ពជាផ្លូវការទាំងក្នុងស្រុក និងក្រៅស្រុកបានផ្តោតទៅលើ សន្តតិកម្ម ដែលជាប្រធានបទដែលមានភាពទូលាយ។ ថ្វីត្បិតថាការកំណត់នេះអាចឲ្យអ្នកនិពន្ធ មានសិទ្ធិសរសេរអំពីបញ្ហា និងការយល់ឃើញរបស់ខ្លួនជាច្រើនចំណុចក៏ដោយការកំណត់របៀបនេះ បានធ្វើឲ្យចំណុចសំខាន់មួយចំនួនដូចជា ការយល់ព្រម និងការបោះបង់ចោលសន្តតិកម្មត្រូវបានរៀបរាប់ក្នុងទម្រង់ខ្លីៗ ដែលមិនបានលំអិតអត្ថន័យទៅលើប្រធានបទនេះឲ្យបានស៊ីជម្រៅ។

ដើម្បីដោះស្រាយបញ្ហាខាងលើ សំណេរសារណានេះបានធ្វើការបែងចែកទៅជា ៤ ជំពូក។ ជំពូកទី១ នឹងផ្តល់ជាគោលគំនិតសំខាន់ៗសម្រាប់ឲ្យអ្នកអាន ជាពិសេសមនុស្សទូទៅ មានភាពងាយស្រួលក្នុងការយល់។ បន្ទាប់ពីនេះ ជំពូកទី២ និង៣ នឹងផ្តោតទៅលើចំនុចស្នូលនៃប្រធានបទ គឺការយល់ព្រម និងការបោះបង់។ ជំពូកដែលជាស្នូលនៃសារណា មានការលំអិតទៅប្រភេទនៃការយល់ព្រម និងការបោះបង់នីមួយៗ ក៏ដូចជានីតិវិធី និងអានុភាពរបស់សកម្មភាពពាក់ព័ន្ធ។ ចុងក្រោយគឺជំពូកទី៤ ដែលនិយាយអំពីអំឡុងពេល និងការលុបចោលនៃការយល់ព្រម និងបោះបង់សន្តតិកម្ម។

## ២. គោលបំណង និងចំណោទបញ្ហានៃការស្រាវជ្រាវ

ប្រធានបទ ការយល់ព្រម និងការបោះបង់សន្តតិកម្ម មានភាពចាំបាច់សម្រាប់អ្នកច្បាប់ក្នុងការសិក្សា និងចងក្រងឲ្យមានភាពស៊ីជម្រៅ ដោយសារចំនុចនេះមិនសូវទទួលបានការយកចិត្តទុកដាក់ពី បណ្តាអ្នកនិពន្ធ តាមរយៈការយកប្រធានបទនេះធ្វើជាប្រធានបទគោលឡើយ។ ជាទូទៅ

ការយល់ព្រម និងការបោះបង់សន្តតិកម្ម ត្រូវបានគេយកទៅរៀបរាប់នៅក្នុងចំនុចតូចមួយនៅក្រោមប្រធានបទធំ ដូចជា សន្តតិកម្ម ឫភាគបម្រុងជាដើម។ ហេតុដូច្នេះ សំណេរសារណានេះមានគោលបំណងសម្រាយចំនុចខ្លីៗដែលអ្នកនិពន្ធពីមុនមិនសូវលំអិតមកធ្វើឲ្យមានភាពស៊ីជម្រៅ និងមានភាពជាក់លាក់តាមរយៈការយកប្រធានបទការយល់ព្រម និងការបោះបង់សន្តតិកម្មមកធ្វើជាប្រធានបទគោលនៃសំណេរនេះ។

## ៣. ទំហំ និងដែនកំណត់

សំណេរសារណានេះមានគោលបំណងក្នុងការរៀបរាប់ឲ្យបានច្បាស់លាស់អំពី ការយល់ព្រមនិងការបោះបង់សន្តតិកម្ម។ ការស្រាវជ្រាវរបស់យើងនឹងធ្វើការរៀបរៀងឡើងដោយផ្អែកទៅលើបញ្ញត្តិច្បាប់នៅក្នុងគន្ថីទី៨ នៃក្រមរដ្ឋប្បវេណី ដែលរៀបរាប់អំពីសន្តតិកម្ម។ ការប្រើប្រាស់មាត្រានៅក្នុងគន្ថីទី៨ អាចជាចំនុចខ្លាំងរបស់សារណា ដោយសារតែវាមានលក្ខណៈខិតទៅជិតការអនុវត្តសព្វថ្ងៃជាខ្លាំង ពីព្រោះគោលគំនិតនៅក្នុងរដ្ឋប្បវេណី ជាគំនិតដែលបានកំពុងតែដាក់ប្រើប្រាស់សព្វថ្ងៃនៅក្នុងប្រទេសកម្ពុជា។ អ្វីដែលអាចជាចំណុចខ្វះខាតនៃសំណេរសារណានេះ អាចសំដៅទៅលើចំណោទបញ្ហាមួយចំនួនដែលបានរកឃើញនៅក្នុងសំណេរសារណា តែពុំបានសិក្សាឲ្យស៊ីជម្រៅដើម្បីស្វែងរកដំណោះស្រាយ ដោយសារតែវាស្ថិតនៅក្រៅរង្វង់នៃដែនកំណត់។ ចំពោះដែនកំណត់ទៅលើពេលវេលាសិក្សា នៃសារណានេះ គឺសិក្សាទៅលើតែឯកសារច្បាប់ទាក់ទងនឹងសន្តតិកម្មនៅប្រទេសកម្ពុជាតែប៉ុណ្ណោះ ដែលបានអនុម័តឲ្យប្រើប្រាស់ចុងក្រោយគេបង្អស់នៅថ្ងៃទី ២១ ខែធ្នូ ឆ្នាំ ២០១១ ដែលមានដូចជាក្រមរដ្ឋប្បវេណី ជាដើម។

## ៤. សារៈសំខាន់នៃប្រធានបទ

សំណេរជាច្រើនបានបោះពុម្ពទាក់ទងទៅនឹងប្រធានបទ សន្តតិកម្ម ប៉ុន្តែជាទូទៅមិនសូវធ្វើការផ្តោតសំខាន់ទៅលើ ការយល់ព្រម និងការបោះបង់សន្តតិកម្មឡើយ។ លើសពីនេះទៅទៀត ការប្រែប្រួលនិងការផ្លាស់ប្តូរបានកើតឡើងទៅលើរបបសន្តតិកម្ម ក៏ដូចជាទៅលើការអនុវត្តច្បាប់នេះផងដែរ។ តែគេសង្កេតឃើញថា គោលគំនិតដែលត្រូវបានបញ្ឈប់ឲ្យប្រើប្រាស់ដូចជា"បំណុលឪពុកកូនសង" ជាដើមនៅតែបន្តរមានឥទ្ធិពលរហូតមកដល់បច្ចុប្បន្នទៅលើផ្នត់គំនិតរបស់ប្រជាពលរដ្ឋ និងបានបង្កជាបញ្ហាជាច្រើនទៅដល់បុគ្គល និងសង្គម។ ហេតុនេះហើយទើបសំណេរសារណាទាក់ទងទៅនឹង "**ការយល់ព្រម និងការបោះបង់សន្តតិកម្ម**" មានសារៈសំខាន់ណាស់ដើម្បីចែករំលែកចំនេះដឹងទៅឲ្យអ្នកអាន ដោយតាមរយៈការជួយឲ្យពួកគាត់អាចធ្វើការបែងចែងបានយ៉ាងច្បាស់លាស់អំពីលក្ខខណ្ឌ សិទ្ធិនិងកាតព្វកិច្ច ដែលកំពុងអនុវត្តបច្ចុប្បន្នទៅនឹងគោលគំនិតចាស់

ដែលគេបានឈប់អនុវត្តដូចជាគោលគំនិត "បំណុលឪពុក កូនសង"ជាដើម។ លើសពីនេះទៅទៀត សំណេរសារណានេះអាចជួយសម្រួលទៅដល់ការអនុវត្តទូទៅសម្រាប់ប្រជាពលរដ្ឋធម្មតា ដោយពួកគាត់អាចយល់ច្បាស់អំពីការប្រព្រឹត្តទៅ និងអានុភាពនៃការយល់ព្រម និងការបោះបង់ សន្តតិកម្ម។ ចំនេះដឹងនេះ អាចធ្វើជាជំនួយទៅដល់ពួកគាត់នៅពេលដែលពួកគាត់ជួបប្រទះករណីទាំងនេះនាពេលអនាគត។

## ៥. វិធីសាស្ត្រនៃការស្រាវជ្រាវ

### ៥.១ តម្រូវការពត៌មាន និងការប្រមូលពត៌មាន

ពត៌មាន គឺជាតម្រូវការយ៉ាងសំខាន់ក្នុងការស្រាវជ្រាវ។ ក៏ដូចគ្នានេះដែរ សំណេរសារណានេះនឹងធ្វើការប្រមូលពត៌មាននានាដែលអ្នកនិពន្ធយល់ថាចាំបាច់ក្នុងការសរសេរ។ ដោយសារតែមានការរីកចម្រើនទៅលើបច្ចេកវិទ្យា ប្រភពនៃពត៌មានមានច្រើន និងការដកស្រង់ពត៌មានទាំងនោះមានភាពងាយស្រួល។ ដូច្នេះ ការសិក្សានេះនឹងធ្វើឡើងដោយមានការប្រមូល និងប្រើប្រាស់ ទាំងពត៌មានចម្បង និង ពត៌មានបន្ទាប់បន្សំ។ ពត៌មានចម្បងមានដូចជា ឯកសារច្បាប់ដែលបានអនុម័តឲ្យប្រើប្រាស់ ដូចជាក្រមរដ្ឋប្បវេណី ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ឬច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ជាដើម។ លើសពីនេះទៅទៀត ពត៌មានចម្បងអាចជាទម្រង់កិច្ចសម្ភាសន៍រូចរាល់ ជាមួយនឹងមេធាវី ដែលជាអនុវត្តច្បាប់ ដែលអាចដកស្រង់បានតាមរយៈប្រព័ន្ធអ៊ីនធឺណែត។ រីឯ ពត៌មានបន្ទាប់បន្សំវិញ នឹងត្រូវធ្វើការប្រមូលតាមរយៈជាសៀវភៅមេរៀន និងអត្ថបទពន្យល់ដែលបានសរសេរ និងរៀបរាងដោយអ្នកជំនាញ ក៏ដូចជាសាស្ត្រាចារ្យនៅក្នុងវិស័យច្បាប់។

### ៥.២ ដំណើរការនៃការជ្រើសរើសគំរូតាង

ការប្រើប្រាស់គំរូតាងដើម្បីប្រមូលពត៌មាន គឺជាវិធីសាស្ត្រមួយដែលមានប្រសិទ្ធិភាព និងមានប្រជាប្រិយភាពនាពេលបច្ចុប្បន្ននេះ ដោយអ្នកស្រាវជ្រាវអាចយល់ដឹងពីការយល់ឃើញរបស់គំរូតាងរបស់ខ្លួនតាមរយៈការធ្វើវង្វាយតម្លៃជាដើម (Survey)។ តែនៅក្នុងការស្រាវជ្រាវនេះ ការបង្កើតគំរូតាងគឺមិនមានភាពចាំបាច់ឡើយ ដោយហេតុថាសារណានេះនឹងធ្វើការផ្តោតសំខាន់ទៅលើការបកស្រាយឯកសារច្បាប់ដែលបានចងក្រងរួចមកហើយ និងអាចរំលោភទៅលើដែនកំណត់នៃប្រធានបទ។ លើសពីនេះទៅទៀត គំរូតាងអាចមានផលអវិជ្ជមានមកលើការស្រាវជ្រាវដោយសារអ្នកចូលរួមអាចមិនមានចំនេះដឹង ឬ ជំនាញគ្រប់គ្រាន់ទៅលើប្រធានបទដែលនាំឲ្យពត៌មានក្លាយជាមិនបានការ។

### ៥.៣ វិធីសាស្ត្រវិភាគទិន្នន័យ

ការវិភាគទិន្នន័យនេះនឹងត្រូវធ្វើឡើងតាមរយៈការប្រមូលពត៌មានពីប្រភពផ្សេងៗ ដូចជា សៀវភៅច្បាប់ សៀវភៅមេរៀន អត្ថបទដែលបានបោះពុម្ពផ្សាយតាមរយៈប្រព័ន្ធអ៊ីនធឺណែត ក៏ដូចជាការប្រមូលវីដេអូនៃការសម្ភាសន៍របស់អ្នកអនុវត្តច្បាប់មួយចំនួន។ ពត៌មានដែលបានប្រមូលទាំងនេះ នឹងត្រូវបានយកមកវិភាគតាមរយៈការសង្ខេប និងផ្គុំតាមប្រភេទនីមួយៗដែលមានលក្ខណៈស្រដៀងគ្នា។ នៅពេលដែលពត៌មានណាមួយមានការបញ្ជាក់ពីរយៈពត៌មានផ្សេងថាមានភាពប្រហាក់ប្រហែល ឬ ដូចគ្នា នោះយើងអាចសន្មតថាពត៌មានដែលយើងទទួលបានអាចយកជាការបាន និងអាចប្រើប្រាស់នៅក្នុងសំណេរសារណា។

## ៦. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

នៅក្នុងការស្រាវជ្រាវទៅលើប្រធានបទ ការយល់ព្រម និងការបោះបង់សន្តតិកម្ម យើងបានបែងចែកចេញជាបីជំពូក។ ជំពូកទី១ មានចំនងជើង "សញ្ញាណនៃសន្តតិកម្ម" ដែលធ្វើការរៀបរាប់អំពីគោលការណ៍ចម្បងមួយចំនួនដូចជា និយមន័យសន្តតិកម្ម ប្រភេទនៃសន្តតិកម្ម និងការកំណត់ទៅលើសន្តតិជន។ បន្ទាប់មកជំពូកទី២ និងទី៣ មានលក្ខណៈស៊ីជម្រៅដោយជំពូកពីរនេះ ជាចំនុចស្នូលនៃសារណា។ ចំណែកឯជំពូកទី២ មានចំនងជើងថា "ការយល់ព្រមចំពោះសន្តតិកម្ម" ធ្វើការរៀបរាប់អំពីប្រភេទនៃការយល់ព្រមដែលមានពីរប្រភេទ ការយល់ព្រមទាំងស្រុង និងការយល់ព្រមមានកម្រិត។ ជំពូកនេះបន្តរៀបរាប់អំពីនីតិវិធី និងអានុភាពនៃការយល់ព្រមទាំងពីរប្រភេទនេះ។ រីឯជំពូកទី ៣ មាន ចំនងជើង "ការបោះបង់ចំពោះសន្តតិកម្ម" ដែលផ្តោតសំខាន់ទៅលើប្រភេទនៃការបោះបង់សន្តតិកម្ម ដែលមានលក្ខណៈទូទៅ និងការបោះបង់អច្ច័យទាន។ ដើម្បីឲ្យមានភាពស៊ីចង្វាក់គ្នានឹងជំពូកទី២ យើងបានយកទម្រង់ដូចគ្នាដែលរៀបរាប់អំពីនីតិវិធី និងអានុភាពនៃការបោះបង់សន្តតិកម្ម។ ហើយជំពូកទី ៤ នឹងបកស្រាយពីអំឡុងពេល និងការលុបចោលនៃការយល់ព្រម និងបោះបង់សន្តតិកម្ម។

# ជំពូកទី ១

# សញ្ញាណនៃសន្ធតិកម្ម

មុននឹងយើងអាចយល់បានថាសន្តតិកម្មជាអ្វីនោះ យើងត្រូវតែយល់ពីសញ្ញាណរបស់សន្តតិកម្មជាមុនសិនដើម្បីអាចទទួលបាននូវគំនិតមួយចំនួនក្នុងការស្វែងយល់បញ្ហាដទៃរបស់សន្តតិកម្ម ព្រោះថាបើយើងពុំទាន់យល់ច្បាស់អំពីគ្រឹះនៃសន្តតិកម្មទេ យើងច្បាស់ជាពិបាកយល់នូវខ្លឹមសារលំអិតរបស់វាខ្លាំងណាស់។

ដូចដែលយើងបានដឹងហើយថាក្នុងសង្គមមនុស្សទូទៅ នៅពេលមានសមាជិកគ្រួសារណាម្នាក់ទទួលមរណភាព តែងតែមានការផ្ទេរចំណែកទ្រព្យសម្បត្តិមនុស្សទទួលមរណភាពទៅមនុស្សដែលនៅរស់ ហើយការផ្ទេរនេះបានកើតមានឡើងតាំងពីសម័យបុរាណមកម្ល៉េះ។ ប៉ុន្តែការផ្ទេរទ្រព្យនាសម័យមុនមានភាពលំបាក ដោយពុំបានផ្តល់សិទ្ធិទៅដល់អ្នកទទួលក្នុងការព្រម ឬ មិនព្រមនោះទេ។ បញ្ហានេះហើយដែលជាហេតុបង្កឲ្យមានភាពស្មុគស្មាញដល់មនុស្ស ហើយភាពស្មុគស្មាញនេះកើតឡើងដោយសារប្រភេទនៃទ្រព្យផងដែរ។ ជាការពិតណាស់ មនុស្សម្នាក់ៗតែងតែខិតខំប្រឹងប្រែងដើម្បីទទួលបានប្រាក់ចំណូលក្នុងការចិញ្ចឹមជីវិត និងទទួលបាននូវជីវភាពដែលពួកគេចង់បាន។ ដោយសារតែតម្រូវការមនុស្សទាំងនេះ វាបានបង្កើតនូវទ្រព្យចំនួនពីរប្រភេទគឺ ទ្រព្យសកម្ម និងទ្រព្យអកម្ម។

ទ្រព្យសកម្ម គឺជាទ្រព្យវិជ្ជមាន ដូចជាប្រាក់ដែលខ្លួនទទួលបាន និង ទ្រព្យសម្បត្តិប្រភេទផ្សេងទៀតរួមមានអចលនវត្ថុ និង ចលនវត្ថុនានា។ ចំពោះមនុស្សមួយចំនួនទៀត គេយកប្រាក់នេះដើម្បីបង្កើតមុខរបរផ្សេងៗទៀត ដែលតម្រូវឲ្យទិញនូវសម្ភារៈ ឬឧបករណ៍ជាច្រើនក្នុងការប្រកបរបររកស៊ី ដូចនេះសម្ភារៈ ឬឧបករណ៍ទាំងនោះក៏ក្លាយជាទ្រព្យសម្បត្តិរបស់គេផងដែរ។ ទ្រព្យដែលគេមានព្រមទាំងពុំមានជាប់កាតព្វកិច្ចក្នុងការសងទៅជនណាផ្សេងនោះ គេចាត់ទុកវាថាជាទ្រព្យសកម្ម។

ផ្ទុយទៅវិញ ចំពោះមនុស្សពុំមានប្រាក់គ្រប់គ្រាន់ក្នុងការបង្កើតនូវរបររកស៊ីរបស់ខ្លួន ឬ យកប្រាក់ដើម្បីប្រើប្រាស់តាមតម្រូវការរបស់ខ្លួននោះ ពួកគេបានបង្កើតនូវចំណងកាតព្វកិច្ចរវាងរូបវន្តបុគ្គល និងរូបវន្តបុគ្គល ឬ រូបវន្តបុគ្គល និងនីតិបុគ្គល ពោលគឺជាការបង្កើតនូវកិច្ចសន្យាដើម្បីខ្ចីប្រាក់ពីរូបវន្តបុគ្គល ឬ នីតិបុគ្គលមួយចំនួនដូចជាធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុជាដើម។ នៅពេលដែលគេបានខ្ចីប្រាក់ពីរូបវន្តបុគ្គល ឬ នីតិបុគ្គលហើយ ប្រាក់ដែលគេទទួលបានគឺជាទ្រព្យសម្បត្តិ

របស់គេហើយ ប៉ុន្តែក្នុងករណីនេះវាមានភាពខុសប្លែកពីករណីខាងលើ ព្រោះថាប្រាក់ដែលគេទទួលបានគឺជាប់កាតព្វកិច្ចត្រូវសងទៅម្ចាស់បំណុលវិញ ដោយទ្រព្យប្រភេទនេះ គឺជាទ្រព្យអកម្ម ។

ដោយសារតែមានភាពស្មុគស្មាញ រវាងទ្រព្យសម្បត្តិទាំងនេះវាបានធ្វើឲ្យមានភាពលំបាកនៅពេលដែលបែងចែកទ្រព្យសម្បត្តិនៅពេលដែលមតកជនបានទទួលមរណភាព ហើយសន្តតិជនមួយចំនួនក៏ពុំយល់ច្បាស់អំពីបញ្ហានេះ វាធ្វើឲ្យមានភាពស្មុគស្មាញនៅពេលដែលមានការធ្វើសន្តតិកម្ម ម្តងៗ។ ដោយហេតុថានៅក្នុងសម័យកាលមុន សន្តតិជនត្រូវមានកាតព្វកិច្ចក្នុងការទទួលនូវទ្រព្យសកម្ម និងទ្រព្យអកម្មទាំងស្រុងដោយពុំមានសិទ្ធិក្នុងការប្រកែកបានឡើយ ទោះបីជាទ្រព្យសម្បត្តិនោះគឺមានទ្រព្យអកម្មក្នុងនោះយ៉ាងលើសលប់ក៏ដោយ។ ហេតុដូចនេះហើយទើបច្បាប់នៃព្រះរាជាណាចក្រកម្ពុជាយើងបានចែងអំពីសន្តតិកម្មនេះឡើង ដើម្បីសម្រួលនូវភាពស្មុគស្មាញដល់ប្រជាពលរដ្ឋក្នុងការទទួលបាននូវចំណែកមតិក ដោយពុំមានភាពលំបាកខ្លាំងព្រោះថាច្បាប់នេះបានផ្តល់សិទ្ធិឲ្យសន្តតិជនមានសិទ្ធិក្នុងការយល់ព្រម និងបដិសេធក្នុងការទទួលចំណែកមតិកនេះបាន។ មុននឹងយល់អំពី សន្តតិកម្មនេះឲ្យកាន់តែស៊ីជម្រៅបន្ថែមទៀត យើងគួរតែយល់អំពីនិយមន័យ និងអានុភាពរបស់វាជាមុនសិន។

### ១.១. និយមន័យ និងការចាប់ផ្តើម

ពាក្យថា "សន្តតិកម្ម" នេះមានន័យថាជាការផ្ទេរនូវសិទ្ធិ និងករណីយកិច្ចរបស់មតកជនទៅឲ្យសន្តតិជនម្នាក់ ឬច្រើននាក់តាមឆន្ទៈ ឬតាមច្បាប់[1]។ យោងទៅតាមនិយមន័យនេះ អ្នកទទួលសន្តតិកម្ម គេហៅថា សន្តតិជន ចំណែកឯអ្នកដែលបានស្លាប់ទៅគេហៅថា មតកជន។

យោងតាមមាត្រា ១១៩៥ នៃក្រមរដ្ឋប្បវេណី សន្តតិកម្ម ត្រូវចាប់ផ្តើមឡើងនៅពេលដែលមតិកជនទទួលមរណភាព ។

### ១.២. សន្តតិជន

សន្តតិជន គឺជាបុគ្គលដែលទទួលបន្តនូវសិទ្ធិ និងករណីយកិច្ចរបស់មតកជនតាមរយៈសន្តតិកម្ម។ ប្រសិនបើបុគ្គលនេះព្រមទទួលនូវសន្តតិកម្មនោះ គាត់នឹងមានសិទ្ធិ និងកាតព្វកិច្ចបន្តពីមតកជននោះ។ ទោះបីជាយ៉ាងណាក៏ដោយ សិទ្ធិ និងករណីយកិច្ចមួយចំនួនរបស់មតកជនគឺមិនត្រូវបានផ្ទេរទៅឲ្យសន្តតិជនបាននោះទេ ពោលគឺសិទ្ធិ និងករណីយកិច្ចផ្តាច់មុខរបស់មតកជនដែល

[1] លេខ ១៩៣ ក្នុងសទ្ទានុក្រមនៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា

មានដូចជាសិទ្ធិ និងកាតព្វកិច្ចអាណាព្យាបាល សិទ្ធិលើសញ្ញាប័ត្រ សិទ្ធិមនុស្ស ពោលគឺសិទ្ធិទាំងឡាយដែលស្ថិតនៅក្រៅបេតិកភ័ណ្ឌ[2]។

### ១.២.១. លក្ខណៈសម្បត្តិនៃសន្តតិជន

ដើម្បីក្លាយទៅជាសន្តតិជនត្រឹមត្រូវតាមច្បាប់ បុគ្គលនោះត្រូវតែមានលក្ខណៈសម្បត្តិមួយចំនួនដូចជា ត្រូវមានជីវិតរស់នៅនាពេលចាប់ផ្តើមសន្តតិកម្ម ហើយពុំមែនជាអភ័ព្វបុគ្គលនៃសន្តតិកម្ម ឬ ពុំមែនជាជនដែលត្រូវបានផ្តាច់ចេញពីមតិកឡើយ[3]។ ម្យ៉ាងវិញទៀត បើបុគ្គលដែលជាសន្តតិជននោះជាជនបរទេស ឬគ្មានសញ្ជាតិខ្មែរទេនោះ គឺសន្តតិជននោះពុំអាចទទួលបាននូវដីធ្លីបានទេ ដែលនេះបានចែងក្នុងមាត្រា ១១៥៥ នៃក្រមរដ្ឋប្បវេណីផងដែរ ហើយច្បាប់ភូមិបាលក៏បានចែងផងដែរថា "មានតែរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិជាខ្មែរទេទើបមានសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីនៃព្រះរាជាណាចក្រកម្ពុជា"[4]។ ការបង្ការដូចនេះគឺគោលបំណង ដើម្បីការពារទឹកដីជាតិរបស់យើងពីការលក់ទិញ ឬផ្ទេរទៅឲ្យជនបរទេសដែលនាំឲ្យខូចប្រយោជន៍ជាតិ។ បន្ថែមពីនេះបើយោងទៅតាមក្រមរដ្ឋប្បវេណី សន្តតិជនត្រូវបែងចែកទៅជាច្រើនលំដាប់ផងដែរ ក្នុងគោលបំណងសម្គាល់នូវអាទិភាពរបស់សន្តតិជននីមួយៗថាបុគ្គលណាមានអាទិភាពមុនគេក្នុងការទទួលនូវមតិករបស់មតកជន។

### ១.២.២.លំដាប់នៃសន្តតិជន

ក្នុងការទទួលនូវមតិក សន្តតិជនត្រូវបានបែងចែកជាលំដាប់ថ្នាក់ ដើម្បីកំណត់អំពីអាទិភាពក្នុងការទទួលទ្រព្យសម្បត្តិដែលជាមតិក ព្រមទាំងជៀសវាងនូវការដណ្តើមទ្រព្យសម្បត្តិគ្នាផងដែរ។ យើងត្រូវដឹងផងដែរថា ការគិតលំដាប់ថ្នាក់នៃសន្តតិជននេះគឺប្រើតែចំពោះសន្តតិកម្មតាមច្បាប់នោះទេ ព្រោះថាបើតាមមតកសាសន៍គឺវាពឹងផ្អែកលើបំណងរបស់មតកជន ដូចនេះវាមិនអាចគិតពីលំដាប់បានទេ។ ជារួមយោងតាមក្រមរដ្ឋប្បវេណី សន្តតិជនត្រូវបានបែងចែកជា ៣ លំដាប់ដែលក្នុងនោះមានដូចជា កូន បុព្វញាតិផ្ទាល់ និងបងប្អូនបង្កើត។

ចំពោះសន្តតិជនលំដាប់ទី ១ គឺកូនរបស់មតកជនតែម្តង។ កូនរបស់មតកជនត្រូវក្លាយទៅជាសន្តតិជន ដោយពុំគិតថាជាកូនបង្កើត ឬ ក៏កូនសុំឡើយ ពោលគឺអាចក្លាយជាសន្តតិជនបានដូចគ្នា។ ម្យ៉ាងទៀត ច្បាប់ក៏បានចែងផងដែរថាប្រសិនបើសន្តតិជនដែលបានស្លាប់ទៅមុនពេលចាប់

---

[2] មាត្រា ១១៤៧ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា

[3] មាត្រា ១១៤៩ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា

[4] មាត្រា ៨ នៃច្បាប់ភូមិបាល ២០០១ នៃព្រះរាជាណាចក្រកម្ពុជា

ផ្តើមសន្តតិកម្ម ឬ សន្តតិជននោះត្រូវបានក្លាយទៅជាអភ័ព្វបុគ្គល ឬ ដោយការផ្តាច់មតិក ច្បាប់បានប្រគល់សិទ្ធិដល់កូនរបស់សន្តតិជននោះ ទទួលសន្តតិកម្មជំនួសសន្តតិជនដែលបានស្លាប់ដើម្បីសម្រេច ព្រោះថាគាត់ត្រូវច្បាប់ចាត់ទុកថាជាសន្តតិជនជំនួស ដោយសារតែកូននេះក៏ចាត់ទុកថាជាបច្ឆាញាតិផ្ទាល់ផងដែរ[5]។ មិនតែប៉ុណ្ណោះ សន្តតិកម្មរបស់សន្តតិជនដែលបានស្លាប់ទៅក៏ត្រូវរាប់បញ្ចូលថាជាសិទ្ធិរបស់គាត់ដែរ ដូចនេះសិទ្ធិនេះក៏ត្រូវបញ្ចូលទៅក្នុងសន្តតិកម្មចំពោះសន្តតិជនរបស់គាត់ផងដែរ។ ក្នុងករណីមួយវិញទៀត នៅពេលដែលមតកជនពុំមានកូន ឬ បច្ឆាញាតិផ្ទាល់នោះទេ មតិកត្រូវផ្តល់ទៅឲ្យ សន្តតិជនលំដាប់ទី ២ ដែលជាបុព្វញាតិផ្ទាល់របស់មតកជន។ ចំពោះបុព្វញាតិរបស់មតកជននេះ គឺត្រូវតែយកបុព្វញាតិដែលនៅថ្នាក់ញាតិជិតជាងគេនឹងមតកជនជាមុន។ ប្រសិនបើមតកជនពុំមានទាំង បច្ឆាញាតិផ្ទាល់ និងបុព្វញាតិផ្ទាល់ទេនោះ មតិកនឹងត្រូវធ្វើការផ្ទេរទៅឲ្យសន្តតិជនលំដាប់ទី ៣ ដែលត្រូវជាបងប្អូនបង្កើតរបស់មតកជននោះ។

ទោះបីជាលំដាប់សន្តតិជនមានតែ ៣ លំដាប់ដូចបានរៀបរាប់ខាងលើនេះ ក៏នៅមានសន្តតិជនមួយប្រភេទទៀត ដែលមានលក្ខណៈពិសេស គឺសហព័ទ្ធ។ ដោយយោងតាមមាត្រា ១១៦១ នៃក្រម រដ្ឋប្បវេណី សហព័ទ្ធត្រូវបានចាត់ទុកថាជាសន្តតិជនជានិច្ច។ ពាក់ព័ន្ធនឹងការបែងចែកទ្រព្យរបស់មតកជននេះ សហព័ទ្ធដែលជាសន្តតិជនជានិច្ច គឺត្រូវតែក្លាយជាសន្តតិជនរហូត បានន័យថាបើទោះបីជាស្ថិតក្នុងស្ថានភាពបែបណា ក៏សហព័ទ្ធត្រូវមានសិទ្ធិទទួលចំណែកមតិកជាមួយនឹងសន្តតិជនដ៏ទៃទៀតដែរ លុះត្រាតែសហព័ទ្ធនោះត្រូវបានផ្តាច់មតិកពីមតិក ឬ ជាអភ័ព្វបុគ្គល។

### **១.៣. ប្រភេទទូទៅនៃសន្តតិកម្ម**

នៅក្នុងជីវិតមនុស្សជាក់ស្តែង ការស្លាប់គឺមិនទៀងទាត់នោះទេ មានមនុស្សខ្លះទទួលមរណភាពដោយសារតែគ្រោះថ្នាក់ផ្សេងៗ ដែលមិនអាចស្មានដល់ដែលគាត់បានបន្សល់ទុកនូវទ្រព្យសម្បត្តិ ហើយពុំបានចាត់ចែងថាត្រូវប្រគល់ឲ្យសន្តតិជនមួយណាជាអ្នកទទួលនោះទេ ប៉ុន្តែមនុស្សពេលខ្លះក៏ទទួលមរណភាពដោយសារជំងឺ ឬ ចាស់ជរា ដែលគេអាចស្មានពេលវេលាដែលបុគ្គលនោះទទួលមរណភាពបាន ដែលអាចឲ្យជននោះចាត់ចែង និងបែងចែកនូវទ្រព្យសម្បត្តិរបស់ខ្លួនទៅឲ្យសន្តតិជន ដែលខ្លួនមានបំណងប្រគល់ទ្រព្យសម្បត្តិទៅឲ្យមុនពេលដែលខ្លួនទទួលមរណភាព។ ដោយសារតែមានហេតុផលបែបនេះ ទើបច្បាប់បានបែងចែកវិធីពីរប្រភេទក្នុងការបែងចែកទ្រព្យសម្បត្តិដោយ សន្តតិកម្ម។ សន្តតិកម្មតាមច្បាប់ ជាវិធីក្នុងការធ្វើសន្តតិកម្មនៅពេលដែល

[5] មាត្រា ១១៥៧ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា

មតកជនទទួលមរណភាពដោយមិនបានបន្សល់បណ្តាំមតិក និងមតកសាសន៍ ជាវិធីសម្រាប់ផ្ទេរទ្រព្យសម្បត្តិទៅសន្តតិជនតាម បណ្តាំមតិក។

### ១.៣.១. សន្តតិកម្មតាមច្បាប់

នៅពេលមតកជនមិនបានបន្សល់បណ្តាំមតិកសម្រាប់បញ្ជាក់ពីបំណងរបស់ខ្លួនទេ សន្តតិជនអាចនឹងមានជំលោះក្នុងការបែងចែកមតិកដែលបានបន្សល់ទុក។ ហេតុនេះ ដើម្បីឲ្យមានភាពសុក្រឹត្យ និងយុត្តិធម៌ ក្រមរដ្ឋប្បវេណីរបស់ប្រទេសកម្ពុជាយើងបានកំណត់អំពីចំណែកមតិកសម្រាប់សន្តតិជនគ្រប់ថ្នាក់ ដើម្បីទទួលបាននៅពេលដែលម្ចាស់ទ្រព្យបានទទួលអនិច្ចកម្មទៅដោយមិនបានធ្វើបណ្តាំមតិក ព្រមទាំងអាចធ្វើឲ្យសន្តតិជនទទួលយកបានដោយមិនអាចបង្កបញ្ហានានាដល់សមាជិកគ្រួសារផ្សេងទៀត។ ការបែងចែកមតិកដែលបានបន្សល់ទុកដោយមតកជនដោយពឹងផ្អែកទៅលើបញ្ញត្តិច្បាប់នេះហើយគេហៅថា សន្តតិកម្មតាមច្បាប់។

នៅក្នុងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា បានចែងនូវវិធីនៃការបែងចែកទ្រព្យសម្បត្តិរបស់មតកជនដែលបានស្លាប់ទៅដោយពុំបន្សល់នូវបណ្តាំមតិក។ ការបែងចែកនេះត្រូវកើតឡើងភ្លាមនៅទីលំនៅរបស់មតកជននៅពេលដែលមតកជនទទួលមរណភាព។ ក្រមរដ្ឋប្បវេណីរបស់ព្រះរាជាណាចក្រ កម្ពុជាបានចែងយ៉ាងច្បាស់អំពីការបែងចែងទ្រព្យសម្បត្តិនេះ ដោយយោងតាមមាត្រា ១១៦២ ប្រសិន បើសន្តតិជនមានសហព័ទ្ធ និងបច្ឆាញាតិផ្ទាល់នោះ ការបែងចែកមតិកនេះត្រូវបែងចែកស្មើៗគ្នា។

ប្រសិនបើពុំមានបច្ឆាញាតិផ្ទាល់នោះទេ ដូចនេះត្រូវបែងចែកទ្រព្យសម្បត្តិទៅឲ្យបុព្វញាតិផ្ទាល់ដែលនៅជិតជាងគេ និងសហព័ទ្ធ ហើយក្នុងការបែងចែកនេះគឺសហព័ទ្ធត្រូវទទួលបាន ១/៣ នៃមតិក និង ២/៣ ទៀតផ្ទេរឲ្យឪពុក និងម្តាយ លើកលែងតែមានតែឪពុក ឬ ម្តាយតែម្នាក់នៅរស់ទើបចំណែក មតិកនេះបែងចែកស្មើគ្នាជាមួយនឹងសហព័ទ្ធ។

តែបើមតកជនពុំមានឪពុក ម្តាយ ឬ កូននោះទេ ដូចនេះចំណែកមតិកទាំងអស់ត្រូវបានបែងចែកឲ្យទៅសហព័ទ្ធចំនួន ១/២ និងចំណែក ១/២ ទៀតដែលនៅសល់ត្រូវយកទៅបែងចែកឲ្យបុព្វញាតិក្រៅពីឪពុក ឬ ម្តាយដែលមានខ្សែជិតជាងគេដូចដែលបានពន្យល់ខាងលើ ឬ ទៅឲ្យបងប្អូនបង្កើតដែលជាសន្តតិជនលំដាប់ទី ៣ ឬអ្នកទទួលសន្តតិកម្មជំនួស [6] ។ សូមបញ្ជាក់ផងដែរទោះបីជាគ្មាន បុព្វញាតិផ្ទាល់ក៏ដោយបុគ្គលដែលមានឋានៈជាញាតិពន្ធពុំមានសិទ្ធិក្លាយទៅជាសន្តតិជនរបស់មតកជនបាននោះទេ។

---

[6] មាត្រា ១១៦២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា

### ១.៣.២ មតកសាសន៍

ក្រៅពីការបែងចែកចំណែកមតិកតាមច្បាប់ហើយនោះ បុគ្គលម្នាក់ៗអាចធ្វើការផ្ទេរមតិក ឬធ្វើសន្តតិកម្មទៅតាមបំណងរបស់ពួកគេបាន ដោយគ្រាន់តែធ្វើជាបណ្តាំមតិកសម្រាប់បែងចែកទ្រព្យសម្បត្តិទៅឲ្យសន្តតិជនប៉ុណ្ណោះ។ ការធ្វើបណ្តាំមតិកត្រូវធ្វើតាមទម្រង់របស់វាដែលមានចែងក្នុងក្រមរដ្ឋប្បវេណីឲ្យបានត្រឹមត្រូវទើបគេអាចទុកជាបានការ។

មតកសាសន៍ ត្រូវធ្វើឡើងដោយបុគ្គលដែលជានីតិជន ឬ ជាអនីតិជនដែលទទួលបានអត្តាធីនភាព[7] និងត្រូវតែបំពេញទៅតាមទម្រង់ដែលបានកំណត់ដោយក្រមរដ្ឋប្បវេណីដូចជា៖

#### ១.៣.២.១ មតកសាសន៍ដោយលិខិតយថាភូត

បណ្តាំមតិកដែលជាលិខិតយថាភូត ត្រូវធ្វើឡើងតាមទម្រង់ដូចមានចែងក្នុងមាត្រា ១១៧៣ នៃក្រមរដ្ឋប្បវេណី ដោយក្នុងមាត្រានេះបានបង្គាប់ឲ្យម្ចាស់បណ្តាំធ្វើលិខិតបណ្តាំនៅចំពោះមុខសារការី ព្រមទាំងមានសាក្សីចំនួនយ៉ាងតិច ០២ នាក់។ ក្នុងពេលធ្វើបណ្តាំ ម្ចាស់បណ្តាំត្រូវរៀបរាប់ដោយផ្ទាល់មាត់នូវខ្លឹមសារចំពោះសារការី បន្ទាប់មកសារការីត្រូវសរសេរនូវអត្ថន័យនៃមតកសាសន៍នោះជាលាយល័ក្ខណ៍អក្សរ ហើយត្រូវសូត្រឲ្យម្ចាស់បណ្តាំ និងសាក្សីដែលមានវត្តមានស្តាប់។ ពេលដែលម្ចាស់ បណ្តាំ និងសាក្សីបានទទួលស្គាល់ថា អត្ថន័យក្នុងមតកសាសន៍នោះមានភាពត្រឹមត្រូវហើយ ជននីមួយៗត្រូវបំពេញឈ្មោះ អាយុ និងលំនៅឋាន របស់ខ្លួនឲ្យមានភាពច្បាស់លាស់ ព្រមទាំងធ្វើការចុះហត្ថលេខានៅលើមតកសាសន៍រៀងៗខ្លួន។ ក្នុងករណីដែលម្ចាស់បណ្តាំ មិនអាចសរសេរអក្សរ ឬមិនអាចចុះហត្ថលេខា ដូចជាក្នុងករណីដែលម្ចាស់បណ្តាំពិការដៃទាំងពីរ មិនចេះអក្សរ ឬ ក្នុងករណីផ្សេងៗទៀត សារការីអាចសរសេរ និងចុះហត្ថលេខាជំនួសបានដោយសរសេរឈ្មោះ អាយុ និង លំនៅឋានរបស់ជននោះ ហើយត្រូវសរសេរបន្ថែមនូវហេតុដែលធ្វើឲ្យគាត់មិនអាចសរសេរ ឬ ចុះហត្ថលេខានោះផងដែរ។ បន្ទាប់ពីបានធ្វើតាមទម្រង់រួចរាល់ សារការីត្រូវសរសេរថ្ងៃខែឆ្នាំ ហើយត្រូវចុះហត្ថលេខាផងដែរ ដើម្បីបញ្ជាក់ពីភាពក្លាយជាលិខិតយថាភូតនៃបណ្តាំ។[8] តែបើក្នុងករណីពិសេសដែលម្ចាស់បណ្តាំរស់នៅឯបរទេស នោះកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅកន្លែងនោះត្រូវអនុវត្តមុខនាទីជាសាការី[9]។

---

[7] មាត្រា ១១៦៨ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា

[8] មាត្រា ១១៧៣ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា

[9] មាត្រា ១១៨១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា

### ១.៣.២.២. មតកសាសន៍ដោយលិខិតឯកជន

ក្នុងករណីដែលម្ចាស់បណ្តាំ ពុំបានស្វែងរកសាការីដើម្បីធ្វើបណ្តាំជាលិខិតយថាភូតនោះទេ គាត់ក៏អាចធ្វើលិខិតបណ្តាំដោយខ្លួនឯង ដោយម្ចាស់បណ្តាំត្រូវសរសេរអត្ថន័យនៃបណ្តាំ ចុះថ្ងៃខែឆ្នាំ និងចុះហត្ថលេខាដោយផ្ទាល់ដៃ។ ការធ្វើបណ្តាំតាមលិខិតឯកជននេះ ម្ចាស់បណ្តាំមិនត្រូវប្រើម៉ាស៊ីន ឬ ឲ្យអ្នកដ៏ទៃសរសេរឲ្យជាដាច់ខាត ពីព្រោះថាដើម្បីជៀសវាងក្នុងការបន្លំឯកសារ ឬ ក្លែងអត្ថន័យនានាក្នុងឯកសារនៅពេលដែលសរសេរនោះ។ ក្នុងការសរសេរបណ្តាំមតិកខាងលើនេះ បើសិនជាមានការលុប ឬ កែប្រែនានា នៅក្នុងលិខិតនេះត្រូវចាត់ទុកថាពុំមានអានុភាពឡើយ លុះត្រាតែម្ចាស់បណ្តាំបង្ហាញនូវកន្លែង និងសរសេរបញ្ជាក់នូវមូលហេតុនៃការកែប្រែនោះដោយភ្ជាប់ជាមួយនឹងហត្ថលេខា បញ្ជាក់ពីការកែប្រែនៅក្នុងនោះផងដែរ។

### ១.៣.២.៣. មតកសាសន៍ដោយលិខិតសម្ងាត់

ពាក់ព័ន្ធនឹងមតកសាសន៍ទម្រង់បែបនេះ គឺគេត្រូវបំពេញលក្ខខណ្ឌមួយចំនួនដើម្បីបញ្ជាក់ថាលិខិតនេះគឺជាលិខិតសម្ងាត់ និងមិនអាចមានអ្នកណាម្នាក់ក្រៅពីមតកជនអាចដឹងពីនៃខ្លឹមសារនៅក្នុងនោះបានឡើយ ដើម្បីជៀសវាងការច្រណែនគ្នារវាងសាច់ញាតិដែលអាចធ្វើឲ្យបែកបាក់គ្រួសារ។

បើយោងទៅតាមច្បាប់ លិខិតសម្ងាត់នេះត្រូវធ្វើឡើងដោយម្ចាស់បណ្តាំផ្ទាល់ក៏បាន ឬ ពឹងឲ្យអ្នកដែលម្ចាស់បណ្តាំជឿទុកចិត្តសរសេរឲ្យ ឬអាចប្រើម៉ាស៊ីនសម្រាប់សរសេរក៏បាន[10]។ នៅពេលដែលសរសេរលិខិតបណ្តាំហើយនោះ ម្ចាស់បណ្តាំត្រូវតែចុះហត្ថលេខាលើលិខិតនោះដើម្បីបញ្ជាក់ថាខ្លួនពិតជាទទួលស្គាល់ថាវាពិតជាត្រឹមត្រូវ និងមានខ្លឹមសារតាមបំណងរបស់ខ្លួនមែន។ បន្ទាប់មកម្ចាស់បណ្តាំត្រូវដាក់លិខិតនោះក្នុងស្រោមដែលបិទជិត ហើយត្រូវចុះហត្ថលេខា ឬ សរសេរសញ្ញាសំគាល់ ឬមធ្យោបាយផ្សេងទៀតនៅលើមាត់នៃស្រោមលិខិតនោះ ដើម្បីអាចវិនិច្ឆ័យបានអំពីការបានបើក ឬមិនបានបើកស្រោមលិខិតនោះ។ ម្យ៉ាងទៀតនៅពេលដែលដាក់លិខិតដែលបានបិទជិតនោះ គឺត្រូវធ្វើឡើងនៅចំពោះមុខសាការី និងសាក្សី ២ នាក់ ទៀត ព្រមទាំងត្រូវធ្វើសេចក្តីថ្លែងការណ៍ថា លិខិតដែលបានដាក់ចូលស្រោមបិទជិតនេះគឺជាលិខិតមតកសាសន៍របស់ខ្លួន ហើយបើមានករណីដែលមានជនដ៏ទៃក្រៅពីម្ចាស់បណ្តាំបានសរសេរ ជននោះត្រូវធ្វើសេចក្តីថ្លែងការណ៍អំពីឈ្មោះ និងលំនៅឋានរបស់ជនដែលបានសរសេរនោះ។[11] លិខិតសម្ងាត់នេះត្រូវរក្សាទុក

[10] មាត្រា ១១៧៥ នៃសេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី

[11] មាត្រា ១១៧៥ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា

នៅសាការីផងដែរដើម្បីកាត់បន្ថយនូវហានិភ័យក្នុងការលួចបើក ឬកែប្រែនានាដែលប៉ះពាល់ដល់បំណាងរបស់ម្ចាស់បណ្ដាំ។ ហើយប្រសិនបើម្ចាស់បណ្ដាំរស់នៅឯបរទេស នោះកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅកន្លែងនោះត្រូវអនុវត្តមុខនាទីជាសាការី[12]។

### ១.៣.២.៤ មតកសាសន៍នៃជននៅក្រោមអាណាព្យាបាលទូទៅ

ជាទូទៅ មនុស្សម្នាក់ៗតែងតែមានសិទ្ធិក្នុងការធ្វើសកម្មភាពអ្វីមួយដែលស្ថិតនៅក្រោមច្បាប់ ហើយក្នុងករណីមតកសានស៍នេះក៏ដូចគ្នាដែរ។ មនុស្សដែលមានស្មារតីល្អក៏អាចធ្វើមតកសាសន៍នេះបាន ចំណែកមនុស្សដែលស្ថិតនៅក្រោមអាណាព្យាបាលទូទៅក៏អាចមានសិទ្ធិធ្វើដែរ គ្រាន់តែស្ថិតក្នុងកាលៈទេសៈពិសេសតែប៉ុណ្ណោះ។ ក្នុងករណីដែលជនស្ថិតក្រោមអាណាព្យាបាលទូទៅអាចធ្វើមតកសាសន៍បាននោះ គឺលុះត្រាតែបុគ្គលនោះបានជាសះស្បើយមួយរយៈឡើងវិញហើយ បានន័យថាបុគ្គលនោះមានស្មារតីល្អបានខ្លះហើយដែលមានសមត្ថភាពអាចយល់ដឹងនូវសកម្មភាព និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់ដែលកើតចេញពីសកម្មភាពដែលខ្លួនប្រព្រឹត្តបាន។ បន្ថែមពីនេះទៀតនោះគឺពេលដែលធ្វើមតកសាសន៍នោះច្បាប់តម្រូវឲ្យមានវត្តមានវេជ្ជបណ្ឌិតយ៉ាងតិច ០២ នាក់ ធ្វើជាសាក្សីបញ្ជាក់ថាម្ចាស់បណ្ដាំ ពិតជាមានស្មារតីគ្រប់គ្រាន់ដែលពុំបានស្ថិតក្នុងស្ថានភាពខ្វះសមត្ថភាពក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួនដោយសារមានវិបត្តិស្មារតីពិតប្រាកដមែននៅពេលដែលធ្វើមតកសាសន៍នោះ ដើម្បីជៀសវាងមានជនដ៏ទៃមកអះអាងលើ បណ្ដាំ មតិកដោយយោងពីសមត្ថភាពរបស់ម្ចាស់បណ្ដាំ។ មិនតែប៉ុណ្ណោះនៅពេលដែលធ្វើសេចក្ដីបញ្ជាក់នៃភាពប្រក្រតីរបស់ម្ចាស់បណ្ដាំនោះ វេជ្ជបណ្ឌិតត្រូវតែសរសេរបញ្ជាក់លើលិខិតមតកសាសន៍នោះ ព្រមទាំងចុះហត្ថលេខាផងដែរ។[13]

### ១.៣.២.៥ មតកសាសន៍របស់ជនដែលកំពុងជួបគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត

ជាទូទៅជីវិតមនុស្សគឺមិនទៀងទាត់នោះទេដោយមនុស្សអាចនឹងស្លាប់បានគ្រប់ពេល ហេតុនេះហើយច្បាប់បានចែងអំពីកាលៈទេសៈដែលមនុស្សនឹងជួបគ្រោះថ្នាក់ដល់ជីវិតនោះ និងផ្ដល់សិទ្ធិឲ្យជនទទួលរងគ្រោះនោះបានធ្វើមតកសាសន៍ទុកឲ្យទាយាទរបស់គេផងដែរ។ ដូចនេះប្រសិនបើជនដែលកំពុងជួបគ្រោះថ្នាក់ដល់ជីវិត ដូចជាមានជំងឺធ្ងន់ធ្ងរមានបំណងធ្វើមតកសាសន៍នោះ គាត់អាចធ្វើបានតាមរយៈលិខិតឯកជនក៏បាន ឬ ធ្វើជាលិខិតយថាភូតជាមួយសាការីក៏បានប្រសិន

[12] មាត្រា ១១៨១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា

[13] មាត្រា ១១៧៦ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា

បើធ្វើទៅបាន ប៉ុន្តែបើក្នុងកាលៈទេសៈបន្ទាន់ គាត់អាចធ្វើមតកសាសន៍បានដោយធ្វើការប្រកាសផ្ទាល់មាត់ចំពោះសាក្សីម្នាក់ក្នុងចំណោមសាក្សីទាំង ០៣ នាក់ ដែលច្បាប់បានតម្រូវឲ្យមាន។ ក្រោយមក ជនដែលបានទទួលការប្រកាសដោយផ្ទាល់មាត់ត្រូវសរសេរជាលាយល័ក្ខណ៍អក្សរ ហើយអានឲ្យសាក្សីស្ដាប់ ឬឲ្យមើល ហើយក្រោយពេលដែលបានមើល និងទទួលស្គាល់ថាត្រឹមត្រូវហើយនោះសាក្សីនីមួយៗ ត្រូវចុះហត្ថលេខាលើលិខិតនោះ។ សូមបញ្ជាក់ផងដែរជនដែលជាសាក្សីនៅក្នុងមតកសាសន៍ពុំអាចជាសន្តតិជនបានទេ ជៀសវាងមានបញ្ហានៅថ្ងៃក្រោយ[14]។

ក្រោយពីបានធ្វើរួចហើយ ជនដែលជាសាក្សី ឬ បុគ្គលដែលពាក់ព័ន្ធត្រូវតែដាក់ពាក្យសុំទៅតុលាការក្នុងអំឡុងពេល ១ ខែ ដោយគិតចាប់ពីថ្ងៃដែលបានធ្វើមតកសាសន៍នោះ ដើម្បីឲ្យតុលាការធ្វើការបញ្ជាក់លើភាពត្រឹមត្រូវរបស់មតកសាសន៍ ពីព្រោះថាលិខិតនេះបានធ្វើឡើងក្នុងករណីពិសេស ដូចនេះច្បាប់តម្រូវឲ្យជនពាក់ព័ន្ធដាក់ពាក្យសុំទៅតុលាការ ដើម្បីទុកឲ្យតុលាការដែលជាស្ថាប័នឯករាជ្យជាអ្នកវិនិច្ឆ័យ។ ប្រសិនបើតុលាការពុំមានជំនឿទុកចិត្តថាមតកសាសន៍នោះត្រឹមត្រូវដោយចេញពីឆន្ទៈពិតប្រាកដរបស់ម្ចាស់បណ្ដាំនោះ លិខិតមតកសាសន៍នេះនឹងមិនត្រូវបានបញ្ជាក់ពីតុលាការនោះទេ ហើយក៏គ្មានប្រសិទ្ធិភាពផងដែរ។

### ១.៣.២.៦. មតកសាសន៍នៃជនដែលត្រូវជាប់ឃុំឃាំង ជាអាទិ៍

ដោយសារតែពេលខ្លះមនុស្សបានប្រព្រឹត្តអំពើខុសច្បាប់ ហើយត្រូវបានដាក់ទោសឲ្យជាប់ពន្ធនាគារ ដែលទោសខ្លះមានរយៈពេលយូរខ្លាំង ដូចនេះទ្រព្យសម្បត្តិរបស់គាត់ដែលបន្សល់មុនពេលគាត់ចូលពន្ធនាគារនោះនឹងបន្សល់ទុកចោល ហេតុនេះហើយច្បាប់បានផ្ដល់សិទ្ធិឲ្យជនដែលជាប់ ឃុំឃាំងនេះធ្វើមតកសាសន៍បានផងដែរដើម្បីឲ្យមានអ្នកចាត់ចែងទ្រព្យសម្បត្តិរបស់ជននោះ ក្រែងគាត់ពុំអាចចេញពីពន្ធនាគារវិញបាន។ ក្នុងករណីបែបនេះម្ចាស់បណ្ដាំត្រូវមានវត្តមានរបស់នគរបាល ឬមន្ត្រីនៃមន្ទីរឃុំឃាំងម្ចាស់ និងសាក្សីយ៉ាងតិច ០២ នាក់ ដើម្បីបញ្ជាក់ពីលិខិតបណ្ដាំនោះ។ បើក្នុងករណីត្រូវជាប់ក្នុងនាវា ឬយន្តហោះវិញ គេអាចធ្វើលិខិតមតកសាសន៍ដោយត្រូវមានមេបញ្ជាការនាវា បរិបាលនាវា ឬ យន្តហោះ ឬ បុគ្គលិកនាវាឬយន្តហោះម្នាក់ និងសាក្សីយ៉ាងតិច ០២ នាក់។ ប្រសិនបើគាត់ពុំចេះអក្សរទេ ឬ មិនអាចសរសេរបានគាត់អាចធ្វើលិខិតនេះតាមរបៀបដូចលិខិតយថាភូតដែរ តែគឺនគរបាល ឬ មេបញ្ជាការនាវាជាអាទិ៍ ជាអ្នកដើរតួធ្វើជាសាការី។ ប៉ុន្តែលិខិតនេះ គឺមិនមែនជាលិខិតយថាភូតនោះទេ ព្រោះថានគរបាល ឬមេបញ្ជាការនាវាជាអាទិ៍ មិនមែនជាសាការីនោះទេ។

[14] មាត្រា ១១៧៧ នៃសេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី

បន្ទាប់ពីបានធ្វើលិខិតមតកសាសន៍ហើយ តែម្ចាស់បណ្តាំបែរជាបន្តនៅរស់ ព្រមទាំងបានរួចខ្លួនចេញពីការជាប់ឃុំនោះ ហើយគាត់បានទៅធ្វើលិខិតបណ្តាំប្រភេទផ្សេងទៀតដូចជាមតកសាសន៍តាមលិខិតឯកជន ឬយថាភូតទៅវិញ ដូចនេះអានុភាពនៃមតកសាសន៍ដែលបានធ្វើនៅពេលដែលជាប់ឃុំនោះគឺនឹងអស់សុពលភាពក្រោយអំឡុងពេល ៦ ខែ គិតចាប់ពីពេលដែលម្ចាស់បណ្តាំនោះបានធ្វើលិខិតបណ្តាំបែបថ្មី។ ការកំណត់អានុភាពបែបនេះ ព្រោះថាលិខិតដែលធ្វើពេលឃុំឃាំងនោះគឺគ្រាន់តែជាលិខិតបណ្តោះអាសន្នប៉ុណ្ណោះ ដោយហេតុថាម្ចាស់បណ្តាំមិនដឹងថាខ្លួនអាចបានរួចខ្លួនចេញមកវិញ ឬ មិនបានទេ។ ដូច្នេះហើយប្រសិនគាត់បានរួចចេញហើយនោះគាត់អាចនឹងធ្វើមតកសាសន៍ថ្មីទៀត ដែលអាចមានខ្លឹមសារខុសពីលិខិតចាស់ដែលម្ចាស់បណ្តាំកំពុងស្ថិតនៅក្នុងការជាប់ឃុំ ដូចនេះហើយបានជាច្បាប់កំណត់អានុភាពរបស់លិខិតបណ្តាំចាស់។[15]

## ១.៣.២.៧.មតកសាសន៍នៃបុគ្គលដែលមិនអាចនិយាយបាន ជាអាទិ៍

មនុស្សម្នាក់ៗកើតមកគឺមិនអាចមានលក្ខណៈសម្បត្តិដូចគ្នាទាំងស្រុងនោះទេ ហើយក្នុងករណីខ្លះទៀតមនុស្សកើតមកដោយមិនគ្រប់លក្ខណៈផ្នែកសារពាង្គកាយ ដូចជា គ ឬថ្លង់ជាដើម តែទោះបីជាមនុស្សមិនគ្រប់លក្ខណៈបែបនេះក៏ដោយ ពេលខ្លះក៏គេមានទ្រព្យសម្បត្តិបន្សល់ទុកឲ្យទាយាទរបស់គេដែរ។ ហេតុដូចនេះហើយច្បាប់ក៏បានចែងពីករណីពិសេសពាក់ព័ន្ធទៅនឹងមតកសាសន៍សម្រាប់ការពារប្រយោជន៍របស់មនុស្សទាំងនោះ។ យោងតាមក្រមរដ្ឋប្បវេណី បុគ្គលដែលមិនអាចនិយាយបាន តែចង់ធ្វើមតកសាសន៍តាមលិខិតយថាភូត ឬ មតកសាសន៍នៅពេលដែលកំពុងមានគ្រោះថ្នាក់បន្ទាន់នោះ គាត់អាចធ្វើបានដែរគ្រាន់តែត្រូវការផ្លាស់ប្តូរនីតិវិធីខ្លះៗ។ ដោយហេតុថាបើធ្វើតាមលិខិតយថាភូត ម្ចាស់បណ្តាំត្រូវធ្វើសេចក្តីថ្លែងការណ៍ពាក់ព័ន្ធនឹងខ្លឹមសារ ឬសេចក្តីថ្លែងការណ៍ថាលិខិត នោះពិតជាលិខិតមតកសាសន៍ដល់សាការីដើម្បីសរសេរ ឬ ដឹង តែបើក្នុងករណីដែលម្ចាស់បណ្តាំជា មនុស្សគនោះ ម្ចាស់បណ្តាំអាចជំនួសការថ្លែងនេះដោយពឹងពាក់អ្នកបកប្រែ ឬសរសេរដោយដៃខ្លួនផ្ទាល់ នៅចំពោះមុខសារការី ឬសាក្សីវិញក៏បាន។ ច្បាប់ធ្វើបែបនេះគឺដើម្បីសម្រួលដល់ម្ចាស់បណ្តាំ និងអាចធ្វើឲ្យខ្លឹមសារនៃបណ្តាំមានភាពត្រឹមត្រូវទាំងស្រុងផងដែរ។ ក៏ប៉ុន្តែបើក្នុងករណីដែលម្ចាស់បណ្តាំជាមនុស្សថ្លង់វិញនោះ ក្រោយពីសរសេរខ្លឹមសារបណ្តាំហើយ សារការី ឬបុគ្គលដែលកំណត់ក្នុងច្បាប់នោះ ត្រូវអានខ្លឹមសារម្តងទៀតឲ្យម្ចាស់បណ្តាំស្តាប់ដើម្បីបញ្ជាក់ថាខ្លឹមសារគឺត្រឹមត្រូវតាមអ្វីដែលម្ចាស់បណ្តាំចង់បានហើយ តែដោយសារតែម្ចាស់បណ្តាំជាមនុស្សថ្លង់នោះ ដូចនេះអ្នកដែលត្រូវអាច អាចជំនួសការអានឲ្យម្ចាស់បណ្តាំ ឬ

[15] មាត្រា ១១៧៨ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា

សាក្សីស្ដាប់នោះ ទៅជាការបកប្រែតាមអ្នកបកប្រែវិញ។ ក្រោយពីបានធ្វើលិខិតនេះហើយនោះ បើទោះបីជាក្នុងករណីម្ចាស់បណ្ដាំជាមនុស្ស គ ឬថ្លង់ក៏ដោយ សារការី ឬបុគ្គលដែលពាក់ព័ន្ធ ត្រូវសរសេរបញ្ជាក់អំពីមូលហេតុដែលខ្លួនប្រើប្រាស់របៀបនេះក្នុងការធ្វើលិខិតនេះ ជៀសវាងមានការតវ៉ាពីភាពត្រឹមត្រូវរបស់លិខិតបណ្ដាំ[16]។

[16] មាត្រា ១១៧៩ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា

# ជំពូកទី ២

# ការយល់ព្រមចំពោះសន្តតិកម្ម

## ២.១. គោលគំនិតទូទៅ

ដូចដែលបានរៀបរាប់ត្រួសៗខាងលើរួចមកហើយ ដើម្បីជៀសវាងនូវភាពអយុត្តិធម៌ដែលសាច់ញាតិនានា ត្រូវទទួលរងនូវការសងបំណុលជំនួសមតកជន ច្បាប់បានផ្តល់សិទ្ធិអាទិភាពដល់សន្តតិជនដើម្បីសម្រេចចិត្តក្នុងការទទួលយក ឬ បោះបង់នូវសន្តតិកម្មដែលខ្លួននឹងទទួលយកនោះ។ ប្រសិនបើសន្តតិជនយល់ឃើញថា សន្តតិកម្មដែលខ្លួននឹងទទួលមានសិទ្ធិធំជាងកាតព្វកិច្ចនោះ គេអាចសម្រេចទទួលយកបាន។

ជាទូទៅ កាលណាសន្តតិជនសម្រេចចិត្តយល់ព្រមចំពោះសន្តតិកម្ម មានន័យថាសន្តតិជនព្រមព្រៀងក្នុងការទទួលយកទាំងសិទ្ធិ និងករណីយកិច្ចទាំងឡាយ ដែលមានក្នុងសន្តតិកម្មនោះ។ ចំពោះការយល់ព្រមទទួលយកសន្តតិកម្ម សន្តតិជនត្រូវធ្វើការសម្រេចចិត្តក្នុងអំឡុងពេលដែលច្បាប់បានផ្តល់ទៅឲ្យខ្លួនដោយផ្អែកលើស្ថានភាពធម្មតា និងស្ថានភាពពិសេស។ ម្យ៉ាងទៀត សន្តតិជនអាចមានជម្រើសពីរចំពោះការយល់ព្រមទទួលសន្តតិកម្ម ដោយគាត់អាចយល់ព្រមទទួលយកសន្តតិកម្មនោះទាំងស្រុង ឬ ទទួលយកដោយមានកម្រិត។

## ២.២.ការយល់ព្រមទាំងស្រុងចំពោះសន្តតិកម្ម

ជាទូទៅ ក្រោយពីធ្វើការពិចារណាក្នុងអំឡុងពេលដែលបានកំណត់រួចហើយសន្តតិជននឹងធ្វើការសម្រេចក្នុងការទទួលយកសន្តតិកម្ម តាមរយៈការទទួលយល់ព្រមទាំងស្រុង ប្រសិនបើយល់ឃើញថាខ្លួនទទួលបានប្រយោជន៍ពីសន្តតិកម្មនោះ។ នៅពេលដែលសន្តតិជនធ្វើការយល់ព្រមទាំងស្រុងលើសន្តតិកម្ម មានន័យថា សន្តតិជនយល់ព្រមទទួលបន្តនូវសិទ្ធិ និងកាតព្វកិច្ច ដែលមាន ភ្ជាប់ជាមួយនឹងមតិកដោយគ្មានកម្រិត[17]។

ដើម្បីស្វែងយល់ ឲ្យកាន់ច្បាស់អំពីការយល់ព្រមទាំងស្រុង នីតិវិធីនៃការយល់ព្រមទាំងស្រុង និងអានុភាពនៃការយល់ព្រមទាំងស្រុង គឺជាចំណុចដែលត្រូវពិចារណា និងពន្យល់បកស្រាយ។

[17] មាត្រា ១២៥៤ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា

## ២.២.១ នីតិវិធីនៃការយល់ព្រមទាំងស្រុង

ក្នុងការយល់ព្រមនេះ សន្តតិជនអាចយល់ព្រមទទួលសន្តតិកម្មទាំងស្រុងបានទៅតាមនីតិវិធីមួយចំនួនផងដែរ។ សន្តតិជនអាចសម្តែងឆន្ទៈរបស់ខ្លួននូវការយល់ព្រមទៅលើសន្តតិកម្មដោយអាចធ្វើការចាត់ចែងលើមត៌កដែលទទួលនោះទាំងអស់ ឬមួយភាគ។ ដោយសារតែសន្តតិជនបានបង្ហាញឆន្ទៈ និងសកម្មភាពជាម្ចាស់កម្មសិទ្ធិទៅលើមត៌ក ដូចនេះយោងតាមសកម្មភាពនេះ គេអាចកំណត់បានថាសន្តតិជនយល់ព្រមទទួលសន្តតិកម្មហើយ ព្រោះថាគាត់បានធ្វើការចាត់ចែងដើម្បីទទួលប្រយោជន៍ពី មត៌កទាំងនោះដូចជាជួល ឬលក់ដូរ ជាដើម ដែលវាបង្ហាញឲ្យឃើញនូវឆន្ទៈដែលសន្តតិជនបានចាត់ទុកទ្រព្យនៃសន្តតិកម្មជារបស់ខ្លួន និងអាស្រ័យផលទៅលើទ្រព្យទាំងនោះ។ ប៉ុន្តែមានករណីពិសេសមួយដែលគេមិនអាចចាត់ទុកជាការយល់ព្រមនោះទេ ប្រសិនបើសន្តតិជនធ្វើការចាត់ចែងលើមត៌កក្នុងគោលបំណងថែរក្សា និងមានសកម្មភាពត្រឹមតែជាការគ្រប់គ្រងដូចជាការកាប់ព្រៃ កាត់ស្មៅ ស្រោចដំណាំ ឬធ្វើរបងដើម្បីកុំឲ្យមានការបំពានពីជនទុច្ចរិតជាដើម បើសិនជាមានសកម្មភាពបែបនេះគេមិនអាចចាត់ទុកវាថាជាយល់ព្រមទទួលដោយមានការចាត់ចែងនោះទេ ព្រោះថាប្រសិនបើសន្តតិជនមិនធ្វើការថែរក្សា ឬគ្រប់គ្រងលើមត៌កនោះ វាអាចនឹងខូចខាត ឬត្រូវគេបំពាន និងប្រើប្រាស់ក្នុងគោលបំណងទុច្ចរិតជាដើម ដូចជាការចូលក្នុងដីដែលមិនមានអ្នកថែរក្សាដើម្បីប្រើប្រាស់គ្រឿងញៀន។

ក្រៅពីការបង្ហាញឆន្ទៈ ក៏មានករណីមួយទៀតដែលច្បាប់ជាអ្នកកំណត់ថាសន្តតិជននោះទទួលយកទាំងស្រុងតែម្តង បើទោះបីជាគាត់មិនបង្ហាញឆន្ទៈថាទទួលក៏ដោយ។ ដែលករណីនេះគឺជាកើតឡើងនៅពេលដែលសន្តតិជនមិនបានធ្វើការបង្ហាញឆន្ទៈថាខ្លួនយល់ព្រមដោយកម្រិត ឬបោះបង់សន្តតិកម្មនៅក្នុងអំឡុងពេល ០៣ ខែដែលច្បាប់បានបើកសិទ្ធិឲ្យសម្រេចនោះ។ ច្បាប់បានកំណត់ថាសន្តតិជនយល់ព្រមទាំងស្រុងលើសន្តតិកម្មនោះ ព្រោះថាច្បាប់បានបើកសិទ្ធិឲ្យគាត់បោះបង់ ឬ យល់ព្រមដោយកំរិតដែរ ប៉ុន្តែក្នុងអំឡុងពេលនោះគាត់មិនបានសម្រេចអ្វីទាំងអស់សូម្បីតែបោះបង់ ឬយល់ព្រមដោយកំរិតក៏មិនបានធ្វើការសម្រេចថាយកមួយណាដែរ ដូចនេះច្បាប់កំណត់ថាគាត់មិនបានបដិសេធចំពោះសន្តតិកម្មនេះទេ។ ម្យ៉ាងទៀតច្បាប់កំណត់បែបនេះព្រោះថាច្បាប់បានបើកសិទ្ធិឲ្យសន្តតិជនក្នុងការសម្រេច តែសន្តតិជនបែរជាមិនបំពេញសិទ្ធិនោះទៅវិញ ដូចនេះគេចាត់ទុកថា សន្តតិជនបានទទួលយកសន្តតិកម្មនេះដោយតុណ្ហីភាព ពោលគឺការបង្ហាញឆន្ទៈដោយស្ងៀមស្ងាត់។

នីតិវិធីមួយប្រភេទទៀតក៏ជាការកំណត់របស់ច្បាប់ដែរនូវការទទួលយកទាំងស្រុងលើសន្តតិកម្មចំពោះសន្តតិជន។ ដោយច្បាប់ចាត់ទុកថាសន្តតិជនយល់ព្រមទាំងស្រុងដោយត្រូវទទួលបន្តដោយគ្មានកម្រិត ក្នុងករណីដែលសន្តតិជននេះបានធ្វើការបំពានលើការយល់ព្រមរបស់ខ្លួន ដូចជាធ្វើផ្ទុយពីការយល់ព្រមដោយមានកម្រិត ឬ បោះបង់ចោលនូវសន្តតិកម្ម[18]។ ក្នុងករណីនេះប្រសិនបើសន្តតិជនបានធ្វើការយល់ព្រមដោយមានកម្រិត ឬបោះបង់សន្តតិកម្មហើយ ប៉ុន្តែគាត់បែរជាធ្វើការលាក់ ឬ យកទ្រព្យសម្បត្តិនោះទៅប្រើប្រាស់មួយភាគ ឬ ទាំងអស់ដើម្បីប្រយោជន៍ផ្ទាល់ខ្លួនទៅវិញ ដោយវាបង្ហាញពីឆន្ទៈមិនស្មោះត្រង់របស់សន្តតិជន ព្រោះថាពេលខ្លះសន្តតិជនលួចលាក់ទ្រព្យសម្បត្តិដែលនៅក្រៅពីយល់ព្រមរបស់ខ្លួននោះដើម្បីយកមកលក់ ឬ ជួលដើម្បីទទួលបានប្រយោជន៍ផ្ទាល់ខ្លួន ព្រមទាំងមិនចង់ទទួលខុសត្រូវលើកាតព្វកិច្ចដែលមានលើចំណែកនោះ។ បើយោងតាមសកម្មភាពរបស់សន្តតិជនបែបនេះ ច្បាប់ក្រមរដ្ឋប្បវេណីរបស់ប្រទេសកម្ពុជាបានសម្រេចថាឲ្យសន្តតិជននេះទទួលខុសត្រូវទាំងស្រុងលើមតិកទាំងអស់ ដែលរួមមានទាំងបំណុលលើមតិកនោះផងដែរដើម្បីឲ្យមានភាពយុត្តិធម៌ និងជាទណ្ឌកម្មផងដែរ ព្រោះថាគាត់មានចេតនាទុច្ចរិតដែលអាចនាំឲ្យខូចខាតដល់ប្រយោជន៍របស់សន្តតិជនដ៏ទៃទៀត។ ប៉ុន្តែក្នុងករណីដែលសន្តតិជនលំដាប់មុនបានសម្រេចថាបោះបង់ ហើយសន្តតិជនលំដាប់ក្រោយបានសម្រេចទទួលយកនូវមតិកដែលមានក្នុងសន្តតិកម្ម ដូចនេះត្រូវតែប្រគល់មតិកទៅឲ្យសន្តតិជនលំដាប់ក្រោយវិញ ប្រសិនបើសន្តតិជនលំដាប់មុនមានចេតនាទុច្ចរិតដោយយកមតិក ជួល លក់ ឬសកម្មភាពនានាដែលប៉ះពាល់ដល់មតិក ឬ ប្រយោជន៍របស់សន្តតិជនលំដាប់ក្រោយនោះ ច្បាប់ក៏មិនអាចបង្ខំឲ្យសន្តតិជនលំដាប់មុននោះមកទទួលសន្តតិម្មទាំងស្រុងវិញដែរ ព្រោះថាគាត់បានបោះបង់ហើយ ព្រមទាំងបានទទួលដោយសន្តតិជនលំដាប់ក្រោយហើយ ដូចនេះមិនអាចដកហូតពីសន្តតិជនលំដាប់ក្រោយទៅឲ្យសន្តតិជនលំដាប់មុនវិញបានទេ។ ប៉ុន្តែ ច្បាប់បានបើកផ្លូវឲ្យសន្តតិជនលំដាប់ក្រោយ អាចធ្វើការទាមទារឲ្យសន្តតិជនលំដាប់មុនប្រគល់មតិកទាំងនោះចេញមកវិញ ឬទាមទារឲ្យសងនូវសំណងខូចខាតនានា ដែលកើតចេញពីទង្វើទុច្ចរិតរបស់សន្តតិជនលំដាប់មុនទៅលើសន្តតិជនក្រោយ ដោយគេអាចដាក់ពាក្យបណ្តឹងទៅតុលាការបានដើម្បីទាមទារសំណងខូចខាតទាំងនេះ[19]។

[18] មាត្រា ១២៥៥ នៃសេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី

[19] មាត្រា ១២៥៥ នៃសេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី

### ២.២.២ អានុភាពនៃការយល់ព្រមទាំងស្រុង

បន្ទាប់ពីបានធ្វើការយល់ព្រមហើយនោះ ការសម្រេចនេះនឹងមានអានុភាពចំពោះសន្តតិជន។ ដូចនេះនៅពេលដែលសន្តតិជនបានយល់ព្រមទាំងស្រុងហើយបានន័យថា ទោះបីជាមតិកនោះមានជាប់បំណុលច្រើនយ៉ាងណាក៏ដោយ ឬរហូតដល់ច្រើនជាងតម្លៃនៃមតិកនោះទៀតក៏សន្តតិជនត្រូវមានកាតព្វកិច្ចសងបំណុលដែលមាននោះឲ្យអស់ ពោលគឺត្រូវទទួលសិទ្ធិ និងកាតព្វកិច្ចទាំងស្រុងលើមតិកនោះ។ ឧទាហរណ៍ថា បុគ្គល ក បានខ្ចីប្រាក់របស់ បុគ្គល ខ ចំនួន USD ៤០០,០០០ ហើយក្រោយពីបានខ្ចីហើយនោះ បុគ្គល ក ស្រាប់តែមានគ្រោះថ្នាក់ស្លាប់បាត់ទៅដោយបន្សល់កូនពីរនាក់ ដូចនេះប្រសិនបើកូនទាំងពីរនាក់នោះសម្រេចចិត្តយល់ព្រមទទួលសន្តតិកម្មរបស់បុគ្គល ក ដោយគ្មានកម្រិតនោះ កូនទាំងពីរនាក់នោះត្រូវតែសងបំណុលទាំងអស់ឲ្យរួច។ ក្នុងករណីបែបនេះប្រសិនបើបុគ្គល ក បានបន្សល់ទ្រព្យជាមតិកចំនួនUSD១០០,០០០ ដូចនេះកូនទាំងពីរនាក់នោះត្រូវបែងចែកទ្រព្យដែលជាមតិកនោះជាពីរស្មើគ្នា និងទទួលកាតព្វកិច្ចលើមតិកនោះស្មើគ្នាផងដែរ ដោយក្នុងម្នាក់ត្រូវយកប្រាក់ផ្ទាល់ខ្លួនក្រៅពីមតិកដើម្បីសងចំនួន USD ១៥០,០០០ ទៀត។ ប៉ុន្តែក្នុងករណីដែលកូនទាំងពីរនោះបានទទួលសន្តតិកម្មនេះ ប៉ុន្តែគាត់ពុំបានដឹងអំពីអត្ថិភាពនៃបំណុលដែលមានលើមតិកនោះទេ ហើយក្រោយពីបានយល់ព្រមទទួលមតិកនេះហើយទើបបានដឹងអំពីបំណុលដែលមានលើមតិកនោះ ដូចនេះការយល់ព្រមដោយមានការចាត់ចែងតាមមាត្រា ១២៥៥ នៃក្រមរដ្ឋប្បវេណី ពុំមានអានុភាពនោះទេ[20]។

## ២.៣ ការយល់ព្រមដោយមានកម្រិត

ក្រៅពីការយល់ព្រមទាំងស្រុងហើយ ច្បាប់បានបើកសិទ្ធិឲ្យសន្តតិជនសម្រេចទទួលយកសន្តតិកម្មដោយមានកម្រិតផងដែរ បានន័យថាគឺទទួលតែមួយចំណែកប៉ុណ្ណោះ។ យើងអាចសង្កេតឃើញបានថាការបោះបង់ និងការទទួលយកមានកម្រិតនេះគឺវាមានលក្ខណៈស្រដៀងនឹងគ្នាដែរ ព្រោះថាការយល់ព្រមមានកម្រិតបានន័យថាសន្តតិជនបោះបង់មតិកមួយចំនួនចោល។ ច្បាប់បានបើកផ្តល់សិទ្ធិដល់សន្តតិជនបែបនេះ ព្រោះថាពេលខ្លះមនុស្សយើងអាចមានគំនិតថា ឬជឿថាមតកជនដែលជាឪពុក ម្តាយ ឬសាច់ញាតិដែលបានទទួលមរណភាពទៅហើយ គឺមិនចង់ឲ្យពួកគាត់នៅជាប់បំណុល គេទៀតនោះទេ ដោយហេតុថាខ្លាចមតកជនមានជាប់កម្មពារ ឬបំណុលទៅជីវិតក្រោយទៀត។ ដោយសារតែជំនឿ និងការគិតបែបនេះ ច្បាប់បានផ្តល់សិទ្ធិឲ្យសន្តតិជនអាចយល់

[20] មាត្រា ១២៥១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា

ព្រមដោយកម្រិត ដើម្បីធ្វើការដោះបំណុលខ្លះរបស់មតកជនក្រោយពេលដែលមតកជនបានស្លាប់ទៅ។ ដូចនេះគេត្រូវតែយល់ឲ្យច្បាស់នូវការយល់ព្រមប្រភេទនេះ។

ការយល់ព្រមដោយមានកម្រិត ជាការទទួលនូវចំណែកមត៌កពីសន្តតិជនត្រឹមតែកម្រិតណាមួយប៉ុណ្ណោះ ពោលគឺមួយចំណែកនៃមត៌ករបស់មតកជន។ ក្នុងចំនុចនេះយើងអាចឃើញថាច្បាប់បានតម្រូវឲ្យ សន្តតិជនអាចបម្រុងទុកនូវសំណងកាតព្វកិច្ចដែលមានលើមត៌ក ប៉ុន្តែការទទួលខុសត្រូវលើ មត៌កនេះគឺត្រឹមតែកម្រិតដែលសន្តតិជនបានទទួលប៉ុណ្ណោះ បានន័យថាប្រសិនបើសន្តតិជនទទួលចំណែកមត៌កនៃសន្តតិកម្មនោះប៉ុន្មានភាគ សន្តតិជននោះត្រូវទទួលនូវកាតព្វកិច្ចនោះស្មើនឹងចំណែកភាគដែលគេយល់ព្រមទទួលនោះ[21]។

ឧទាហរណ៍ថា ប្រសិនបើបុគ្គល ខ ដែលជាសន្តតិជនរបស់មតកជន ក បានយល់ព្រមទទួលសន្តតិកម្មត្រឹមតែ ១/២ នៃទ្រព្យដែលជាមត៌ករបស់មតកជននោះ ដូចនេះ បុគ្គល ខ ត្រូវទទួលកាតព្វកិច្ច ១/២ នៃបំណុលដូចគ្នា ពោលគឺមានប្រភាគស្មើនឹងមត៌កដែលបានទទួល។ ដូចនេះ សន្តតិជនត្រូវធ្វើការសងនូវកាតព្វកិច្ចដែលបានទទួលដោយសន្តតិកម្ម ដោយសងត្រឹមតែកម្រិតនៃទ្រព្យដែលបានទទួលដោយសន្តតិកម្មប៉ុណ្ណោះ។

ប្រសិនបើមានសន្តតិជនច្រើននាក់វិញ ការយល់ព្រមដោយមានកម្រិតអាចធ្វើបានលុះត្រាតែសហសន្តតិជននោះបានធ្វើដោយរួមគ្នាទាំងអស់ មានន័យថាសហសន្តតិជនត្រូវធ្វើការយល់ព្រមដោយមានកម្រិតទាំងអស់គ្នាតែម្តងទើបអាចដំណើរការបាន ហើយបើសិនជាមានសន្តតិជនម្នាក់ក្នុងចំណោមសហសន្តតិជនទាំងអស់ ដាច់ខាតមិនយល់ព្រមដោយធ្វើឲ្យមានបញ្ហានោះ គេនឹងបែងចែក មត៌កនេះទៅតាមច្បាប់វិញដើម្បីជៀសវាងមានបញ្ហា។ ការទទួល សន្តតិកម្មបែបនេះក៏មាននីតិវិធី និងអានុភាពរបស់វាផងដែរដែលនឹងរៀបរាប់នៅចំនុចបន្ទាប់នេះ។

### ២.៣.១. នីតិវិធីនៃការយល់ព្រមដោយមានកម្រិត

នៅពេលដែលសន្តតិជនបានយល់ព្រមទទួលសន្តតិកម្មរបស់មតកជនដោយមានកម្រិត ហើយសន្តតិជនមិនអាចគ្រាន់តែនិយាយដោយផ្ទាល់មាត់បានទេ សន្តតិជនត្រូវតែធ្វើទៅតាមនីតិវិធីច្បាប់ដោយត្រូវដាក់ពាក្យសុំអំពីការយល់ព្រមដោយកម្រិតទៅតុលាការនៅក្នុងអំឡុងពេល ៣ ខែ ដែលជាអំឡុងពេលនៃការយល់ព្រមរបស់សន្តតិជន[22]។ ពោលគឺធ្វើបែបនេះដើម្បីដឹងថាសន្តតិជនយល់ព្រមទទួលកាតព្វកិច្ចលើទ្រព្យដែលជាមត៌កនោះត្រឹមកម្រិតណា ព្រោះថាប្រសិនបើសន្តតិកម្ម

[21] មាត្រា ១២៥៦ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា

[22] មាត្រា ១២៥៧ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា

នោះមានជាប់កាតព្វកិច្ចដូចជាបំណុល ម្ចាស់បំណុលច្បាស់ជាដាក់ពាក្យទៅតុលាការដើម្បីទាមទារបំណុលនោះ ដោយធ្វើការលក់នូវទ្រព្យសម្បត្តិរបស់សន្តតិជនដែលនៅសល់ដើម្បីសងបំណុលជាដើម។ ដូចនេះគេត្រូវដាក់ពាក្យសុំទៅតុលាការ ជៀសវាងតុលាការយល់ឃើញថាសន្តតិជនបានធ្វើការយល់ព្រមទាំងស្រុងលើសន្តតិកម្មដូចមានចែងក្នុងមាត្រា ១២៥៥ នៃក្រមរដ្ឋប្បវេណីអំពីការយល់ព្រមទាំងស្រុងដោយមិនបានយល់ព្រមដោយកម្រិត ឬបោះបង់។ ម្យ៉ាងទៀតការដាក់ពាក្យសុំទៅតុលាការនេះក៏អាចផ្តល់ភាពងាយស្រួលដល់តុលាការ ក្នុងការទូទាត់ទ្រព្យសម្បត្តិរបស់មតកជនដែលនៅសល់នោះទៅឲ្យម្ចាស់បំណុលវិញ និងអាចដឹងថាសន្តតិជនមានកាតព្វកិច្ចត្រឹមកម្រិតដើម្បីសងកាតព្វកិច្ចរបស់ខ្លួន។ បន្ថែមពីនេះទៀត នៅពេលដែលគេយល់ព្រមដោយកម្រិតបែបនេះ សន្តតិជនត្រូវធ្វើបញ្ជីសារពើភ័ណ្ឌផងដែរនៅពេលដែលគេដាក់ពាក្យសុំទៅតុលាការនោះ ដើម្បីធ្វើការរាយនាមវត្ថុដែលជាមតិកដែលគេយល់ព្រមទទួលនោះ ក្នុងគោលបំណងឲ្យតុលាការដឹងថាទ្រព្យសម្បត្តិដែលជាមតិកមានអ្វីខ្លះ ព្រមទាំងដឹងថាសន្តតិជនបានយល់ព្រមទទួលយកទ្រព្យណាខ្លះងាយស្រួលឲ្យតុលាការគណនានៃតម្លៃ និងកាតព្វកិច្ចរបស់សន្តតិជន។

ពេលដែលសន្តតិជន បានដាក់ពាក្យសុំក្នុងការទទួលខុសត្រូវមានកម្រិតទៅតុលាការហើយ តុលាការមិនចាំបាច់ធ្វើការទាញហេតុផលដោយផ្ទាល់មាត់ក៏បានដែរ [23] ព្រោះថារឿងក្តីប្រភេទនេះគឺគេហៅថាជារឿងក្តីរដ្ឋប្បវេណីមិនមែនជាបណ្តឹងដែលត្រូវសម្រេចដោយដីកាសម្រេច[24]។ ទោះបីជាយ៉ាងណាក្តីយោងតាមមាត្រា ២៨ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង តុលាការមានសិទ្ធិកោះហៅ និងសាកសួរអ្នកដាក់ពាក្យសុំ ភាគីម្ខាងទៀត ឬជនផ្សេងទៀតដែលតុលាការយល់ឃើញថាចាំបាច់បាន ដើម្បីទទួលបានចម្លើយជាលាយលក្ខណ៍អក្សរ ឬផ្ទាល់មាត់ពីគ្រប់ភាគីចាំបាច់ជៀសវាងមានការមិនយល់ព្រមណាមួយ ហើយតុលាការក៏អាចអនុញ្ញាតឲ្យអ្នកដែលតុលាការយល់ថាសមរម្យចូលស្តាប់ជាអ្នកសង្កេតការណ៍បានដែរ។ ម្យ៉ាងទៀតតុលាការអាចធ្វើការស្រាវជ្រាវអង្គហេតុ និងធ្វើការពិនិត្យភស្តុតាងដោយឆន្ទានុសិទ្ធិបាន[25] ម្យ៉ាងទៀតបើរឿងក្តីមានពាក់ព័ន្ធដល់ប្រយោជន៍ សាធារណៈនោះ តុលាការត្រូវជូនដំណឹងទៅតំណាងអយ្យការអំពីរឿងក្តី និងកាលបរិច្ឆេទនៃការសួរ[26]។ ក្រោយពីបានពិនិត្យភស្តុតាង និងសាកសួរជនដែលពាក់ព័ន្ធហើយ តុលាការត្រូវចេញដីកាសម្រេច និងត្រូវជូនដំណឹងពីដីកាសម្រេចទៅជនដែលត្រូវទទួលដីកា

[23] មាត្រា ២៨ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង
[24] មាត្រា ៣ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង
[25] មាត្រា ២៧ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង
[26] មាត្រា ៣០ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង

សម្រេចនេះ[27]។ ប៉ុន្តែនៅពេលដែលចេញដីកាសម្រេចនេះហើយ វាក៏មិនទាន់ចូលជាស្ថាពរភ្លាមដែរ លុះត្រាតែផុតអំឡុងពេលប្តឹងជំទាស់សិន [28] ពោលគឺតុលាការបើកសិទ្ធិឲ្យជនទទួលឥទ្ធិពលដែលខូចប្រយោជន៍ដល់សិទ្ធិ ឬឋានៈគតិយុត្តរបស់ខ្លួនដោយសារដីការសម្រេចនេះអាចប្តឹងជំទាស់ចំពោះដីកាសម្រេចបាន ដែលអំឡុងពេល ២ សប្តាហ៍ គិតចាប់ពីពេលដែលបានទទួលដំណឹងអំពីដីកាសម្រេចនោះហើយ បើជនដែលអាចប្តឹងជំទាស់មិនមែនជាជនដែលត្រូវទទួលនូវការជូនដំណឹងអំពីដីកាសម្រេចទេ បណ្តឹងជំទាស់ត្រូវធ្វើឡើងក្នុងអំឡុងពេល ២ សប្តាហ៍គិតចាប់ពីថ្ងៃដែលជនដាក់ពាក្យសុំបានទទួលការជូនដំណឹង[29] ។ យោងតាមមាត្រា ៣៧ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ប្រសិនបើផុតអំឡុងពេលជំទាស់ដោយគ្មានការជំទាស់ក្នុងនោះទេ ដីកាសម្រេចនឹងចូលជាស្ថាពរ ហើយក្លាយទៅជាលិខិតអនុវត្ត។

### ២.៣.២ អានុភាពនៃការយល់ព្រមដោយមានកម្រិត

នៅពេលដែលសន្តតិជនបានធ្វើការយល់ព្រមដោយមានកម្រិតហើយនោះ អានុភាពនៃសន្តតិកម្មគឺមានត្រឹមតែកម្រិតដែលបានទទួលប៉ុណ្ណោះ ពោលគឺសន្តតិជនមានកាតព្វកិច្ចត្រូវសងចំពោះកាតព្វកិច្ចសមាមាត្រនឹងភាគដែលសន្តតិជនបានទទួលប៉ុណ្ណោះ ដូចនេះម្ចាស់បំណុលមិនអាចធ្វើការប្តឹងទាមទារចំពោះសន្តតិជន ឲ្យយកទ្រព្យផ្ទាល់ខ្លួនរបស់សន្តតិជនមកសងនូវបំណុលដែលលើសពីភាគដែលសន្តតិជនបានទទួលជាដាច់ខាត[30] ។ ទោះបីជាមតកជនជំពាក់ប្រាក់ម្ចាស់បំណុលច្រើនយ៉ាងណាក៏ដោយ នៅពេលដែលសន្តតិជនបានសងកាតព្វកិច្ចរបស់ខ្លួនចំពោះសន្តតិកម្មរួច ម្ចាស់បំណុលមិនអាចធ្វើការបង្ខំឲ្យសន្តតិជនសងគេនោះទេ ពោលម្ចាស់បំណុលបានត្រឹមតែដាក់ពាក្យ បណ្តឹងទៅតុលាការ ដើម្បីឲ្យតុលាការធ្វើការលក់ឡៃឡុងទ្រព្យដែលនៅសល់ពីការទទួលយកដោយកម្រិតនោះដើម្បីសងបំណុល ហើយបើនៅតែសងមិនគ្រប់ទៀតនោះគឺបំណុលដែលនៅសល់នោះមិនអាចទាមទារបានទៀតនោះទេ។ ប៉ុន្តែករណីបែបនេះ វាអាចកើតមានឡើងចំពោះតែមនុស្សធម្មតាដែលតែងតែយោគយល់ពីមនោសញ្ចេតនាគ្នាប៉ុណ្ណោះ ដែលពួកគាត់តែងតែឲ្យកូនបំណុលខ្ចីប្រាក់ដោយមិនចាំបាច់មានវត្ថុធានាអ្វីឡើយ ដែលជាហេតុធ្វើឲ្យពួកគាត់ជួបប្រទះនឹងហានិភ័យបែបនេះ។ ចំពោះករណីក្រុមហ៊ុននានា ដូចជាធនាគារជាដើម ពួកក្រុមហ៊ុនបែបនេះតែងតែទាមទារឲ្យមានវត្ថុធានាដើម្បីបង្ការពេលដែលកូនបំណុលមិនអាចសងបាន

[27] មាត្រា ៣៦ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង

[28] មាត្រា ៣៧ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង

[29] មាត្រា ៤០ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង

[30] មាត្រា ១២៥៨ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា

ម្យ៉ាងទៀតនៅពេលដែលខ្ចីប្រាក់នោះ ធនាគារឬក៏ក្រុមហ៊ុនតែងតែផ្តល់នូវប្រាក់កម្ចីតិចជាងតម្លៃរបស់វត្ថុធានា ពោលគឺជាវិធីសាស្ត្រដ៏ល្អក្នុងការបង្ការពី ហានិភ័យនៃការខាតបង់ប្រាក់របស់ខ្លួន។

ម្យ៉ាងវិញទៀតចំពោះសិទ្ធិ និងករណីយកិច្ចនៅក្នុងមតិកដែលមានការយល់ព្រមដោយមានកម្រិតនេះគឺមិនអាចចាត់ទុករលត់ដោយព្យាកុលភាពនោះទេ ពីព្រោះថាទ្រព្យសម្បត្តិដែលជាមតិករបស់មតកជននេះ ត្រូវយកទៅជំរះបញ្ជីជាមុនសិនមុននឹងធ្វើការបែងចែកមកឲ្យសន្តតិជនគឺធ្វើការគណនាកាត់កងបំណុលសិនដើម្បីការពារផលប្រយោជន៍របស់សន្តតិជនផ្សេងទៀត។ ដូច្នេះបានន័យថាប្រសិនបើមានសន្តតិជនផ្សេងទៀតដែលមិនស្ថិតក្នុងលក្ខខណ្ឌនៃព្យាកុលភាព ហើយបែរជាឲ្យសិទ្ធិ និងកាតព្វកិច្ចរបស់សន្តតិជនដែលស្ថិតក្នុងលក្ខខណ្ឌនៃព្យាកុលភាពនេះរលត់ វានឹងមានការប៉ះពាល់ដល់សន្តតិជនផ្សេងទៀត ព្រោះថាវានឹងធ្វើឲ្យមានការបាត់បង់នូវទ្រព្យដែលមាននៅក្នុងសន្តតិកម្មនោះ ដូចនេះចាំបាច់ត្រូវធ្វើការជម្រះបញ្ជីដោយនីតិវិធីដូចគ្នានឹងការជម្រះបញ្ជីសិទ្ធិលើបំណុល និងកាតព្វកិច្ចផ្សេងដែរដើម្បីជៀសវៀងពីបញ្ហាទាំងអស់នេះ[31]។

ក្នុងករណីមួយវិញទៀត ដែលអានុភាពយល់ព្រមដោយមានកំរិតត្រូវបានរលត់ គឺនៅពេលដែលសន្តតិជនបានធ្វើការយល់ព្រមដោយកំរិតហើយប៉ុន្តែបែរជាមិនសរសេរទ្រព្យទាំងអស់ ឬមួយភាគ នៅក្នុងបញ្ជីសារពើភ័ណ្ឌដោយទុច្ចរិតនោះ ច្បាប់បានចាត់ទុកថាសន្តតិជននោះយល់ព្រមទាំងស្រុងតែម្តងទៅលើសន្តតិកម្មនោះ។ មូលហេតុ គឺគាត់បានទទួលផលប្រយោជន៍ពីការយល់ព្រមដោយកម្រិតនោះរួចហើយ ប៉ុន្តែសន្តតិជននោះបែរជាធ្វើការលាក់បាំងនូវទ្រព្យផ្សេងទៀតដោយមិនសរសេរចូលក្នុងបញ្ជីសារពើភ័ណ្ឌ ដែលធ្វើឲ្យមានការប៉ះពាល់ដល់ម្ចាស់បំណុល ដូចនេះដើម្បីមានភាពយុត្តិធម៌ និងដាក់ពិន័យដល់សន្តតិជនទុច្ចរិតផងនោះ ច្បាប់បានបង្គាប់ឲ្យសន្តតិជននោះទទួលខុសត្រូវទាំងស្រុងលើសិទ្ធិ និងកាតព្វកិច្ចនៃមតិកក្នុងសន្តតិកម្មនោះ ហើយសេចក្តីថ្លែងការណ៍ដែលសន្តតិជនបានដាក់ចូលទៅតុលាការនោះ ចាត់ទុកថាគ្មានអានុភាពតាំងពីដំបូងមកម្ល៉េះ[32]។

ប៉ុន្តែប្រសិនបើក្នុងការធ្វើសន្តតិកម្មនេះមានសន្តតិជនច្រើន ឬសហសន្តតិជន ហើយមានសន្តតិជនម្នាក់បានប្រព្រឹត្តអំពើទុច្ចរិតដូចខាងលើ ឬអំពើនានាដែលចាត់ទុកថាមានមូលហេតុនៃការយល់ព្រមទាំងស្រុងនោះ ច្បាប់មានវិធានការផ្សេងទៀតក្នុងការដោះស្រាយ។ ដោយក្នុងករណីនេះគេត្រូវធ្វើការជម្រះបញ្ជីជាមុនសិន ដើម្បីដឹងថាមតិករបស់មតកជននោះអាចសងកាតព្វកិច្ចគ្រប់

[31] មាត្រា ១២៥៨ នៃសេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី

[32] មាត្រា ១២៥៩ កថាខណ្ឌទី ១ នៃសេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី

ចំនួន ឬទេ បន្ទាប់ពីបានធ្វើការជម្រះបញ្ជីហើយ ប្រសិនបើនៅតែមិនគ្រប់ទៀតនោះគេត្រូវយកទ្រព្យរបស់សន្តតិជនដែលត្រូវចាត់ថាទទួលខុសត្រូវទាំងស្រុងលើសន្តតិកម្មនោះយកមកសង ប៉ុន្តែត្រូវសងត្រឹមតែទំហំនៃទ្រព្យសម្បត្តិដែលទទួលបានប៉ុណ្ណោះ[33]។ បានន័យថាប្រសិនបើមតិកមាន ៤ ចំណែក បំណុលក៏មាន៤ ចំណែកដែរ ហើយសន្តតិជនមាន ៣ នាក់ ដោយម្នាក់ទទួលយកដោយកម្រិតត្រឹមតែមួយចំណែកប៉ុណ្ណោះ និងនៅសល់មួយចំណែកទៀត ប៉ុន្តែដោយសារតែមានសន្តតិជនម្នាក់បានប្រព្រឹត្តការទទួលសន្តតិកម្មដោយទុច្ចរិត ហើយត្រូវបានចាត់ទុកថាទទួលយកសន្តតិកម្មទាំងស្រុង សន្តតិជនទុច្ចរិតនោះត្រូវទទួលនូវចំណែកមតិកទាំងស្រុង ពោលគឺទទួលយកនូវចំណែកមតិកដែលនៅសល់ពីសន្តតិជនពីរនាក់ដែល ដូចនេះសន្តតិជនទាំងពីរអ្នកនោះត្រូវទទួលបានម្នាក់មួយចំណែក ហើយ សន្តតិជនដែលចាត់ទុកថាទទួលខុសត្រូវទាំងស្រុងនោះ ត្រូវទទួលពីរចំណែកដែលនៅសល់ពីការបែងចែកនោះ។

[33] មាត្រា ១២៥៩ កថាខណ្ឌទី ២ នៃសេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី

# ជំពូកទី ៣

# ការបោះបង់សន្តតិកម្ម

## ៣.១. គោលគំនិតទូទៅ

នៅក្នុងបរិបទសង្គមនៃព្រះរាជាណាចក្រកម្ពុជា យើងអាចសង្កេតឃើញថាប្រជាពលរដ្ឋខ្មែរ នៅពេលដែលនិយាយអំពីសន្តតិកម្ម ភាគច្រើនពួកគាត់បានធ្វើការផ្តោតសំខាន់ទៅលើការទទួលយល់ព្រមចំពោះសន្តតិកម្ម ក៏ប៉ុន្តែការយល់ឃើញនេះមានសភាពចង្អៀតជាខ្លាំងណាស់ ដោយសារការបោះបង់សន្តតិកម្មក៏មានសារៈសំខាន់ដូចទៅនឹងការយល់ព្រមចំពោះសន្តតិកម្មផងដែរ។ ដូចដែលបានលើកឡើងខាងលើនេះ សន្តតិកម្ម មាននិយមន័យថាជាការផ្ទេរនូវសិទ្ធិ និងករណីយកិច្ចរបស់មតកជនទៅឲ្យសន្តតិជន។ បើសិនជាយើងធ្វើការវិភាគទៅលើខ្លឹមសារនេះយើងអាចយល់ថា សន្តតិកម្មអាចផ្តល់មកឲ្យសន្តតិជននូវសិទ្ធិកាន់កាប់ទៅលើមតិករបស់មតកជន ដែលមានឧទាហរណ៍ដូចជា ផ្ទះ យានយន្ត ដីធ្លី...។ល។ ក៏ប៉ុន្តែអ្វីដែលពួកគាត់មិនសូវនិយាយ ហើយក៏តែងតែភ្លេចនោះគឺ សន្តតិជនក៏ត្រូវការស្នងនូវករណីយកិច្ចរបស់មតកជនផងដែរ។ ហើយករណីយកិច្ចមួយចំនួនមានភាពអវិជ្ជមានជាខ្លាំង ដែលមិនអាចឲ្យសន្តតិជនរ៉ាប់រងបាន ។

ឧទាហរណ៍៖ ដូចជាបំណុល កាតព្វកិច្ចបង់រំលោះផ្ទះ...។ល។ នៅក្នុងករណីនេះ សន្តតិជនត្រូវចាំបាច់មានការយល់ដឹង និងស្វះស្វែងរកជំនួយផ្នែកច្បាប់អំពីការបោះបង់សន្តតិកម្ម ដែលនីតិវិធីអាចជួយរំដោះសន្តតិជនពីកាតព្វកិច្ចមួយចំនួនដែលពួកគេមិនចង់បាន ឬ ក៏មានភាពមិនពេញចិត្ត។

ដោយការបោះបង់សន្តតិកម្មមានភាពស្មុគស្មាញ ទើបផ្នែកនៃសារណានេះបានបំបែកជាគោលចំនុចធំៗ ដូចជា អំឡុងពេលសម្រាប់បោះបង់សន្តតិកម្ម ប្រភេទនៃការបោះបង់សន្តតិកម្ម នីតិវិធីនៃការបោះបង់សន្តតិកម្ម អានុភាពនៃការបោះបង់សន្តតិកម្ម និងការលុបចោលនៃការបោះបង់សន្តតិកម្ម។

## ៣.២. ប្រភេទនៃការបោះបង់សន្តតិកម្ម

ការបោះបង់សន្តតិកម្ម ត្រូវបានបែងចែកជាពីរប្រភេទធំៗដែលមាននៅក្នុងផ្នែកនេះ យើងនឹងធ្វើការរៀបរាប់អំពី ការបោះបង់លក្ខណៈទូទៅ និង ផ្នែកបន្ទាប់យើងនឹងធ្វើការរៀបរាប់អំពីការបោះបង់អច្ច័យទាន។

### ៣.២.១. ការបោះបង់លក្ខណៈទូទៅ

នៅពេលដែលយើងនិយាយអំពីការបោះបង់លក្ខណៈទូទៅ យើងសំដៅទៅលើការបោះបង់ចោលសន្តតិកម្មអំពីសំណាក់សន្តតិជន ទៅលើសន្តតិកម្មដែលបានផ្តល់មកឲ្យខ្លួនតាមរយៈ ការទទួលមរណភាពរបស់មតកជន។ លើសពីនេះទៅទៀត ការបោះបង់លក្ខណៈទូទៅសំដៅទៅលើការបោះបង់លក្ខណៈសាមញ្ញ ពោលគឺការបោះបង់សន្តតិកម្មនេះ កើតឡើងរវាងកូន ឪពុកម្តាយ បង ប្អូន និងសាច់ញាតិរបស់មតកជនជាដើម ដោយគិតតាមលំដាប់នៃសន្តតិជនពីទី ១ រហូតទៅដល់លំដាប់ដទៃៗទៀត ក៏ដូចជាសន្តតិជនជានិច្ចដែលជាសហព័ទ្ធផងដែរ។ នៅពេលដែលមតកជនបានទទួលមរណភាព សន្តតិជនដែលពាក់ព័ន្ធមានសិទ្ធិដាក់ពាក្យសុំទៅតុលាការ ក្នុងកម្មវត្ថុបោះបង់ចោលសន្តតិកម្ម តាមរយៈហេតុផលសមស្របណាមួយ។ បន្ថែមពីនេះទៀត ការបោះបង់សន្តតិកម្មទូទៅ ក៏អនុវត្តការគណនាអំឡុងពេលនៃការបោះបង់ដូចដែលបានរៀបរៀបរាប់នៅក្នុងផ្នែក អំឡុងពេលនៃការបោះបង់ទូទៅ ផងដែរ។

លើសពីនេះទៅទៀត អ្នកអានអាចមានចម្ងល់ដូចជា "តើហេតុអ្វីបានជាការបោះបង់សន្តតិកម្មមិនមានការរៀបរាប់អំពីការបោះបង់មានកម្រិត?" ចម្លើយយ៉ាងខ្លីនោះគឺ ដោយសារ នីតិវិធីការយល់ព្រមមានកម្រិត គឺមានន័យដូចទៅនឹងការបោះបង់ដោយកម្រិតហើយ ពោលគឺទទួលខ្លះ និងបោះបង់ខ្លះ។ ការយល់ព្រមមានកម្រិត បានបកស្រាយពីការទទួលនូវចំណែកមតិកពីសន្តតិជនត្រឹមតែកម្រិតណាមួយប៉ុណ្ណោះ ពោលគឺមួយចំណែកនៃមតិករបស់មតកជន ដែលចំណែកផ្សេងៗទៀតដែលបុគ្គលនោះមិនបានទទួលបានប្រែក្លាយដោយស្វ័យប្រវត្តិទៅជាផ្នែកដែលខ្លួនបានបោះបង់ចោល ដែលអ្នកអាចហៅសកម្មភាពនេះបានថាជា ការបោះបង់មានកម្រិត។ ដោយសារការបោះបង់មានកម្រិត និងការយល់ព្រមមានកម្រិត គឺជាសកម្មភាពតែមួយទើបច្បាប់មិនចាំបាច់ធ្វើការបញ្ញត្តិទៅលើនិយមន័យ នៃសកម្មភាពដូចគ្នានេះឡើយ។

### ៣.២.២. ការបោះបង់អច្ច័យទាន

ក្រៅពីការបោះបង់សន្តតិកម្មទូទៅ យើងមានប្រភេទនៃការបោះបង់សន្តតិកម្មមួយផ្សេងទៀត គឺការបោះបង់អច្ច័យទាន។ មុននឹងឈានទៅដល់ការរៀបរាប់ដែលមានភាពស៊ីជម្រៅ យើងគួរគប្បីយល់ដឹងឲ្យច្បាស់អំពីនិយមន័យអច្ច័យទានជាមុនសិន។

អច្ច័យទាន គឺជាប្រទានកម្មនូវទ្រព្យសម្បត្តិដែលម្ចាស់បណ្តាំធ្វើទៅឲ្យមនុស្សម្នាក់ ឬច្រើននាក់ ដោយមតកសាសន៍ ។ តាមមាត្រា ១១៩៩ នៃក្រមរដ្ឋប្បវេណី បានបង្ហាញឡើងថា អច្ច័យទានមានពីរប្រភេទ គឺអច្ច័យទានសកល និង អច្ច័យទានមានកំណត់។ អច្ច័យទានសកល គឺជា

ប្រទានកម្មដែលម្ចាស់បណ្តាំធ្វើទៅឲ្យមនុស្សម្នាក់ ឬច្រើននាក់ជាក់លាក់នូវទ្រព្យសម្បត្តិទាំងអស់ ឬ មួយផ្នែកដែលកំណត់តាមភាគនៃទ្រព្យ (ទាំងអស់, មួយភាគពីរ, ឬមួយភាគបី ជាដើម)។ ឧទាហរណ៍៖ នៅក្នុងមតកសាសន៍របស់ម្ចាស់បណ្តាំ បានកំណត់ឲ្យទ្រព្យមួយភាគបី នៃមតិកទាំងអស់ដើម្បីធ្វើជាអច្ច័យទានទៅដល់អច្ច័យលាភី។ ចំណែក អច្ច័យទានមានកំណត់ គឺជាប្រទានកម្មដែលកំណត់ទ្រព្យសម្បត្តិជាក់លាក់ទៅឲ្យមនុស្សម្នាក់ ឬ ច្រើននាក់ដោយមតកសាសន៍។ ឧទាហរណ៍៖ នៅក្នុងមតកសាសន៍របស់ម្ចាស់ បណ្តាំ បានកំណត់ឲ្យផ្ទះ(A) ដើម្បីធ្វើជាអច្ច័យទានទៅដល់អច្ច័យលាភី។

បន្ទាប់ពីបានពន្យល់នូវនិយមន័យរបស់អច្ច័យទាន យើងនឹងបន្តចូលទៅដល់ការរៀបរាប់ទៅលើកាលៈទេសៈមួយចំនួនដែលអាចកើតឡើងនៅក្នុងការបោះបង់អច្ច័យទាននេះ។ យើងអាចបែងចែកវាទៅជាបីកាលៈទេសៈដូចខាងក្រោម ដែលកាលៈទេសៈទី១ និងទី២ រៀបរាប់អំពីអច្ច័យលាភីដែលជាសន្តតិជន និងកាលៈទេសៈទី៣ រៀបរាប់អំពីអច្ច័យទានដែលមិនមានជាសន្តតិជន។

កាលៈទេសៈទី ១ គឺជាការបោះបង់អច្ច័យទានក្នុងករណីដែលអច្ច័យលាភីជាសន្តតិជន។ បើអច្ច័យលាភីជាសន្តតិជន បានបោះបង់សន្តតិកម្ម បុគ្គលនោះត្រូវបានចាត់ទុកថាបានបោះបង់អច្ច័យទានផងដែរ។[34] មានន័យថាប្រសិនជាអច្ច័យលាភីបានធ្វើការបោះបង់សន្តតិកម្មរបស់ខ្លួនដែលមានអច្ច័យទានបញ្ចូលនៅក្នុងសន្តតិកម្មនោះ គេចាត់ទុកថាអច្ច័យលាភីបានបោះបង់ទាំងអច្ច័យទានរបស់ខ្លួនហើយ។ តែបើគាត់បានទទួលស្គាល់ ឬយល់ព្រមសន្តតិកម្ម និងអច្ច័យទានផងនោះ អច្ច័យលាភីដែលជាសន្តតិជននេះ ក៏នៅតែមានសិទ្ធិបោះបង់អច្ច័យទានដែលខ្លួនបានទទួលស្គាល់ហើយបានដែរ។

ឧទាហរណ៍៖ នៅក្នុងមតិករបស់ម្ចាស់បណ្តាំ មានដូចជា ផ្ទះ ប្រាក់ ឡាន និងបំណុល។ នៅក្នុងមតកសាសន៍ ម្ចាស់បណ្តាំបានធ្វើអច្ច័យទាន ជាកំណត់នៅផ្ទះឲ្យទៅកូនរបស់គាត់ឈ្មោះ ទី ដែលជាសន្តតិជនលំដាប់ទី១។ ដូច្នេះកូនរបស់គាត់ដែលជាសន្តតិជន ទន្ទឹមគ្នានោះដែរបានក្លាយខ្លួនជាអច្ច័យលាភី ហើយទ្រព្យដែលនៅសល់ទាំងប៉ុន្មាននឹងត្រូវបានចែកទៅឲ្យសន្តតិជនបីនាក់ឈ្មោះ គង់ រស្មី និងទី (ដែលជាអច្ច័យលាភី)។ ក្នុងករណីនេះ អច្ច័យលាភីដែលមាននាមជាសន្តតិជនឈ្មោះ ទី មិនអាចបោះបង់សន្តតិកម្ម (ដែលមានសរុបទាំងអស់ដូចជា ផ្ទះ ប្រាក់ ឡាន និងបំណុលតាមសមាមាត្ររវាងសន្តតិជនទាំងបីនាក់) ដោយទទួលយកតែ អច្ច័យទាន (ផ្ទះ) ឡើយ។ មូលហេតុពីព្រោះថា ការធ្វើបែបនេះ នឹងបង្កផលប៉ះពាល់ទៅដល់ ផលប្រយោជន៍សន្តតិជនពីរ

[34] មាត្រា ១២០៥ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា

ផ្សេងទៀត ដោយពួកគាត់ត្រូវទទួលរ៉ាប់រងបំណុល។ ផ្ទុយទៅវិញ យោងទៅតាមមាត្រា ១២០៥ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ទោះបីជាឈ្មោះ ទី ដែលជាអច្ច័យលាភី ជាសន្តតិជននោះបានទទួលស្គាល់សន្តតិកម្ម (ផ្ទះ ប្រាក់ ឡាន និងបំណុល) ហើយក៏ដោយក៏អច្ច័យលាភីរូបនេះ អាចបោះបង់អច្ច័យទានមានកំណត់ (ផ្ទះ) បានដែរ។

កាលៈទេសៈទីពីរ នឹងធ្វើការផ្តោតទៅលើករណីដែល ការបោះបង់អច្ច័យទាន ដោយសន្តតិជនរបស់អច្ច័យលាភី។ កាលៈទេសៈនេះ សំដៅទៅលើក្នុងពេលដែលអច្ច័យលាភី បានទទួលមរណភាពដោយមិនបានធ្វើការទទួលស្គាល់ ឬបោះបង់អច្ច័យទាននៅឡើយ។ នៅក្នុងករណីនេះ សិទ្ធិ និងកាតព្វកិច្ចរបស់អច្ច័យលាភីនោះ ត្រូវបានធ្លាក់មកក្នុងដៃសន្តតិជនរបស់អច្ច័យលាភីនោះ។ ពោលវាគឺស្រដៀងទៅនឹងសន្តតិកម្មជំនួសដែរ ដោយហេតុថាសន្តតិជនរបស់អច្ច័យលាភីគាត់មានសិទ្ធិក្នុងការទទួលបាននៅមតិករបស់មតកជនគាត់ដែលរួមទាំងសិទ្ធិទទួលស្គាល់ ឬ បោះបង់អច្ច័យទាននៅក្នុងនោះផងដែរ។

ឧទាហរណ៍សន្តតិជនលំដាប់ទី១ របស់អច្ច័យលាភី មានន័យថាជាកូនរបស់អច្ច័យលាភី។ នៅក្នុងករណីនេះ សន្តតិជនរបស់អច្ច័យលាភី អាចសម្រេចចិត្តទទួលស្គាល់ ឬបោះបង់ទៅតាមទំហំនៃសិទ្ធិលើសន្តតិកម្មរបស់ខ្លួន យោងតាមមាត្រា ១២០៣ នៃក្រមរដ្ឋប្បវេណី[35]។

កាលៈទេសៈទី ៣ ពាក់ព័ន្ធទៅនឹងការបោះបង់អច្ច័យទានដោយបុគ្គលមិនមែនជាសន្តតិជន។នៅក្រោយពេលដែលម្ចាស់បណ្តាំ បានទទួលមរណភាព អច្ច័យលាភីអាចបោះបង់អច្ច័យទាននៅពេលណាក៏បាន ដោយយោងតាមមាត្រា ១២០១ នៃក្រមរដ្ឋប្បវេណី។ ដោយចរិតលក្ខណៈរបស់អច្ច័យទាន គឺជាការផ្ទេរទ្រព្យសម្បត្តិដោយសកម្មភាពឯកតោភាគីរបស់ម្ចាស់បណ្តាំ ហើយអានុភាពនៃអច្ច័យទាននឹងកើតឡើងដោយស្វ័យប្រវត្តិ ដោយមរណភាពរបស់ម្ចាស់បណ្តាំ ដូច្នេះការកកើតឡើងនូវអច្ច័យទានពុំមានទំនាក់ទំនងទៅនឹង ឆន្ទៈរបស់អច្ច័យលាភីទេ។ ប៉ុន្តែទោះជាយ៉ាងណាក្តី ប្រសិនបើអច្ច័យលាភីមិនមានបំណងក្នុងការទទួលអច្ច័យទានទេនោះ វានឹងបង្កើតភាពមិនសមស្របជាខ្លាំង ទៅកាន់បុគ្គលដែលជាអច្ច័យលាភី ដោយជននោះមិនបានពាក់ពន្ធ នៅក្នុងការសម្រេចចិត្តណាមួយ ដែលឈានទៅដល់បុគ្គលក្លាយខ្លួនជាអច្ច័យលាភីឡើយ ដែលជាហេតុនាំឲ្យមានការបោះបង់អច្ច័យទាននេះឯង។

ក្រៅពីកាលៈទេសៈទាំងនេះ យើងមានចំនុចសំខាន់ៗមួយដែលយើងគួរកត់សម្គាល់ ដែលនោះសំដៅទៅលើ ការមិនមានការកំណត់ទៅលើពេលវេលា នៃការបោះបង់នូវអច្ច័យទានឡើយ

[35] មាត្រា ១២០៣ នៃក្រមរដ្ឋប្បវេណី

ដោយសារតែមុនពេលម្ចាស់បណ្តាំទទួលមរណភាព អច្ច័យលាភីមិនទាន់បានទទួលសិទ្ធិណាមួយនៅឡើយទេ ហេតុនេះហើយ ការបោះបង់មុនពេលមរណភាពរបស់ម្ចាស់បណ្តាំមិនមានន័យអ្វីទេ។ លើសពីនេះទៅទៀត ក្នុងករណីដែលសន្តតិជនជាអច្ច័យលាភី ប្រសិនបើសន្តតិជននោះបានបោះបង់សន្តតិកម្មមានន័យថាបុគ្គលនោះបានបោះបង់ អច្ច័យទាន រួមជាមួយនិងសន្តតិកម្មជាមួយគ្នាផងដែរ។ ហេតុដូច្នេះហើយបានជា នៅក្នុងផ្នែកអំឡុងពេលនៃការបោះបង់សន្តតិកម្ម ពួកយើងមិនបានរៀបរាប់អំពីពេលវេលានៃការបោះបង់អច្ច័យទានឡើយ ដោយសារភាពមិនចាំបាច់ដូចបានរៀបរាប់នេះ។[36]

## ៣.៣. នីតិវិធី និងអានុភាពនៃការបោះបង់សន្តតិកម្ម

### ៣.៣.១. នីតិវិធីនៃការបោះបង់សន្តតិកម្ម

នីតិវិធីនៃការបោះបង់សន្តតិកម្ម គឺជាការអនុវត្តទៅតាមផ្លូវច្បាប់ ដើម្បីឲ្យការបោះបង់របស់សន្តតិជន ឬ អច្ច័យលាភីនោះបានសម្រេច និងការពារផលប្រយោជន៍របស់បុគ្គលទាំងនោះ។ យោងតាមមាត្រា ១២៦០ នៃក្រមរដ្ឋប្បវេណីបានលើកឡើងថា "បុគ្គលដែលមានបំណងបោះបង់សន្តតិកម្ម ត្រូវដាក់ពាក្យសុំការបោះបង់សន្តតិកម្មនោះ ទៅតុលាការ។"[37] ដោយយោងតាមមាត្រា ១១៤៦ នៃក្រមរដ្ឋប្បវេណី សន្តតិកម្ម ត្រូវចាប់ផ្តើមលើលំនៅឋានរបស់មតកជន នាពេលទទួលមរណភាព ដែលមានការបង្ហាញថា ក្នុងករណីដែលចាំបាច់មានអន្តរាគមន៍របស់តុលាការចំពោះសន្តតិកម្ម ដូចជាការបោះបង់នូវសន្តតិកម្ម ជាដើម។ ដូច្នេះ តុលាការដែលមានសមត្ថកិច្ចនៅលំនៅឋានរបស់មតកជន នៅពេលដែលមតកជននោះបានទទួលមរណភាព ជាតុលាការដែលមានសមត្ថកិច្ច ក្នុងការទទួលពាក្យសុំបោះបង់សន្តតិកម្ម។

នៅពេលដែលសន្តតិជនដែលមានបំណងបោះបង់ចោលសន្តតិកម្ម គេត្រូវធ្វើការដាក់ពាក្យសុំបោះបង់ទៅតុលាការ ដែលមានភាពសមស្រប និងត្រឹមត្រូវតាមការកំណត់របស់តុលាការ ក៏ដូចជាបានដាក់ទៅតុលាការដែលមានសមត្ថកិច្ចក្នុងការសម្រេចក្នុងអំឡុងពេល ៣ខែ។គោលដៅនៅក្នុងចំនុចនេះ គឺដើម្បីឲ្យសន្តតិជន មានពេលវេលាសម្រាប់ធ្វើការស្រាវជ្រាវ រវាងសិទ្ធិ និងកាតព្វកិច្ចមួយចំនួនដូចជា បំណុល ជាដើម ហើយធ្វើការពិចារណាថាខ្លួនអាចទទួលយកបានត្រឹមកម្រិតណា ឬក៏ត្រូវការបោះបង់ទាំងស្រុង។ លើសពីនេះទៅទៀត ធ្វើតាមនីតិវិធីតុលាការអាចផ្តល់ប្រយោជន៍ និងសម្រួល ក្នុងការទូទាត់ទ្រព្យសម្បត្តិរបស់មតកជនដែលបានបន្សល់ និងចាត់ចែងក្នុងការទូទាត់

[36] មាត្រា ១១៩៩ នៃសេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី

[37] មាត្រា ១២៦០ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា

ទៅកាន់ម្ចាស់បំណុល។ នៅក្នុងករណីដែលបានដាក់ពាក្យសុំបោះបង់សន្តតិកម្ម តុលាការពុំចាំបាច់ធ្វើការទាញហេតុផលដោយផ្ទាល់មាត់ឡើយ ដោយករណីនេះ ត្រូវបានគេចាត់ទុកថាជាប្រភេទរឿងក្ដីរដ្ឋប្បវេណីមិនមែនជាបណ្ដឹងដែលត្រូវសម្រេចដោយដីកាសម្រេច។ ដោយហេតុថាវាជារឿងក្ដីរដ្ឋប្បវេណីមិនមែនជាបណ្ដឹង វាមាននីតិវិធីនៃការដាក់ពាក្យសុំដូចទៅនឹងការយល់ព្រមដោយកម្រិតដែរ ។

### ៣.៣.២ អានុភាពនៃការបោះបង់សន្តតិកម្ម

អានុភាពនៃការបោះបង់សន្តតិកម្ម ចាប់ផ្តើមមានអានុភាព នៅពេលដែលតុលាការបានចេញដីកាសម្រេច អនុញ្ញាតឲ្យបុគ្គលដែលជាសន្តតិជន បោះបង់ចោលសន្តតិកម្មរបស់ខ្លួន។ ដោយឡែក អានុភាព នៃការបោះបង់សន្តតិកម្ម អាចដកស្រង់បាននៅមាត្រា ១២៦១ នៃក្រមរដ្ឋប្បវេណី៖

ប៉ុន្តែជាដំបូងយើងត្រូវតែពិនិត្យលើច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីបានធ្វើវិសោធនកម្មលើក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ត្រង់មាត្រា ១២៦១ នេះ ប្តូរពីចែងថា៖

-"បុគ្គលដែលបានបោះបង់សន្តតិកម្ម ត្រូវចាត់ទុកថា បុគ្គលនោះមិនមែនជាសន្តតិជនតាំងពីដំបូងមក។" [38]

ដោយបន្ថែមនៅឃ្លាថា "ចំពោះសន្តតិកម្មនោះ" នៅក្រោយឃ្លា "បុគ្គលនោះមិនមែនជាសន្តតិជន"[39] ដូចនេះឃ្លាថ្មីនៃមាត្រានេះគឺ៖

-"បុគ្គលដែលបានបោះបង់សន្តតិកម្ម ត្រូវចាត់ទុកថា បុគ្គលនោះមិនមែនជាសន្តតិជនចំពោះសន្តតិកម្មនោះតាំងពីដំបូងមក។"

ក្នុងចំនុចនេះ គឺបានន័យថាការបោះបង់សន្តតិកម្មគឺមានភាពប្រតិសកម្មដោយចាត់សន្តតិជនដែលបានបោះបង់សន្តតិកម្មថាមិនមែនជាសន្តតិជនតាំងពីដំបូង ដែលនេះបង្ហាញឲ្យឃើញថាតាំងពីដំបូងមកគឺសន្តតិជនមិនអាចទទួលបានផលអ្វីពីមតិកនោះទេ។ ប៉ុន្តែពេលខ្លះមានភាពមិនច្បាស់លាស់អំពីពេលវេលាដែលគេចាត់ទុកថា តាំងពីដំបូង នោះថាវាគិតចាប់ពីពេលណា។ ក្នុងចំនុចនេះយើងអាចបកស្រាយបានថាសន្តតិកម្មចាប់ផ្តើមពេលដែលមតកជនបានស្លាប់ ដូចនេះសិទ្ធិ និងកាតព្វកិច្ចរបស់សន្តតិជនគឺកើតឡើងនៅពេលដែលសន្តតិកម្មចាប់ផ្តើមនេះឯងដែលជាហេតុឲ្យយើងអាចបកស្រាយបានថាពេលវេលា តាំងពីដំបូង នេះគឺគិតចាប់ពីពេលដែលសន្តតិកម្មចាប់ផ្តើម។

[38] មាត្រា ១២៦១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា

[39] មាត្រា ៨១ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី

ទោះជាយ៉ាងណាក្តី កាលៈទេសៈទាំងនេះអាចនឹងមានការប្រែប្រួលនៅពេលដែលយើងរាប់បញ្ចូលផលប្រយោជន៍ពិសេស។ ផលប្រយោជន៍ពិសេស សំដៅទៅលើប្រទានកម្មនៅក្នុងឱកាសអាពាហ៍ពិពាហ៍ ឬហេតុការណ៍ផ្សេងទៀត ឬដើម្បីមូលធននៃជីវភាពរស់នៅ និងអច្ច័យទានដែលបានប្រគល់ទៅឲ្យសន្តតិជន[40] ។ ប្រសិនបើមានផលប្រយោជន៍ពិសេស (តម្លៃនៃប្រទានកម្ម ឬអច្ច័យទាន) គេត្រូវរាប់បញ្ចូលវាទៅក្នុងមតិកនៅពេលសន្តតិកម្មបានចាប់ផ្តើម ។

មតិក = ទ្រព្យដែលមាននៅពេលចាប់ផ្តើមសន្តតិកម្ម + ផលប្រយោជន៍ពិសេស ។

ក៏ប៉ុន្តែគេអាចចោទជាសំនួរថា "តើតម្លៃនៃមតិក អាចមានការប៉ះពាល់យ៉ាងដូចម្តេចខ្លះនៅពេល តម្លៃនៃប្រទានកម្មបានផ្លាស់ប្តូរ?" ចម្លើយនោះគឺ តម្លៃនៃមតិកមិនមានការប្រែប្រួលឡើយ ដោយតម្លៃនៃប្រទានកម្មដែលនឹងធ្វើការរាប់បញ្ចូលជាតម្លៃមតិក ត្រូវធ្វើការគណនាទៅតាមស្ថានភាពនៃវត្ថុដែលជាកម្មវត្ថុនៃប្រទានកម្មនោះ ដោយមិនគិតអំពីការផ្លាស់ប្តូរនៃតម្លៃឡើយ។

ឧទាហរណ៍ថា លោក តុលា ដែលជាបដិគ្គាហក បានទទួលប្រទានកម្មនៅផ្ទះតម្លៃ ១០០,០០០$ (មួយសែនដុល្លារ) នៅពេលដែលមតកជននៅមានជីវិត។ លោក តុលា បានធ្វើការតុបតែង និងធ្វើការសាងសង់បន្ថែមមួយជាន់ថែមទៀត ដែលនាំឲ្យតម្លៃផ្ទះនោះ នៅពេលគាត់សម្រេចចិត្តលក់ បានតម្លៃ រហូតទៅដល់ ២០០,០០០$ (ពីរសែនដុល្លារ)។ ទោះបីផ្ទះដែលជាកម្មវត្ថុនៃប្រទានកម្មនោះ បានកើនឡើងតម្លៃរហូតទៅដល់ទ្វេដងក្តី នៅពេលដែលគេត្រូវការប្រទានកម្មនេះយកទៅបូកជាមួយមតិកដើម្បីធ្វើសន្តតិកម្ម គេមិនបូកតម្លៃលុយចំនួនពីរសែនដុល្លារដែលជាលទ្ធផលនៃការប្រើប្រាស់កម្មវត្ថុនៃប្រទានកម្មបញ្ចូលក្នុងតម្លៃនៃមតិកឡើយ ដោយសារស្ថានភាពដើមនៃផ្ទះដែលជាប្រទានកម្ម មានតម្លៃត្រឹមតែមួយសែនដុល្លារតែប៉ុណ្ណោះ។ លើសពីនេះទៅទៀត ការប្រាក់ និង ផលចំណេញដែលកើតចេញពីប្រទានកម្ម ពុំត្រូវគណនាចូលក្នុងតម្លៃនៃមតិកឡើយ។ បើយើងប្រើប្រាស់ឧទាហរណ៍ ដដែល យើងអាចនិយាយថា អំឡុងពេលដែល តុលា បានបញ្ចប់ការកែច្នៃទៅលើ ផ្ទះ និងពេលដែលគាត់ធ្វើការលក់ផ្ទះមានរយៈពេលពីរឆ្នាំ ហើយនៅក្នុងអំឡុងពេលនោះ លោក តុលា បានជួលផ្ទះនេះទៅឲ្យអតិថិជនរបស់គាត់ ដែលរកបានចំណូលពីការជួលសរុបចំនួន មួយម៉ឺនដុល្លារ។ តាមគោលការណ៍ខាងលើ ផលចំណេញតម្លៃ មួយម៉ឺនដុល្លារនេះ មិនត្រូវរាប់បញ្ចូលក្នុងតម្លៃសរុបនៃមតិកឡើយ។

លើសពីនេះទៅទៀត យើងគួរពិចារណាទៅលើទំនាក់ទំនងរវាងអានុភាពនៃការបោះបង់សន្តតិកម្ម និងសិទ្ធិនៃផលប្រយោជន៍ពិសេស។ ជាទូទៅផលប្រយោជន៍ពិសេសត្រូវបានបែងចែក

[40] មាត្រា ១១៦៣ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា

ជាពីរធំៗ គឺអច្ច័យទាន និងប្រទានកម្ម ដោយក្នុងលក្ខខណ្ឌនេះយើងអាចពន្យល់បានថាពេលដែលមតកជនបានស្លាប់ទៅ គាត់មានបំណងធ្វើអច្ច័យទានទៅឲ្យជនដ៏ទៃរួមទាំងសន្តតិជន ហើយការធ្វើអច្ច័យទានគឺត្រូវធ្វើឡើងតាមមតកសាសន៍ផងដែរ ដូចនេះការដែលបោះបង់សន្តតិកម្មគឺបានន័យថាបោះបង់នូវអច្ច័យទានដូចគ្នា ព្រោះថាអច្ច័យទានគឺស្ថិតក្នុងមតកសាសន៍ផងដែរ ម្យ៉ាងទៀតដើម្បីការពារសមធម៌ផងដែរកុំឲ្យមានការទទួលតែប្រយោជន៍ហើយបោះបង់កាតព្វកិច្ច។ ចំណែកឯប្រទានកម្មវិញ វាជាការប្រទានពីមតកជននៅពេលដែលនៅរស់ទៅឲ្យបដិគ្គាហកទៅតាមកិច្ចសន្យាជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់ក្តី ដូចនេះវាជាការប្រគល់ដោយបង្ហាញឆន្ទៈនៃភាគីទាំងសងខាង ដែលជាហេតុនាំឲ្យការបោះបង់នៃសន្តតិកម្មគឺមិនអាចមានផលប៉ះពាល់ដល់ប្រទានកម្មនោះទេ លុះត្រាតែមានករណីស្របទៅតាមជំពូកទី ៣ ដែលចែងពីប្រទានកម្ម ដែលអាចឲ្យសិទ្ធិក្នុងការលុបចោលនូវកិច្ចសន្យាប្រទានកម្មនោះវិញ។

ឧទាហរណ៍: ទ្រព្យនៅពេលចាប់ផ្តើមសន្តតិកម្មមានតម្លៃ ១០០០ដុល្លារ ដែលមានសន្តតិជន ៣នាក់ ដែលត្រូវជាកូនរបស់មតកជន។ បុគ្គល ក បានទទួលបានផលប្រយោជន៍ពិសេសចំនួន ៨០០ដុល្លារ។ ដូច្នេះ ក បានសម្រេចចិត្តបោះបង់ចោលសន្តតិកម្ម ក្នុងគោលបំណងរក្សាទុក និងគេចវេសពីការបង្វិលផលប្រយោជន៍ពិសេសរបស់ខ្លួន ឲ្យក្លាយជាមតិកសរុប។ ក៏ប៉ុន្តែ និយមន័យផលប្រយោជន៍ពិសេស មិនបានកំណត់ថាកម្មវត្ថុនៃផលប្រយោជន៍ពិសេស ត្រូវតែនៅក្រោមការគ្រប់គ្រងរបស់ សន្តតិជនដើម្បីស្ថិតនៅក្រោមអានុភាពឡើយ។ ហេតុដូច្នេះ ការប្រកាសខ្លួនមិនមែនជាសន្តតិជនតាំងពីដំបូង តាមរយៈការបោះបង់សន្តតិកម្ម មិនអាចការពារផលប្រយោជន៍ពិសេសពីការរាប់ចូលជាមតិកសរុបឡើយ។ ផ្ទុយទៅវិញ សកម្មភាពនេះបង្កឲ្យលោក ក បាត់បង់ទាំងភាគបម្រុងរបស់គាត់ទៅទៀត។

# ជំពូកទី ៤

# អំឡុងពេល និងការលុបចោលនៃការយល់ព្រម ឬបោះបង់សន្តតិកម្ម

## ផ្នែកទី ១៖ អំឡុងពេលនៃការយល់ព្រម ឬបោះបង់សន្តតិកម្ម

### ១.១ អំឡុងពេលធម្មតា

ការយល់ព្រមទទួល ឬ បោះបង់នូវសន្តតិកម្ម ច្បាប់បានទុកសិទ្ធិឲ្យសន្តតិជនសម្រេចចិត្តក្នុងអំឡុងពេល ៣ខែ ដោយគិតចាប់ពីពេលដែលបានដឹងថាសន្តតិកម្មចំពោះខ្លួនបានចាប់ផ្តើម។ ការទទួលដំណឹងមានរូបភាពដូចជា៖ សន្តតិជនបានទទួលនូវសារអេឡិចត្រូនិត លិខិតនានារួមមានសំបុត្រ ទូរលេខ ឬលិខិតនានា ឬ ក៏បានទទួលដំណឹងដោយផ្ទាល់មាត់ តាមរយៈទូរស័ព្ទ ឬ មានអ្នកមកប្រាប់ដោយផ្ទាល់ដែលជាដំណឹងពិតប្រាកដអំពីការចាប់ផ្តើមសន្តតិកម្ម។

ហេតុផលដែលច្បាប់បានទុកអំឡុងពេល ០៣ ខែព្រោះថាវាសមល្មមនឹងអាចឲ្យសន្តតិជនធ្វើការសម្រេចចិត្តបានហើយ និងអាចមានពេលគ្រប់គ្រាន់ក្នុងការស្វែងរក មតិកដែលនៅសល់ផងដែរ។ ហើយច្បាប់កំណត់ថា គិតអំឡុងពេលនេះចាប់ពីពេលដែលសន្តតិជនបានទទួលដំណឹងនោះព្រោះថាប្រសិនបើគាត់ពុំបានដឹងអំពីការចាប់ផ្តើមសន្តតិកម្មទេ ហើយបែរជាជួបប្រទះនូវការចាប់ផ្តើមគិតពីពេលដែលមតកជនបានស្លាប់ទៅដែលជាមូលហេតុបង្កើតសន្តតិកម្មនោះ វានឹងមានភាពអយុត្តិធម៌ចំពោះសន្តតិជន ហើយក៏អាចធ្វើឲ្យប៉ះពាល់ដល់ប្រយោជន៍របស់សន្តតិជនផងដែរ។

ប៉ុន្តែក្នុងករណីខ្លះដែលមតកជនមានទ្រព្យច្រើន ឬ ករណីផ្សេងទៀតដែលធ្វើឲ្យសន្តតិជនត្រូវការពេលវេលាយូរក្នុងការសម្រេចចិត្តយល់ព្រមនោះ ហើយបើក្រោយពេលទទួលដំណឹងហើយនោះសន្តតិជនគាត់គិតថារយៈពេលបីខែនេះ គឺខ្លីពេកដោយខ្លួនពុំអាចសម្រេចចិត្តទាន់ពេលវេលានោះទេព្រោះថាខ្លួនត្រូវការស្វែងរកមតិក ឬបំណុលនានាទៀត ដូចនេះគាត់អាចដាក់ពាក្យសុំទៅតុលាការបានដើម្បីពន្យានូវអំឡុងពេលនេះ[41]។

<u>ឧទាហរណ៍ថា</u> សន្តតិជនកំពុងតែស៊ើបមើលអំពីបំណុលដែលមតកជនបានជំពាក់អ្នកដទៃ ឬ ក៏ស៊ើបពីទ្រព្យដែលមតកជនមាន ថាមានបញ្ហាដូចជាជាប់ពាក្យបណ្តឹងនានាដែលអាចនាំឲ្យខាត

[41] មាត្រា ១២៤៨ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា

ផលប្រយោជន៍ដល់ខ្លួនធ្ងន់ធ្ងរជាដើម ដែលជាហេតុធ្វើឲ្យសន្តតិជនត្រូវការប្រើពេលវេលាយូរដើម្បីដឹងនូវ ពត៌មានទាំងអស់របស់ទ្រព្យដែលស្ថិតក្នុងសន្តតិកម្មនេះ។

ដូចក្នុងករណីខាងលើនេះជាដើម ដែលជាហេតុធ្វើឲ្យច្បាប់បានចែងឲ្យសន្តតិជនអាចមានសិទ្ធិសុំពន្យាពេលនៃការយល់ព្រមសន្តតិកម្មបាន ដោយពេលខ្លះសន្តតិជនត្រូវការស៊ើបអង្កេតពីទ្រព្យដែលជាមតិកផងដែរ។ ចំពោះការស៊ើប ឬ ស្រាវជ្រាវពីមតិកនេះគឺច្បាប់ជាអ្នកផ្តល់សិទ្ធិឲ្យសន្តតិជនតែម្តងដោយមានក្នុងមាត្រា ១២៤៨ នៃក្រមរដ្ឋប្បវេណីដោយក្នុងគោលបំណងដើម្បីឲ្យគេសម្រេចចិត្តឲ្យបានត្រឹមត្រូវមុននឹងទទួលយក ឬបោះបង់សន្តតិកម្មរបស់គេ ពីព្រោះថានៅពេលដែលគេបោះបង់សន្តតិកម្មហើយនោះគេទទួលយកសន្តតិកម្មនោះម្តងទៀតបានទេ។

ពាក់ព័ន្ធនឹងការស្វែងរកមតិកនេះ សន្តតិជនអាចផ្តល់សិទ្ធិតំណាងដោយអាណត្តិទៅឲ្យមេធាវីដើម្បីធ្វើឯកសារឲ្យ ឬក៏សរសេរដោយខ្លួនឯងក៏បានដោយនៅក្នុងឧបសម្ព័ន្ធខាងក្រោយមានគំរូមួយក្នុងចំណោមគំរូជាច្រើនដែលគេអាចសរសេរបាន ពោលចំនុចដែលសំខាន់គឺត្រូវផ្តល់អត្តសញ្ញាណរបស់អ្នកដាក់ពាក្យសុំឲ្យបានច្បាស់លាស់ហើយត្រូវបញ្ជាក់ពីកម្មវត្ថុ និងមានឯកសារយោងឲ្យបានគ្រប់គ្រាន់ដើម្បីបញ្ជាក់ពីការសុំស្វែងរកមតិកនេះទៅតុលាការផងដែរ។

## ១.២. អំឡុងពេលក្នុងករណីពិសេស

### ១.២.១. អំឡុងពេលក្នុងករណីពិសេសដោយមរណភាពរបស់សន្តតិជន

ចំណែកអំឡុងពេលក្នុងករណីពិសេសវិញ គឺធ្វើឡើងនៅពេលដែលសន្តតិកម្មបានចាប់ផ្តើមហើយសន្តតិជនកំពុងតែស្ថិតក្នុងអំឡុងពេលសម្រេចចិត្តក្នុងការយល់ព្រម ឬបោះបង់សន្តតិកម្មប៉ុន្តែសន្តតិជនបែរជាទទួលមរណភាពក្នុងអំឡុងពេលនេះទៅវិញ ដូចនេះគេត្រូវគិតអំឡុងពេលដែលមានក្នុងមាត្រា ១២៤៨ នៃក្រមរដ្ឋប្បវេណី ចាប់ពីពេលដែលសន្តតិជនរបស់សន្តតិជនដែលបានស្លាប់ទៅ បានដឹងពីការចាប់ផ្តើមសន្តតិកម្មរបស់ខ្លួន។ ច្បាប់ចែងបែបនេះព្រោះថាសន្តតិជនដែលបានទទួលមរណភាព គឺពុំទាន់បានសម្រេចចិត្តអ្វីឡើយហើយនៅពេលដែលគាត់ស្លាប់ទៅមតិករបស់គាត់រួមទាំងសន្តតិកម្មនឹងត្រូវធ្លាក់លើសន្តតិជនរបស់គាត់ ដូចនេះប្រសិនបើគេនៅតែគិតអំឡុងពេល ០៣ ខែ ចាប់ពីពេលដែលសន្តតិជនដែលបានទទួលមរណភាពនោះបានដឹង វាហាក់បីដូចជាមានភាពអយុត្តិធម៌ចំពោះសន្តតិជនរបស់បុគ្គលដែលស្លាប់ពេក ព្រោះថាគាត់ក៏ត្រូវ

ការពេលវេលាដើម្បីសម្រេចចិត្តនឹងធ្វើការស្វែងរកមតិកដែរ។ ឧទាហរណ៍ថា បុគ្គល ក ជាមតកជន នៃបុគ្គល ខ ហើយនៅពេលដែលបុគ្គល ខ នោះបានដឹងពីការចាប់ផ្តើមសន្តតិកម្មរបស់ខ្លួនហើយ នោះ អំឡុងពេលនៃការបោះបង់ និងទទួលយកសន្តតិកម្មបានចាប់ផ្តើមដែលមានរយៈពេល ៣ ខែ ប៉ុន្តែស្រាប់តែក្នុងអំឡុងពេល ៣ ខែនោះបុគ្គល ខ បានស្លាប់ដោយបន្សល់នូវកូនមានឈ្មោះ គ។ ក្នុងករណីនេះអំឡុងពេលនៃការសម្រេចចិត្តទទួល និងបោះបង់របស់បុគ្គល គ ចំពោះបុគ្គល ខ បាន ចាប់ផ្តើម តែដោយសារតែបុគ្គល ខ នៅមានសន្តតិកម្មដែលមិនទាន់សម្រេចចិត្តនោះ ដូចនេះបុគ្គល គ អាចធ្វើការសម្រេចចិត្តបានពីរយ៉ាង ដោយទី ១ បុគ្គល គ អាចសម្រេចបោះបង់ចោលសន្តតិកម្ម របស់ ខ បាន ប៉ុន្តែប្រសិនបើគាត់សម្រេចដូចនេះគាត់មិនអាចទទួលយកនូវសន្តតិកម្មរបស់ ក ចំពោះ ខ បាននោះទេព្រោះថាគាត់បានសម្រេចមិនទទួលយក សន្តតិកម្មរបស់ ខ រួចហើយ។ ក្នុង ករណីម្យ៉ាងទៀតគឺបុគ្គល គ ក៏អាចសម្រេចទទួលយកសន្តតិកម្មរបស់ ខ បានដោយគាត់អាច សម្រេចទទួលយកទាំងស្រុង ឬដោយមានកម្រិតបាន ហើយអាចសម្រេចយកមតិករបស់ ខ ហើយ បោះបង់ចោលចំណែកដែលជាសន្តតិកម្មរបស់ ក ឬ អាចទទួលយកដោយកម្រិតទៅលើមតិករបស់ ខ និងទទួលយកទាំងស្រុងចំពោះមតិករបស់ ក ឬសម្រេចទទួលយកទាំងស្រុងនូវចំណែក មតិករបស់ ខ ដោយត្រូវទទួលនូវសិទ្ធិ និងករណីយកិច្ចទាំងស្រុងរួមទាំងលើចំណែកមតិករបស់ បុគ្គល ក ផងដែរ[42]។

### ១.២.២. អំឡុងពេលក្នុងករណីពិសេសដោយសន្តតិជនជាអនីតិជន ឬ ស្ថិតក្រោម អាណាព្យាបាលទូទៅ

ចំនុចពិសេសមួយទៀត គឺសន្តតិជនជាអនីតិជន ឬ ក៏ជាជនស្ថិតនៅក្រោមអាណាព្យាបាល ទូទៅ។ សន្តតិជនគឺសុទ្ធតែជាជនដែលពុំមានសមត្ថភាពគ្រប់គ្រាន់ក្នុងការធ្វើសេចក្តីសម្រេចសំខាន់ៗ ដោយសារពួកគាត់នៅពុំទាន់មានការគិតគ្រប់ជ្រុងជ្រោយ និងពុំអាចដឹងអំពីលទ្ធផលតាមផ្លូវ ច្បាប់ដែលអាចនឹងកើតចេញពីសកម្មភាពនីមួយៗរបស់ពួកគាត់នោះទេ ឬ ពុំមានសតិគ្រប់គ្រាន់ក្នុង ការសម្រេចចិត្តខ្លួនឯងនោះទេ។ ដើម្បីធ្វើសកម្មភាពណាមួយ រួមទាំងការយល់ព្រមលើសន្តតិកម្ម

[42] មាត្រា ១២៤៩ នៃសេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី

ផងដែរ ទាំង អនីតិជន និងជនស្ថិតនៅក្រោមរបបអាណាព្យាបាលទូទៅ ត្រូវមានការចូលរួមរបស់អ្នកតំណាងដែលកំណត់ដោយច្បាប់។

ដោយហេតុនេះ អំឡុងពេលត្រូវចាប់គិតពីពេលដែលអ្នកតំណាងស្របច្បាប់របស់អនីតិជន ឬ ជនស្ថិតនៅក្រោមអាណាព្យាបាលទូទៅ ដឹងពីការចាប់ផ្តើមនូវសន្តតិកម្ម[43]។ បានន័យថាបើទោះបីជា អនីតិជន ឬ ជនស្ថិតក្រោមអាណាព្យាបាលទូទៅ បានទទួលដំណឹងអំពីការចាប់ផ្តើមនៃសន្តតិកម្មក៏ដោយ ក៏គេមិនចាត់ទុកជាបានការនោះដែរ។

## ១.២.៣ អំឡុងពេលក្នុងករណីពិសេសដោយសន្តតិជនមិនដឹងពីកាតព្វកិច្ច

ជាទូទៅ ប្រសិនបើដឹងថាមតិកនៃសន្តតិកម្មណាមួយមានភ្ជាប់កាតព្វកិច្ចលើសលុបដែលមិនអាចយកមតិកដែលមានទៅទូទាត់ដាច់ស្រេចនោះ សន្តតិជននឹងមិនទទួលសន្តតិកម្មនោះទេ ព្រោះថាបើយកសន្តតិកម្មនោះមក គឺមានតែធ្វើឲ្យខាតប្រយោជន៍ខ្លួនប៉ុណ្ណោះ។ ដូចនេះ ដើម្បីការពារសន្តតិជនពីការមិនដឹងអំពីកាតព្វកិច្ច ហើយបែរជាទទួលយកមតិកដែលមានកាតព្វកិច្ចច្រើនទៅវិញ ទើបមាត្រា ១២៥១ នៃក្រមរដ្ឋប្បវេណីបានទុកអំឡុងពេលឲ្យសន្តតិជនធ្វើការសម្រេចចិត្តដើម្បីយល់ព្រមលើសន្តតិកម្មក្នុងរយៈពេល ០៣ ខែដោយគិតចាប់ពីពេលដែលសន្តតិជនបានដឹងអំពីអត្ថិភាពនៃកាតព្វកិច្ចនៃសន្តតិកម្ម។ មានន័យថាអំឡុងពេលដែលមានរយៈពេល ០៣ ខែសម្រាប់ធ្វើការយល់ព្រមចំពោះសន្តតិកម្មត្រូវគិតចាប់ពីពេលដែលសន្តតិជនបានដឹងថាកាតព្វកិច្ចនៃសន្តតិកម្មដែលខ្លួននឹងទទួលនោះមានត្រឹមកំរិតណា ដើម្បីឲ្យសន្តតិជនសម្រេចចិត្តទទួលនូវកាតព្វកិច្ចនោះឲ្យបានត្រឹមត្រូវ និងជៀសវាងប៉ះពាល់ដល់ប្រយោជន៍របស់សន្តតិជន។

ម្យ៉ាងទៀត បើទោះបីជាសន្តតិជនបានយកមតិកដែលខ្លួនទទួលបានទៅចាត់ចែងក្នុងគោលបំណង ដើម្បីសងកាតព្វកិច្ចដែលត្រូវបានទទួលតាមរយៈសន្តតិកម្មនៅមុនពេលបានដឹងអំពីអត្ថិភាពនៃកាតព្វកិច្ចនេះក៏ដោយ គេមិនអាចចាត់ទុកថាគាត់បានទទួលមតិកនោះដែរ[44]។ ព្រោះថាសន្តតិជន មិនបានប្រើប្រាស់ទ្រព្យជាមតិកដើម្បីប្រយោជន៍ខ្លួននោះទេ គឺគ្រាន់តែចាត់ចែងដើម្បីទូទាត់បំណុល ឬកាតព្វកិច្ចដែលមានលើសន្តតិកម្មនេះប៉ុណ្ណោះ។

---

[43] មាត្រា ១២៥០ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា

[44] មាត្រា ១២៥១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា

ការមិនដឹងអំពីកាតព្វកិច្ច ដែលជាហេតុនាំឲ្យមានការកែប្រែនូវពេលចាប់ផ្តើមនៃអំឡុងពេលសម្រាប់យល់ព្រមលើសន្តតិកម្ម លុះត្រាតែការមិនដឹងនេះមានមូលហេតុដូចជាពាក់ព័ន្ធនឹងស្ថានភាពនៃជីវភាពរបស់មតកជន ស្ថានភាពនៃទ្រព្យសម្បត្តិរបស់មតកជន ឬស្ថានភាពផ្សេងៗទៀតដែលមិនអាចឲ្យសន្តតិជនដឹងពីអត្ថិភាពនៃកាតព្វកិច្ចបាន[45]។ ចំនុចនេះគឺចង់បញ្ជាក់ពីកាលៈទេសៈមួយចំនួនដែលគេចាត់ទុកជាមូលហេតុដែលនាំឲ្យសន្តតិជនមិនអាចដឹងពីទ្រព្យសម្បត្តិ និងកាតព្វកិច្ចដែលមតកជនមាននៅពេលដែលគាត់នៅរស់។ ពាក់ព័ន្ធនឹងស្ថានភាពនៃជីវភាពនោះគឺពេលខ្លះសន្តតិជនគាត់ជាអ្នកចំណាកស្រុកដែលបានទៅរស់នៅឯបរទេស និងបានទុកកូននៅប្រទេសកម្ពុជា ហេតុនេះ ហើយដោយសារតែស្ថានភាពជីវភាពគាត់គឺនៅឯបរទេសដែលនាំឲ្យសន្តតិជនមិនអាចដឹងថាគាត់រស់នៅ ឯបរទេសនោះមានជាប់បំណុលគេយ៉ាងណាខ្លះទេ រហូតដល់សន្តតិជនព្រមទទួលហើយ តែបែរជាមានម្ចាស់បំណុលមកទាមទារបំណុលទៅវិញ។ ក្នុងករណីមួយទៀតគឺមតកជនទៅធានាបំណុលមិត្តភក្តិរបស់ខ្លួន ហើយនូវពេលដែលខ្លួនទទួលមរណភាពទៅ ក៏មិនបានប្រាប់ជនណាម្នាក់ដែរ។ ក្រោយមកសន្តតិជនរបស់មតកជននោះបានទទួលសន្តតិកម្ម ស្រាប់តែក្រោយមកម្ចាស់បំណុល បានមកទាមទារប្រាក់ដែលមិត្តភក្តិរបស់មតកជនបានជំពាក់ ដោយហេតុថាមិត្តរបស់មតកជននោះបាន ក្ស័យធន និងរត់ទៅបាត់។ ឬក៏អាចមានករណីផ្សេងទៀតដូចជាការវិនិយោគធ្វើសម្បទានដីធ្លី ដែលការរកស៊ីរបស់មតកជនគ្មានជនណាដឹងថាយ៉ាងម៉េចខ្លះនោះទេ ក្រោយមកសន្តតិជនបានទទួលយកដី សម្បទាននោះ ហើយស្រាប់តែបានដឹងថា ដីនេះមានជាប់ធនាគារដែលមានបំណុលលើសលុបមានតម្លៃច្រើនជាដី ដែលគាត់ទទួលនោះទៅទៀត។ ក្នុងករណីទាំងអស់នេះសន្តតិជនពុំបានដឹងពីបំណុលដែលមានលើសន្តតិកម្មនោះទេ ហើយក៏មានករណីផ្សេងទៀតដែរដែលមិនអាចឲ្យសន្តតិជនដឹងបានពីកាតព្វកិច្ចលើទ្រព្យជាមតិកនោះ។ ហេតុដូចនេះច្បាប់បានផ្តល់សិទ្ធិឲ្យសន្តតិជនអាចមានពេលសម្រេចចិត្តម្តងទៀតក្នុងអំឡុងពេល ០៣ ខែនេះ ចាប់ពីពេលដែលខ្លួនបានដឹងពីតម្លៃនៃកាតព្វកិច្ច។

[45] មាត្រា ១២៥១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា

## ផ្នែកទី ២៖ ការលុបចោលការយល់ព្រម ឬ ការបោះបង់សន្តតិកម្ម

### ២.១ មូលហេតុនៃការលុបចោលការយល់ព្រម ឬ ការបោះបង់សន្តតិកម្ម

បើទោះបីជាការយល់ព្រម ឬ ការបោះបង់សន្តតិកម្ម ជាសិទ្ធិមួយរបស់សន្តតិជនក៏ដោយ ក៏នៅពេលដែលសន្តតិជនបានអនុវត្តសិទ្ធិនេះហើយ សន្តតិជនពុំអាចលុបចោលការអនុវត្តរបស់គាត់បានដោយងាយៗនោះទេ។

ចំពោះករណីនេះក្រមរដ្ឋប្បវេណីក៏បានចែងផងដែរ សន្តតិជនគឺពុំអាចលុបចោលនូវការយល់ព្រម ឬការបោះបង់សន្តតិកម្មរបស់ខ្លួននោះទេ បើទោះបីជាអំឡុងពេល ០៣ ខែដែលច្បាប់បានទុកឲ្យសន្តតិជនសម្រេចចិត្តនោះ មិនទាន់ផុតក៏ដោយ[46]។ ច្បាប់ចែងបែបនេះដោយមានគោលបំណងបកស្រាយអំពីមូលហេតុនៃការបដិសេធទៅលើការលុបចោល ពីព្រោះថាការអនុវត្តសិទ្ធិរបស់សន្តតិជនដែលយល់ព្រម និងបោះបង់សន្តតិកម្មនោះគឺមិនមែនមានឥទ្ធិពលត្រឹមខ្លួនឯងម្នាក់ប៉ុណ្ណោះទេ វាមានឥទ្ធិពលដល់ជនដ៏ទៃដែលមានពាក់ព័ន្ធជាមួយនឹងសន្តតិកម្មនេះតែម្តង។ បានន័យថាប្រសិនបើគាត់ធ្វើការសម្រេចទទួលយក ឬយល់ព្រមដោយមានកម្រិតនោះ មតិកដែលមានក្នុងសន្តតិកម្មត្រូវបែងចែកតាមវិធី និងចំណែកខុសគ្នា ហើយសល់ចំណែកប៉ុន្មានគឺអាចចែកទៅដល់សន្តតិជនដ៏ទៃទៀត។ ប្រសិនបើគាត់ធ្វើការសម្រេចចិត្តថាបោះបង់នោះ សន្តតិកម្មនោះគឺត្រូវប្រគល់ទៅដល់សន្តតិជនលំដាប់ក្រោយៗទៀត។ យើងអាចឃើញបានថាការសម្រេចចិត្តរបស់សន្តតិជនចំពោះការយល់ព្រម និងបោះបង់នេះគឺមានពាក់ព័ន្ធជាមួយនឹងសិទ្ធិរបស់ជនដ៏ទៃទៀត ហេតុនេះហើយ ច្បាប់មិនអនុញ្ញាតឲ្យសន្តតិជនធ្វើការលុបចោលការសម្រេចចិត្តយល់ព្រម ឬបោះបង់របស់ខ្លួនដោយងាយៗនោះទេ។

ទោះបីជាច្បាប់មានការរិតត្បិតត្រង់ការលុបចោលការយល់ព្រម ឬបោះបង់សន្តតិកម្មនេះក៏ដោយ ប៉ុន្តែក្នុងករណីខ្លះច្បាប់ក៏បើកសិទ្ធិឲ្យសន្តតិជនលុបចោលនូវការសម្រេចចិត្តរបស់ខ្លួនដែរ ដើម្បីជៀសវាងមានផលប៉ះពាល់ដោយមិនសមហេតុផលដល់សន្តតិជន។ ដូចនេះ ច្បាប់បានអនុញ្ញាតឲ្យសន្តតិជន លុបចោលនូវសេចក្តីសម្រេចរបស់ខ្លួនដោយត្រូវមានមូលហេតុពាក់ព័ន្ធនឹងវិការៈក្នុងការបង្ហាញឆន្ទៈរបស់ខ្លួននៅពេលដែលសម្រេចនោះ។ វិការៈនៅក្នុងចំនុចនេះក៏ដូចជាវិការៈក្នុងផ្នែកដ៏ទៃនៃក្រមរដ្ឋប្បវេណីដែលមានដូចជា ការសម្រេចចិត្តដោយមានការគម្រាមកំហែង ការឆបោក ភាន់ច្រឡំ និងវិការៈផ្សេងៗទៀត។ ដើម្បីឲ្យកាន់តែច្បាស់នៅត្រង់ចំនុចនេះយើងអាចលើកឧទាហរណ៍ថា ខ គឺជាសន្តតិជនរបស់ ក ហើយ ខ មានពេល ០៣ខែក្នុងការសម្រេចចិត្តយល់ព្រម

[46] មាត្រា ១២៥២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា

ឬបោះបង់សន្តតិកម្មចំពោះខ្លួន។ ប៉ុន្តែសន្តតិកម្មនោះត្រូវបានរកឃើញថាមានជាប់កាតព្វកិច្ចច្រើនលើសលុប ហើយ ខ មានបំណងបោះបង់ចោល ដោយសារហេតុនេះម្ចាស់បំណុលរបស់ ក ដោយមានការបារម្ភថាបើសន្តតិជនបោះបង់សន្តតិកម្មនោះចោល គាត់មិនអាចទទួលបានសំណងមកវិញព្រោះថាទ្រព្យដែលជាមតិកនោះមិនអាចទូទាត់សងអស់នោះទេ។ ដោយសារតែមានការបារម្ភបែបនេះម្ចាស់បំណុលបានទៅគំរាមឲ្យ ខ នោះទទួលសន្តតិកម្មនោះដើម្បីឲ្យម្ចាស់បំណុលអាចទាមទារដល់ទ្រព្យរបស់ ខ បានទៀត។ យោងតាមឧទាហរណ៍យើងបានឃើញថា សន្តតិជនសម្រេចចិត្តដោយមានវិការៈជាការគំរាមកំហែងពីម្ចាស់បំណុលរបស់មតកជន ហេតុនេះច្បាប់បានផ្តល់ឱកាសដល់សន្តតិជនធ្វើការលុបចោលការសម្រេចចិត្តរបស់ខ្លួនបានដើម្បីជៀសវាងប៉ះពាល់ដល់ទ្រព្យសម្បត្តិ ឬផលប្រយោជន៍នានារបស់សន្តតិជន។

## ២.២. អំឡុងពេលដែលអាចលុបចោលការយល់ព្រម ឬ ការបោះបង់សន្តតិកម្ម

អំឡុងពេលដែលអាចលុបចោលការយល់ព្រម ឬការបោះបង់សន្តតិកម្ម គឺជាពេលវេលាសម្រាប់ឲ្យសន្តតិជនដែលបានយល់ព្រម ឬបោះបង់សន្តតិកម្ម អាចពិចារណាសារជាថ្មីទៅលើការសម្រេចចិត្តរបស់ខ្លួនទៅលើសន្តតិកម្ម។ ជាដំបូង យើងគួរកត់សម្គាល់ថាអាជ្ញាយុកាលនៃការលុបចោលមានភាពពិសេស នៅពេលប្រៀបធៀបទៅលើអាជ្ញាយុកាលនៃការរំលត់សិទ្ធិទាមទារសំណងទូទៅដែលមានរយៈពេល ០៥ឆ្នាំ[47]។ នៅក្នុងកិច្ចសន្យាធម្មតា អាជ្ញាយុកាលនៃការរំលត់សិទ្ធិទាមទារនឹងត្រូវបានគណនានៅពេលដែលការខូចខាតកើតឡើង និងមានរយៈពេល ០៥ឆ្នាំ។ ផ្ទុយទៅវិញ ការចាប់ផ្តើមរាប់ទៅលើអាជ្ញាយុកាល និងរយៈពេលអាជ្ញាយុកាលមានភាពខុសគ្នា។ អំឡុងពេលសម្រាប់ការលុបចោលសិទ្ធិ មានរយៈពេលកំណត់ត្រឹម ៦ ខែគិតចាប់ពីពេលដែលអាចផ្តល់សច្ចានុមតិបាន ប្រសិនបើគេរកឃើញថា ការយល់ព្រម ឬការបោះបង់បានធ្វើឡើងដោយសារមានវិការៈដូចបានរៀបរាប់ខាងលើ[48]។ ក៏ប៉ុន្តែទោះបីស្ថិតនៅក្រោមឥទ្ធិពលរបស់វិការៈក្តី បើសិទ្ធិលុបចោលនេះ ពុំត្រូវបានអនុវត្តនៅក្នុងរយៈពេលកំណត់នេះ សិទ្ធិនេះនឹងត្រូវរលត់ ដែលនាំឲ្យបុគ្គលជាសន្តតិជននោះមិនអាចលុបចោលការយល់ព្រម ឬការបោះបង់សន្តតិកម្មជារាងរហូត។ យើងអាចសង្កេតឃើញថា អំឡុងពេលដែលអាចលុបចោលការយល់ព្រម ឬការបោះបង់សន្តតិកម្ម មានរយៈពេលវែងជាង អំឡុងពេលគិតជិតដល់រហូតដល់ទៅ ២ដង ស្មើរទៅនឹង ៣ខែ។ តែសិទ្ធិក្នុងការលុបចោលនេះ មិនអាចបណ្តាលឲ្យសន្តតិជនបន្តមានជារៀងរហូតបានឡើយ ដោយការធ្វើបែបនេះនឹង

[47] មាត្រា ៩០៦ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា

[48] មាត្រា ១២៥២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា

បង្កភាពប៉ះពាល់ទៅដល់ជនដែលពាក់ព័ន្ធ និងផលប្រយោជន៍របស់ពួកគេ។ យើងអាចឲ្យឧទាហរណ៍ថា លោក ក ជាសន្តតិជនដែលបានទទួលសន្តតិកម្ម ហើយនៅក្នុងសន្តតិកម្មនោះបានភ្ជាប់ជាមួយនឹងកាតព្វកិច្ចក្នុងការសងបំណុលទៅដល់លោក គ។ ដូច្នេះប្រសិនបើ ក អាចលុបចោលការទទួលសន្តតិកម្មរបស់លោកពេលណាក៏បានដែរនោះ លោក គ ដែលជាម្ចាស់បំណុលនឹងទទួលរងនូវការខូចខាតយ៉ាងខ្លាំងទៅដល់ផលប្រយោជន៍របស់ គាត់។ លើសពីនេះទៅទៀត អំឡុងពេលដែលអាចលុបចោលបាន អាចមានរយៈពេលរហូតទៅដល់ រយៈពេល ៥ឆ្នាំ នៅក្នុងករណីដែលសិទ្ធិនេះពុំបានអនុវត្តទាល់តែសោះ នៅក្នុងរយៈពេលដែលបានកំណត់ ៥ឆ្នាំនេះ ហើយការគណនានៃអំឡុងពេលនេះត្រូវគិតពីពេលនៃការចាប់ផ្តើមធ្វើសន្តតិកម្ម។ ឧទាហរណ៍ ក្រោយពីមរណភាពរបស់លោក ខ ដែលជាមតកជននៃសន្តតិកម្ម លោក ក ដែលត្រូវជាសន្តតិជនបានចាប់ ផ្តើមទទួលសន្តតិកម្ម (ដែលមានដូចជា ផ្ទះ ឡាន និងបំណុលទៅកាន់លោក គ) នោះនៅឆ្នាំ ២០១០ ដោយលោកមិនបានដឹងថាសន្តតិកម្មនោះបានផ្ទុកនូវកាតព្វកិច្ចក្នុងការសងបំណុលរបស់ម្ចាស់បំណុលឈ្មោះ គ។ ដោយវិការៈ នៃការភាន់ច្រលំ បានធ្វើឲ្យ ក មិនបានព្យាយាមនៅក្នុងវិធីណាមួយដើម្បីបំពេញកាតព្វកិច្ចក្នុងនាមជាកូនបំណុលទៅកាន់លោក គ ទាល់តែសោះ។ លុះដល់ឆ្នាំ ២០១៤ លោក គ បានផ្ញើរលិខិតដាស់តឿនមួយ ជូនមកលោក ក ដើម្បីដាស់តឿន ក ឲ្យអនុវត្តកាតព្វកិច្ចរបស់ខ្លួន។ នៅក្នុងករណីនេះ លោក ក អាចធ្វើការលុបចោល ការយល់ព្រមសន្តតិកម្មបានដោយព្រឹត្តិការណ៍នេះ បានកើតឡើងនៅក្នុងរង្វង់ពេល ៥ឆ្នាំ ដែលបានកំណត់។ ចំនុចខុសគ្នារវាងរយៈពេល ០៦ ខែ និងរយៈពេល ៥ឆ្នាំ នៃការគណនាអំឡុងពេលសិទ្ធិលុបចោល ជាចំនុចសំខាន់គួរឲ្យកត់សម្គាល់ដោយសារការលុបចោលបានឈរលើមូលហេតុវិការៈដូចគ្នា ក៏ប៉ុន្តែ រយៈពេលនៃការអនុវត្តិសិទ្ធិលុបចោលមានរយៈពេលខុសគ្នារហូតដល់ទៅ ៤ឆ្នាំ ៦ខែ ឯណោះ។ មូលហេតុគឺដោយសារ អំឡុងពេល ០៦ ខែ គឺត្រូវបានកំណត់ក្នុងន័យថាសន្តតិជន ដែលមានបំណងក្នុងការលុបចោលនោះ អាចផ្តល់សច្ចានុមតិបានក្នុងរយៈពេលនោះ ដូច្នេះបើបុគ្គលនោះ មានលទ្ធភាពហើយមិនបានចូលមក ផ្តល់សច្ចានុមតិក្នុងអំឡុងពេលដែលបានកំណត់ទង្វើនេះបានបង្ហាញថា ជននោះមិនមានឆន្ទៈក្នុងការលុបចោលឡើយ។ រីឯអំឡុងពេល ០៥ឆ្នាំវិញ សំដៅទៅកាន់សន្តតិជនដែលមិនមាន ឱកាសក្នុងការផ្តល់សច្ចានុម័ត នៅក្នុងករណីនេះ ច្បាប់បានផ្តល់ឱកាសជូនពួកគាត់រហូតដល់ ៥ឆ្នាំគិតពីការចាប់ផ្តើមធ្វើសន្តតិកម្ម។ តែទោះបីជាពួកគាត់មិនអាចផ្តល់សច្ចានុមតិក្តី ប្រសិនបើលើសរយៈពេល ៥ឆ្នាំហើយ ពួកគាត់មិនបាន អនុវត្តសិទ្ធិលុបចោល នោះគេក៏អាចសន្មតថាជននោះមិនមានឆន្ទៈក្នុងការលុបចោលដែរ។

# សេចក្តីសន្និដ្ឋាន

សរុបសេចក្តីមក ប្រធានបទ "**ការយល់ព្រម និងការបោះបង់សន្តតិកម្ម**" ជាប្រធានបទមួយដែលបង្ហាញនូវសិទ្ធិ និងករណីយកិច្ចទាំងឡាយដែលបុគ្គលជាសន្តតិជនមានចំពោះសន្តតិកម្មរបស់ ខ្លួន។ ក្រោយពីបានសិក្សានូវប្រធានបទនេះហើយ យើងអាចឃើញបានថាសិទ្ធិ និងកាតព្វកិច្ចចំពោះ មតិកគឺមិនមែនតែងតែធ្លាក់មកលើទាយាទរហូតនោះទេ ព្រោះថានាពេលបច្ចុប្បន្ននេះ ច្បាប់បានធ្វើការសម្រួលដល់ទាយាទដោយផ្តល់នូវសិទ្ធិក្នុងការសម្រេចចិត្តយល់ព្រមទទួលយក ឬបោះបង់សន្តតិកម្មដែលមានចំពោះខ្លួនបាន ជៀសវាងមានការប៉ះពាល់ធ្ងន់ធ្ងរដល់សន្តតិជន។ ក្រោយពីបានសិក្សាប្រធានបទនេះរួចហើយ យើងឃើញថានៅក្នុងការយល់ព្រមទទួលសន្តតិកម្មនោះ យើងអាចឃើញបានថាសន្តតិជនគឺមានជម្រើសពីររួមមានការយល់ព្រមទាំងស្រុង និងការយល់ព្រមដោយកម្រិត ដែលការជ្រើសរើសទាំងពីរនេះមាននីតិវិធី និងអានុភាពខុសគ្នាផងដែរ។ ដូចនេះសន្តតិជនត្រូវពិចារណាឲ្យច្បាស់លាស់មុននឹងធ្វើការជ្រើសរើសយល់ព្រមតាមវិធីណាមួយ ជៀសវាងអានុភាពនៃការសម្រេចចិត្តរបស់ខ្លួនមានការប៉ះពាល់ដល់ប្រយោជន៍ខ្លួន និងអ្នកដំទៃក្នុងថ្ងៃអនាគត។ ប៉ុន្តែក្រៅពីការយល់ព្រមហើយនោះ ច្បាប់ក៏បានបើសិទ្ធិឲ្យសន្តតិជនបោះបង់សន្តតិកម្មចំពោះខ្លួនផងដែរប្រសិនបើវានឹងធ្វើឲ្យប៉ះពាល់ដល់ប្រយោជន៍របស់ខ្លួន។ ការសម្រេចចិត្តយល់ព្រម និងបោះបង់សន្តតិកម្មនេះគឺមាន សារៈសំខាន់ណាស់ចំពោះសន្តតិជន និងជនពាក់ព័ន្ធទាំងឡាយ ហេតុដូច្នេះហើយច្បាប់គឺមានការរិតត្បិតក្នុងការកែប្រែសេចក្តីសម្រេចរបស់សន្តតិជន ពីព្រោះថាបើសន្តតិជនអាចកែប្រែការសម្រេចចិត្តរបស់ខ្លួនដោយងាយស្រួលនោះ វាច្បាស់ជាធ្វើឲ្យប៉ះពាល់ដល់ជនដែលមានផលប្រយោជន៍នៅក្នុងសន្តតិកម្មនេះ ដូចជាសន្តតិជនដែលមានលំដាប់ក្រោយជាដើម។

ដូច្នេះយើងឃើញថាការអនុវត្តសិទ្ធិយល់ព្រម និងបោះបង់សន្តតិកម្មនេះមានអត្ថប្រយោជន៍ខ្លាំងណាស់ចំពោះសន្តតិជន និងជនដែលពាក់ព័ន្ធទាំងឡាយ។ ហេតុនេះហើយមនុស្សគ្រប់រូបគួរយកចិត្តទុកដាក់ និងសិក្សាពីប្រធានបទនេះឲ្យបានស៊ីជម្រៅ ដើម្បីជៀសវាងការប៉ះពាល់ដល់ប្រយោជន៍ខ្លួនដោយសារតែពុំបានយល់នូវសិទ្ធិ និងករណីយកិច្ចរបស់ខ្លួននៅពេលដែលសន្តតិកម្មបានចាប់ផ្តើមចំពោះខ្លួននោះ។

## ឯកសារយោង


១. ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា, ព្រះរាជក្រម នស/រកម/១២០៧/០៣០

២. ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីឆ្នាំ ២០១១, ព្រះរាជក្រម នស/រកម/០៥១១/០០៧

៣. ច្បាប់ភូមិបាល ២០០១, ព្រះរាជក្រម នស/រកម/០៨០១/១៤

៤. ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ឆ្នាំ ២០១១, ព្រះរាជក្រម នស/រកម/០៧១០/០១៣

៥. សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី បោះពុម្ពថ្ងៃទី ០៩ ខែធ្នូ ឆ្នាំ ២០០៩

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

3

## <u>ពាក្យសុំលុបចោល</u>

**<u>មេធាវីតំណាងដោយអាណត្តិ:</u>** មេធាវី **គ** អត្តលេខ .......... និងមេធាវី **ឃ** ជាសមាជិកមេធាវីនៃ ក្រុមមេធាវី **ខ** ជាមេធាវីតំណាងដោយអាណត្តិឲ្យឈ្មោះ **ក** និង **ខ**។

**<u>អ្នកសុំ:</u>** ឈ្មោះ **ក** ភេទស្រី អាយុ ៧៥ឆ្នាំ និងឈ្មោះ **ខ** ភេទស្រី អាយុ ៣៦ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នផ្ទះលេខ: ..........................................................................................................។

**សូមគោរពចូលមក**

**លោក ប្រធានសាលាដំបូងរាជធានីភ្នំពេញ**

*<u>សូមទានជ្រាប។</u>*

**<u>កម្មវត្ថុ:</u>** សុំឲ្យសាលាដំបូងរាជធានីចេញដីកាលុបចោលការសុំទទួលសន្តតិកម្មដែលបានដាក់ជូននៅថ្ងៃXX ខែXX ឆ្នាំXXXX។

**<u>យោង:</u>** - ដីកាសម្រេចទទួលស្គាល់ការយល់ព្រមសន្តតិកម្មចុះថ្ងៃទីXX ខែXX ឆ្នាំXXXX។

- កិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី ២១ ខែកុម្ភៈ ឆ្នាំ២០១២។
- លិខិតជូនដំណឹងមរណៈភាពលេខ: XX/មព១៤ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៦ របស់មន្ទីរពេទ្យព្រះកេតុមាលា។
- សេចក្តីចម្លងសំបុត្រមរណៈភាព ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៤៦របស់ចៅសង្កាត់ទឹកល្អក់១។
- លិខិតបញ្ជាក់លេខ: XXX/១៤ក.ថ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៦ របស់មេឃុំកំពង់ថ្ម។

### អង្គហេតុចាំបាច់សំរាប់បញ្ជាក់ការទាមទារ:

នៅថ្ងៃទីXX ខែXX ឆ្នាំXXXX ឈ្មោះ ក ក្នុងនាមជាសន្តតិជន បានដាក់ពាក្យសុំទៅតុលាការដើម្បីយល់ព្រមសន្តតិកម្ម ក្នុងគោលបំណងគ្រប់គ្រងទ្រព្យសម្បត្តិរបស់បងស្រីខ្លួនដែលជាមតកជន។ ក៏ប៉ុន្តែ ឈ្មោះ ក មានភាពភាន់ច្រឡំនៅពេលសម្រេចចិត្តទទួលយកសន្តតិកម្មដោយ កូនក្តីខ្ញុំបាទមិនបានពិនិត្យច្បាស់លាស់ និងទើបតែដឹងថាមតកជនបានបន្សល់ទុកនូវកាតព្វកិច្ចសងបំណុលមកឲ្យសន្តតិជនចំនួន $២០,០០០០ (ម្ភៃម៉ឺនដុល្លារ) ដែលកូនក្តីរបស់ខ្ញុំបាទមិនមានលទ្ធភាពសងឡើយ។

### អង្គហេតុដែលជាមូលហេតុនៃការទាមទារ:

ដោយសារនាងខ្ញុំឈ្មោះ ក មានការភាន់ច្រឡំទៅលើ សិទ្ធិ និងកាតព្វកិច្ចរបស់សន្តតិកម្ម ដែលជាកម្មវត្ថុនៃការយល់ព្រមសន្តតិកម្ម (តាមមាត្រា១២៥២ ការលុបចោលការយល់ព្រម ឫការបោះបង់ នៃក្រម

រដ្ឋប្បវេណី) នាងខ្ញុំមានសំណូមពរទៅតុលាការឲ្យលុបចោលដីកាសម្រេចទទួលស្គាល់ការយល់ព្រមសន្ធតិកម្មចុះថ្ងៃទីXX ខែXX ឆ្នាំXXXX វិញ។

**ភស្តុតាងបញ្ជាក់ការទាមទារ:**

- កិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី ២១ ខែកុម្ភៈ ឆ្នាំ២០១២។

អាស្រ័យដូចបានជម្រាបជូនដូចខាងលើនេះ សូមលោក **ប្រធាន** មេត្តាពិនិត្យ និងសម្រេចតាមផ្លូវច្បាប់ ដោយក្តីអនុគ្រោះ ។

សូមលោក **ប្រធាន** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ។

រាជធានីភ្នំពេញ,ថ្ងៃទី .......... ខែ......... ឆ្នាំ............

**ស្នាមមេដៃស្តាំ**

***ជូនភ្ជាប់មកជាមួយនូវ:***

- កិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី ២១ ខែកុម្ភៈ ឆ្នាំ២០១២។
(ច្បាប់ថតចម្លង)

បានឃើញ

រាជធានីភ្នំពេញ,ថ្ងៃទី..........ខែមីនា ឆ្នាំ២០១៥

**ហត្ថលេខា និងត្រា**

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ
3

## ពាក្យសុំ

**មេធាវីតំណាងដោយអាណត្តិ:** មេធាវី **គ** អត្តលេខ .......... និងមេធាវី **ឃ** ជាសមាជិកមេធាវីនៃ ក្រុមមេធាវី **ខ** ជាមេធាវីតំណាងដោយអាណត្តិឲ្យឈ្មោះ **ក** និង **ខ**។

**អ្នកសុំ:** ឈ្មោះ **ក** ភេទស្រី អាយុ ៧៥ឆ្នាំ និងឈ្មោះ **ខ** ភេទស្រី អាយុ ៣៦ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នផ្ទះលេខ: ..........................................................................................។

### សូមគោរពចូលមក
### លោក ប្រធានសាលាដំបូងរាជធានីភ្នំពេញ

*សូមទានជ្រាប។*

**កម្មវត្ថុ:** សុំឲ្យសាលាដំបូងរាជធានីចេញដីកាសម្រេចដូចខាងដូចតទៅៈ

១. សុំសិទ្ធិគ្រប់គ្រងផ្ទះដីដែលមានទីតាំងស្ថិតនៅផ្ទះលេខ: ............................................. ..........................................រាជធានីភ្នំពេញ។

២. សុំសិទ្ធិគ្រប់គ្រងប្រាក់របស់មតកជន ទាំងអស់ ដែលបានផ្ញើរទុកនៅធនាគារអម្រឹត តាមគណនីលេខ: XXXXXXXX១០២១៥៩-៨ ។

៣. សុំសិទ្ធិគ្រប់គ្រងរថយន្តម៉ាក TOYOTA RAV4 ស្លាកលេខ ភ្នំពេញ ២Z ៥XXX ពណ៌ទឹកមាស របស់បងស្រី ក (មតកជន)។

៤. សុំសិទ្ធិគ្រប់គ្រងម៉ូតូម៉ាក Honda ប្រភេទ NBC ១១០D (២០១២) ពណ៌ខ្មៅ។

**យោង:** - គណនីលេខ: XXXXXXXXXXX-៨ របស់ធនាគារអម្រឹត។

- លិខិតជូនដំណឹងមរណ:ភាពលេខ: XX/មព១៤ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៦ របស់មន្ទីពេទ្យព្រះកេតុមាលា។
- សេចក្តីចម្លងសំបុត្រមរណៈភាព ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៨៦របស់ចៅសង្កាត់ទឹកល្អក់១។
- លិខិតបញ្ជាក់លេខ: XXX/១៤ក.ថ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៦ របស់មេឃុំកំពង់ថ្ម។

### អង្គហេតុចាំបាច់សំរាប់បញ្ជាក់ការទាមទារ:

នៅថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៦ ឈ្មោះ បងស្រីរបស់ក បានទទួលមរណ:ភាព នៅមន្ទីពេទ្យព្រះកេតុមាលា ហើយយើងខ្ញុំឈ្មោះ ក និងឈ្មោះ ខ បានមកចាត់ចែងរៀបចំពិធីបុណ្យទៅតាមប្រពៃណីទំនៀមទំលាប់ខ្មែររួចរាល់។ កាលពីឈ្មោះ បងស្រីរបស់ក នៅរស់ គាត់ពុំមានប្រពន្ធ និងកូនទេ គាត់មានទ្រព្យសម្បត្តិដូចបានរៀបរាប់ក្នុងកម្មវត្ថុខាងលើតែប៉ុណ្ណោះ។ មួយវិញទៀត មតកជន បានយកប្រាក់មួយចំនួនទៅផ្ញើរនៅធនាគារអម្រិត ក្នុងរយ:ពេលបីឆ្នាំ ដើម្បីសន្សំយកការប្រាក់ (Current Account) ហើយការ

ប្រាក់ដែលត្រូវទទួលបានពីធនាគារ គឺត្រូវបើកក្នុងមួយឆ្នាំម្តង។ រហូតមកដល់ពេលនេះ ឈ្មោះ ក ពុំដែលបានដកយកប្រាក់ដើម និងការប្រាក់ពីធនាគារនោះទេ ។

**អង្គហេតុដែលជាមូលហេតុនៃការទាមទារ:**

ដោយសារនាងខ្ញុំឈ្មោះ ក ត្រូវជាបងស្រីបង្កើត និងជាញាតិថ្នាក់ទី៣របស់មតកជន (តាមមាត្រា ១១៦០ សន្តតិជនដែលមានលំដាប់ទី៣ នៃក្រមរដ្ឋប្បវេណី) មានសិទ្ធិទទួលបានមរតកដោយស្វ័យប្រវត្តិ ព្រមទាំងមានការបារម្ភណ៍លើទ្រព្យសម្បត្តិរបស់ឈ្មោះ បងស្រី កុំឲ្យមានការបាត់បង់ ហេតុដូចនេះ យើងខ្ញុំ សុំតុលាការចេញដីកាសម្រេចដូចដែលមានក្នុងកម្មវត្ថុខាងលើ ទៅតាមផ្លូវច្បាប់។

**ភស្តុតាងបញ្ជាក់ការទាមទារ:**

- លិខិតជូនដំណឹងមរណៈភាពលេខ: XX/ម៣១៤ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៦ របស់មន្ទីរពេទ្យព្រះកេតុមាលា។
- សេចក្តីចម្លងសំបុត្រមរណៈភាព ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៦របស់ចៅសង្កាត់ទឹកល្អក់១។
- លិខិតបញ្ជាក់លេខ: XXX/១៦ក.ថ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៦ របស់មេឃុំកំពង់ថ្ម។
- លិខិតបញ្ជាក់ភាពនៅលីវ ពោះម៉ាយ មេម៉ាយ លេខ:XXX/១៥លប ទល១ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៥។
- សំបុត្របញ្ជាក់កំណើត ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០០៨ របស់ចៅសង្កាត់ទឹកល្អក់១។
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររបស់បងស្រី ក ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០៩។
- លិខិតបញ្ជាក់ការបង់ប្រាក់ពន្ធលេខ: 00XXXX ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១៦។
- ប័ណ្ណសម្គាល់យានយន្ត។
- បង្កាន់ដៃបង់ពន្ធរបស់រថយន្ត ២០១៤ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៦។
- វិញ្ញាបនប័ត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្ត ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៦។
- វិក័យប័ត្រ ហាងលក់ម៉ូតូហុងដា ឆាយ លី ចុះថ្ងៃទី២១ ខែ០៦ ឆ្នាំ២០១៦។

អាស្រ័យដូចបានជម្រាបជូនដូចខាងលើនេះ សូមលោក **ប្រធាន** មេត្តាពិនិត្យ និងសម្រេចតាមផ្លូវច្បាប់ ដោយក្តីអនុគ្រោះ ។

សូមលោក **ប្រធាន** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ។

រាជធានីភ្នំពេញ,ថ្ងៃទី .......... ខែមីនា ឆ្នាំ២០១៥

**ស្នាមមេដៃស្តាំ**

***ជូនភ្ជាប់មកជាមួយនូវៈ***

- លិខិតជូនដំណឹងមរណៈភាពលេខៈ XX/មព១៦ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៦ របស់មន្ទីរពេទ្យព្រះកេតុមាលា។
- សេចក្តីចម្លងសំបុត្រមរណៈភាព ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៦ របស់ចៅសង្កាត់ទឹកល្អក់១។
- លិខិតបញ្ជាក់លេខៈ XXX/១៦ក.ថ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៦ របស់មេឃុំកំពង់ថ្ម។
- លិខិតបញ្ជាក់ភាពនៅលីវ ពោះម៉ាយ មេម៉ាយ លេខៈ១៩៦/១៥ លប ទល១ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៥។
- សំបុត្របញ្ជាក់កំណើត ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០០៥ របស់ចៅសង្កាត់ទឹកល្អក់១។
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរឈ្មោះ ខ្លូត ពៅ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០១។
- លិខិតបញ្ជាក់ការបង់ប្រាក់ពន្ធលេខៈ ០០XXXX ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១៥។
- ប័ណ្ណសម្គាល់យានយន្ត។
- បង្កាន់ដៃបង់ពន្ធរបស់រថយន្ត ២០១៤ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៤។
- វិញ្ញាបនប័ត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្ត ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៤។
- វិក័យប័ត្រ ហាងលក់ម៉ូតូហុងដា ឆាយ លី ចុះថ្ងៃទី២១ ខែ០៦ ឆ្នាំ២០១៣។
- ឯកសារកាលប្បវត្តិ។

(ច្បាប់ថតចម្លង)

បានឃើញ

រាជធានីភ្នំពេញ,ថ្ងៃទី..........ខែមីនា ឆ្នាំ២០១៥

**ហត្ថលេខា និងត្រា**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

៣៣៣✸៤៤៤

# <u>ពាក្យស្នើសុំស្វែងរកមត៌ក</u>

ខ្ញុំបាទមេធាវី ............. អត្តលេខ .............. ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា មានការិយាល័យមេធាវីឈ្មោះ .................................. មានទីស្នាក់ការនៅ......................................... ជាមេធាវីតំណាងដោយអាណត្តិឲ្យលោក/លោកស្រី.....................................។

**<u>សូមគោរពជូន</u>**

**លោក/លោកស្រី .................... ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ**

**<u>កម្មវត្ថុ:</u>** ស្នើសុំលោកចៅក្រមជួយស្វែងរកមតិកដែលជាទ្រព្យរបស់លោក.......................................។

**<u>យោង:</u>** -សំណុំរឿងរដ្ឋប្បវេណីលេខ .....................ចុះថ្ងៃទី ............ ខែ................. ឆ្នាំ ................. របស់សាលាដំបូងរាជធានីភ្នំពេញ

តាមកម្មវត្ថុ និងយោងខាងលើខ្ញុំបាទសូមជំរាបជូន **លោកចៅក្រម** មេត្តាជ្រាបថា: កាលពីថ្ងៃទី .......................................... កូនក្តីខ្ញុំបានដាក់ពាក្យបណ្តឹងសុំទាមទារ និងបែងចែកមតិកទៅសាលាដំបូងរាជធានីភ្នំពេញរួចហើយ។ តែក្រោយមកកូនក្តីខ្ញុំបានប្រទះឃើញថាទ្រព្យសម្បត្តិដែលជាមតិករបស់លោក/លោកស្រី ......................................គឺនៅសល់មួយចំនួនទៀត ម្យ៉ាងវិញទៀតកូនក្តីខ្ញុំក៏បានស្វែងរកអស់លទ្ធភាពហើយដែរតែនៅតែរកពុំទាន់ឃើញ។ ហេតុដូច្នេះហើយទើបសំណូមពរលោកចៅក្រមមេត្តាជួយស្វែងរកទ្រព្យដែលនៅសល់ទាំងនោះ។

អាស្រ័យដូចបានជម្រាបខាងលើសូម **លោក/លោកស្រីចៅក្រម** មេត្តាពិនិត្យ និងសម្រេចតាមកម្មវត្ថុខាងលើ។

សូម **លោក/លោកស្រីចៅក្រម** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

រាជធានីភ្នំពេញ,ថ្ងៃទី ............ ខែ................ ឆ្នាំ .....................

**ហត្ថលេខា និងត្រា**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្ត**
**កំពត**

**ដីកាលេខ:** ០៦ ចុះថ្ងៃទី២៣
ខែកុម្ភៈ ឆ្នាំ២០១៧

# ដីកាសម្រេច

បានឃើញ សំណុំរឿងរដ្ឋប្បវេណីលេខ០១ ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៦

**ជនពាក់ព័ន្ធ:**

**-អ្នកដាក់ពាក្យសុំ:**

-ដើមចោទឈ្មោះស៊ឹម ភេទស្រី អាយុ៥៥ ឆ្នាំ ជាតិខ្មែរឥស្លាម ទីលំនៅបច្ចុប្បន្ន នៅភូមិ ត្រពាំងរពៅ ឃុំព្រៃកន្ទោត ស្រុក ខេត្ត ។

-ដើមចោទឈ្មោះស៊ឹម ភេទប្រុស អាយុ៤២ ឆ្នាំ ជាតិខ្មែរឥស្លាម ទីលំនៅបច្ចុប្បន្ននៅភូមិ បឹងតាស្រី ឃុំបឹងតាព្រហ្ម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ។

តំណាងដោយអាណាព្យាបាល លោកមេធាវីលី គុសល

**ភាគីម្ខាងទៀត:**

-ចុងចម្លើយឈ្មោះ ម៉ៃ ភេទស្រី អាយុ៣២ឆ្នាំ ជាតិខ្មែរឥស្លាម ទីលំនៅបច្ចុប្បន្ននៅភូមិ តាដឹប សង្កាត់អណ្តូងខ្មែរ ក្រុងកំពត ខេត្តកំពត ។

**ការទាមទារ:**

សុំបែងចែកទ្រព្យសម្បត្តិ ដែលជាកេរ្តិ៍មរតកបន្សល់ទុកពីលោកតា ស៊ឹម និង លោកយាយ គង់ ដែលមានដីទំហំ ៥០០០ (ប្រាំពាន់) ម៉ែត្រការ៉េ មានក្បាលដីលេខ ១៥០, ១២៤ និងលេខ ១២២, ១២៣ ស្ថិតនៅភូមិតាដឹប សង្កាត់អណ្តូងខ្មែរ ក្រុងកំពត ខេត្តកំពត ពីចុងចម្លើយឈ្មោះ ម៉ៃ ។

**អង្គហេតុបញ្ជាក់ការទាមទារ:**

លោកមេធាវីលី តំណាងដោយអាណាព្យាបាលដើមចោទ បានថ្លែងការណ៍ថា: កូនក្តីរបស់ខ្លួន ក៏ត្រូវបានទទួលមរតក របស់លោកតា ស៊ឹម និងប្រពន្ធឈ្មោះយាយ មុនឆ្នាំ១៩៧៥ យាយ បានស្លាប់ ដល់ឆ្នាំ១៩៧៥ ទៅឆ្នាំ១៩៧៦ តាប៊ុន ស៊ឹម បានយកយាយ សេន ក្រោយឆ្នាំ១៩៧៩ ស៊ឹម និង យាយសេន បានប្រមូលចៅៗយកមកចិញ្ចឹម ដល់ឆ្នាំ១៩៨៦ លោកតា ស៊ឹម ស្លាប់ទ្រព្យពុំទាន់បានបែងចែកទេនៅទាំង ០៩នាក់ មួលគ្នាមានឈ្មោះ នួន, សុខ, សាមឿន និង រ៉ែន ដោយមានពីរពេញខ្ទះខាតទើប កូនក្តី របស់ខ្លួនបានបែកចេញពីយាយ គង់ តែគាត់មកមើលថែយាយ សេន គង់ រហូតហើយ ឈ្មោះ រ៉ែន នៅជាមួយយាយ ក្រោយមកយាយ សេន បានស្លាប់ ក្រោយមកទៀត ស៊ឹម បានស្លាប់

ដោយ មានកូនឈ្មោះ ម៉ៃ គ្រប់គ្រងដី នោះទាំងអស់ ដោយកូនក្តីរបស់ខ្លួនមិនសុខចិត្ត ទើបសុំបែងចែកទំហំ៥០០០ម៉ែត្រការេ កូនក្តីខ្លួនត្រូវ បានទទួលចំណែកមរតកនោះដែរ ម្យ៉ាងទៀត លោកមេឃុំអណ្តូងខ្មែរបានបញ្ជាក់ថាដីនោះមិនទាន់បែងចែកឲ្យសមាជិកទាំងអស់នោះទេ ដីនោះ ពិតជាដីដែលបន្សល់ទុកពីតា ស៊ុម និងយាយ គង់ ដូចនេះសុំបែងចែកដីនោះជា ០៣ ចំណែក ។ នៅឆ្នាំ២០០៦យាយ គង់ បានស្លាប់នៅ ឈ្មោះ រ៉ែន មើលថែក្រោយមកទៀត ឈ្មោះ រ៉ែន បានស្លាប់ទៀត នៅឈ្មោះ ម៉ៃ គ្រប់គ្រងបន្តដីនោះមាន ៤ ប្លង់។

.សហដើមចោទឈ្មោះ សាមឿនបានថ្លែងការណ៍ថា: ដីស្រែនេះបញ្ជាក់ពីមេឃុំមិនទាន់បែងចែកឲ្យអ្នកណាជាកម្មសិទ្ធិទេ ហើយបងស្រីរបស់ខ្លួនស្លាប់មិនចាំឆ្នាំ មិនដឹងថាឆ្នាំ២០០៦ ឬឆ្នាំ ២០០៧ ពេលតាឈឺខ្ញុំនៅទីនោះ ហើយមើលថែគាត់ ដី ៤ក្បាលដីមានតែមួយប្លង់ទេ ទំហំ៥០០០ ម៉ែត្រការេ សុំឲ្យចែកគ្នាស្មើជា ៣ចំណែក។

ចុងចម្លើយឈ្មោះ ម៉ៃ បានថ្លែងការណ៍ថា: ដីនោះរដ្ឋគេ ចែកឲ្យនៅឆ្នាំ១៩៧៩ ដីស្រែរដ្ឋគេចែកឲ្យយាយ គង់ ពួកគាត់នៅជាមួយឪពុករបស់គាត់ តាចែកដីទួល និងដីភូមិឲ្យ ហើយយាយ គង់ ចែកដីស្រែ ខ្លួនមានសាក្សីដឹងឮ ខ្លួនសុំបញ្ចូលសាក្សី ។

ខ្លួនមិនចែកទេ ដោយតាគាត់យកយាយរបស់ខ្លួន ហើយដីស្រែនោះ ៤ក្បាលដី មានមួយប្លង់ទេ រដ្ឋចែកឲ្យក្រោយឆ្នាំ១៩៧៩ ហើយឈ្មោះស៊ឹម អូន ឈ្មោះស៊ឹម និងឈ្មោះស៊ឹម មិនបាននៅជាមួយតាទេ ដីរបស់តាស៊ឹម មានដីទួល និងភូមិ យាយមុន ចំណែកដីស្រែតាស៊ឹម យកយាយសេន ក្រោយចែកនៅក្រោយឆ្នាំ១៩៧៩ ម្តាយខ្លួនស្លាប់ឆ្នាំ២០១៣ ឈ្មោះស៊ឹម ស្លាប់មុនម្តាយខ្លួន ឈ្មោះស៊ឹម រ៉ែន ។

**តស្តុតាងបញ្ជាក់មាន:**

.សាក្សីរបស់ដើមចោទឈ្មោះម៉ាស ថា: តា ស៊ឹម ខ្លួនមិនដឹងឆ្នាំណាគាត់យកយាយ សេន ទេ យាយសេន ស្លាប់នៅឆ្នាំ២០០៦ ដីនោះរដ្ឋចែកឲ្យនៅឆ្នាំ១៩៧៩ ឲ្យតាប៊ុន និងយាយសេន ចៅគាត់នៅតូចៗ គាត់យកមកចិញ្ចឹម ដីនោះមិនទាន់បែងចែកឲ្យទៅចៅៗទេ ឈ្មោះស៊ឹម និងឈ្មោះស៊ឹម នៅជាមួយយាយតា តែស៊ឹម មានប្តីបានចេញយូរ មកហើយៗមក លេងម្តងម្កាល ពេលយាយឈឺទៅៗនៅឆ្ងាយមកមើលថែ ឈ្មោះស៊ឹមរ៉ែននៅជាមួយ យាយ និងឈ្មោះ អូន នៅប្រចាំ ពេលធ្វើបុណ្យខ្លួនមិនដឹងទេ ។

.សាក្សីរបស់ចុងចម្លើយឈ្មោះសាំ លីហួ ថា:ក្រុមសាមគ្គីចែកដីឈ្មោះសាមឿន មានឪពុកម្តាយវាមិននៅជាមួយតា យាយទេ ឪពុកម្តាយវាមានកូន៤នាក់ ឈ្មោះ អូន ឈ្មោះ សុខ ឈ្មោះ មេត និងឈ្មោះ សាមឿន គ្រួសាររបស់ឈ្មោះ រ៉ែន តាស៊ឹម យាយគង់ មាន៤ នាក់ ឈ្មោះស៊ឹម រ៉ែន និង ឈ្មោះ នី និង តាស៊ឹម យាយគង់ រដ្ឋចែកនៅឆ្នាំ១៩៧៩ បែងចែកតាម គ្រួសាររៀងៗខ្លួន មិនត្រូវបែងចែកដីនោះឲ្យឈ្មោះ សុខ និង ឈ្មោះ សាមឿន មិនកើតទេ ពេលឪពុកឈ្មោះ សែន និងម្តាយឈ្មោះនាង ពៅ ពេលចែកដីហើយស្លាប់ ក្រោយមកឈ្មោះ

ៗ សែនយក ប្រពន្ធទៀត ពេលនោះកូនៗបានបែងចែកគ្នានៅ គ្រួសារឈ្មោះ សែន ចែកឲ្យអស់ហើយ ស៊ឹមស្លាប់ យាយគង់ធ្វើបុណ្យ យាយគង់ ស្លាប់ឈ្មោះ រ៉ន ធ្វើបុណ្យលុយឈ្មោះ រ៉ន ចេញ ឈ្មោះស៊ឹម អូន នៅផ្ទះដោយឡែក ពេលតាស៊ឹម ស្លាប់ ឈ្មោះ អូន មកនៅជាមួយ យាយ វិញ មូលហេតុដឹងថាឈ្មោះ រ៉ន ចេញលុយ ធ្វើបុណ្យសពយាយគង់ ខ្លួនជាអ្នកជួយរៀបចំ ខ្លួនក៏ ចង់ឲ្យចែកដែរ ដោយឈ្មោះសេន ម៉ៃតោះ មិនព្រម ដីនោះមិនមែនដីកេរ្តិ៍ ពីដូនតាទេ គឺដីរដ្ឋ ចែកឲ្យទេ ។

.សាក្សីរបស់ចុងចម្លើយឈ្មោះ ខាន់ ថា: សាមឿន មានបងប្អូន ៤នាក់ ពេលតាស៊ុមស្លាប់ ទុកតែដីស្រែឲ្យយាយគង់ ពេលធ្វើបុណ្យខាង សុខ ក៏បានជួយធ្វើបុណ្យដែរ ចំពោះលុយអ្នកណាចេញខ្លះខ្ញុំមិនដឹងទេ ។

## សំអាងហេតុ

.ទទួលពាក្យសុំរបស់សហដើមចោទឈ្មោះ សុខ និងឈ្មោះ សាមឿន ទុកជាត្រឹមត្រូវតាមនីតិវិធីនៃច្បាប់ ។

.ភាគីដើមចោទថា ដីស្រែជាកេរ្តិ៍មរតករបស់សពតា ស៊ឹម និងយាយ គង់ ទើបសុំបែងចែកមរតក តែភាគីចុងចម្លើយថា ដីស្រែជាកេរ្តិ៍មរតករបស់យាយ គង់ ក្រុមសាមគ្គីចែកឲ្យយាយ គង់ ចំណែកឯដីទួល និងដីភូមិជាកេរ្តិ៍មរតករបស់តា ស៊ឹម តែតា ស៊ឹម បានបែងចែកពួកគាត់អស់ហើយ វាស៊ីចង្វាក់ទៅនឹងចម្លើយសាក្សីចុងចម្លើយ សាំ លីហ្វះ ថាដីខាងអ្នកដាក់ពាក្យសុំបានបែងចែកឲ្យរួចហើយ ម្យ៉ាងទៀតឈ្មោះ រ៉ន ម្តាយចុងចម្លើយជា អ្នកនៅមើលថែរក្សាយាយ គង់ រហូតដល់ស្លាប់ ថែមទាំងជាអ្នកចេញលុយធ្វើបុណ្យសពឲ្យយាយ ទៀត ចំពោះអ្នកផ្សេងគ្រាន់តែចូលរួម នេះបញ្ជាក់ថា ដីដែលជាមរតករបស់យាយ គង់ ក៏ជាសោហ៊ុយក្នុងការធ្វើបុណ្យដែរ ដូចនេះតុលាការ មិនអាចលើកពាក្យសុំរបស់អ្នកប្តឹងសុំមក ពិចារណាបានឡើយ។

.ចំណែកឯលិខិតបញ្ជាក់របស់អាជ្ញាធរឃុំគ្រាន់តែបានបញ្ជាក់ថាលោកតា ស៊ឹម និងលោកយាយ គង់ បានបន្សល់ទុកដីស្រែ ០១កន្លែង មានទំហំ ៥០០០ម៉ែត្រការ៉េ ហើយបច្ចុប្បន្នជាដីទំនាស់ពុំទាន់ដោះស្រាយ តែការបែងចែកយ៉ាងណានោះ អាជ្ញាធរពុំបានបញ្ជាក់ច្បាស់លាស់ ហើយអ្នកប្តឹងសុំបានទទួលចំណែកហើយ តែឈ្មោះស៊ឹម រ៉ន ម្តាយ ម៉ៃតោះ ជាអ្នកនៅថែរក្សាលោកយាយ គង់ រហូតដល់ស្លាប់ ថែមទាំងធ្វើបុណ្យទៀត នេះជាការចំណាយក្នុងនាមកតញ្ញូ ឯអ្នកផ្សេងគ្រាន់តែចូលរួមប៉ុណ្ណោះ ដូច្នេះពុំគប្បីបែងចែកឲ្យទៀតទេ។

## សេចក្តីសម្រេចបញ្ចប់

១.ច្រានពាក្យសុំរបស់សហដើមចោទឈ្មោះ សុខ និងឈ្មោះ សាមឿន ចុះថ្ងៃ១៤ ខែកក្កដា ឆ្នាំ២០១៦ ចោល ។

២.ប្រាក់ប្រដាប់ក្តី ជាបន្ទុករបស់អ្នកប្តឹងសុំ ។

ចៅក្រម

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្ត**
**កំពត**

**ដីកាលេខ: ១៣**
ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៧

# ដីកាសម្រេច

បានឃើញ សំណុំរឿងរដ្ឋប្បវេណីលេខ៣១ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៧

-អ្នកដាក់ពាក្យសុំៈឈ្មោះដើមចោទឈ្មោះ មុំ ភេទស្រី អាយុ ឆ្នាំ ទីលំនៅបច្ចុប្បន្ននៅភូមិត្រពាំងវែង ឃុំត្រពាំងរាំង ស្រុក ខេត្ត ។

**ការទាមទារ:**

សុំទទួលមរតកបន្តពីមរតកជនឈ្មោះគង់

**អង្គហេតុបញ្ជាក់ការទាមទារ:**

ដើមចោទឈ្មោះ មុំ បានអះអាងថា: ខ្លួន និងប្តីឈ្មោះគង់ មានដី០៦កន្លែងដែល មានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ០៧០៤០២ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០ ស្ថិតនៅភូមិកណ្តាល ឃុំ ស្រុក ខេត្ត , វិញ្ញាបនប័ត្រសំគាល់ម្ចាស់ អចលនវត្ថុលេខ០៧០៤ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០ ស្ថិតនៅភូមិកណ្តាល ឃុំ ស្រុក ខេត្ត , វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ០៧០ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០ ស្ថិតនៅភូមិ ឃុំ ស្រុក គីរី ខេត្ត , វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ០៧០៤ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០ ស្ថិតនៅភូមិត្រពាំងវែង ឃុំ ស្រុកជុំគីរី ខេត្ត , វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ០៧០៤០៧០១- ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៦ ស្ថិតនៅភូមិត្រពាំងវែង ឃុំ ស្រុក ខេត្ត , វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ០៧០៤០៧០១- ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០ ស្ថិតនៅភូមិត្រពាំងវែង ឃុំ ស្រុក ខេត្ត ។ នៅថ្ងៃទី០៩ ខែ សីហា ឆ្នាំ២០ ប្តីរបស់ខ្លួនឈ្មោះគង់ បានទទួលមរណភាព ដោយមានសេចក្តីចម្លងសំបុត្រមរណភាព លេខ /២០០៨ ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០ តាមផ្លូវច្បាប់រួចហើយ ដោយបន្សល់នូវអចលនៈ ទ្រព្យដីមានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ០៧០៤ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០ ស្ថិតនៅភូមិកណ្តាល ឃុំ ស្រុក ខេត្ត , វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ០៧០៤ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០ ស្ថិតនៅភូមិ ឃុំ ស្រុក ខេត្ត , វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ០៧០៤ ចុះថ្ងៃទី ១៣ ខែមីនា ឆ្នាំ២០ ស្ថិតនៅភូមិ ឃុំ ស្រុក ខេត្ត , វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ០៧០៤ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០ ស្ថិតនៅភូមិត្រពាំងវែង ឃុំ ស្រុក ខេត្ត , វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ០

០៤០៧០១- ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០ ស្ថិតនៅភូមិត្រពាំងវែង ឃុំត្រពាំង រាំង ស្រុក ខេត្ត , វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ០៧០៤០៧០១- ចុះថ្ងៃ ទី១៣ ខែមីនា ឆ្នាំ២០ ស្ថិតនៅភូមិត្រពាំងវែង ឃុំ ស្រុក ខេត្ត ដោយកូនៗ របស់ខ្លួនមាន ឈ្មោះ នាវ ភេទស្រី, ឈ្មោះ គង់ ភេទប្រុស, ឈ្មោះ គង់ ភេទ ប្រុស, ឈ្មោះ បុត្រ ភេទប្រុស, ឈ្មោះ ម៉ូលីណា ភេទស្រី និងឈ្មោះ សុខលី ភេទស្រី កូនខ្លួនទាំង ០៦នាក់ បានព្រមព្រៀងប្រគល់ដី០៦កន្លែង ដែលមានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ០៧០៤ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០ ស្ថិតនៅភូមិកណ្ដាល ឃុំ ស្រុក ខេត្ត , វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ០៧០៤០ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០ ស្ថិតនៅភូមិកណ្ដាល ឃុំ ស្រុក ខេត្ត , វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ០៧០៤០ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ ស្ថិតនៅភូមិត្រពាំងវែង ឃុំត្រពាំងរាំង ស្រុក ខេត្ត ,វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ០៧០៤០៧០១- ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០ ស្ថិតនៅភូមិត្រពាំងវែង ឃុំត្រពាំងរាំង ស្រុកជុំគីរី ខេត្ត , វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ០៧០៤០៧០១-០៩៩៥ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៦ ស្ថិតនៅភូមិ ត្រពាំងវែង ឃុំ ស្រុក ខេត្ត , វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ០៧០៤០៧ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០ ស្ថិតនៅភូមិត្រពាំង ស្រុក ខេត្ត មកឲ្យខ្លួនមានសិទ្ធិចាត់ចែងចាប់ពីនេះតទៅ ។

**ភស្តុតាងបញ្ជាក់មាន:**

កូនឈ្មោះនាវ លីណាឈ្មោះ ឈ្មោះគង់ និងឈ្មោះ បាន ថ្លែងការណ៍ប្រហាក់ប្រហែលគ្នាថា បងប្អូនពួកខ្លួនទាំង ០៦នាក់ ដែលមានឈ្មោះនាវ ឈ្មោះ សំបូរ ភេទប្រុស, ឈ្មោះ ភេទប្រុស, ឈ្មោះ ភេទប្រុស, ឈ្មោះ ភេទស្រី និងឈ្មោះ ភេទស្រី បានព្រមព្រៀងគ្នា ប្រគល់សិទ្ធិជូនម្ដាយ ខ្លួនចាត់ចែងដីទាំង ០៦កន្លែង ដែលមានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ០៧០៤០២០៣- ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ ស្ថិតនៅភូមិកណ្ដាល ឃុំជម្ពូវន្ត ស្រុក ខេត្ត , វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ ស្ថិតនៅភូមិកណ្ដាល ឃុំជម្ពូវន្ត ស្រុក , វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ០៧០៤០ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០ ស្ថិតនៅភូមិត្រពាំងវែង ឃុំ ស្រុក ខេត្ត , វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ០៧០៤០ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២ ស្ថិតនៅភូមិត្រពាំងវែង ឃុំ ស្រុក ខេត្ត , វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ០៧០៤០៧០១- ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០ ស្ថិតនៅភូមិ ឃុំ ស្រុក ខេត្ត ,វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ០៧០៤០៧ ចុះថ្ងៃទី១៣ ខែមីនា

ឆ្នាំ២០ ស្ថិតនៅភូមិត្រពាំងវែង ឃុំត្រ ស្រុក ខេត្ត ។

.សេចក្តីចម្លងសំបុត្រមរណភាពលេខ ០១/ ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០

.វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ០៧០៤០២០៣ ចុះថ្ងៃទី ខែកញ្ញា ឆ្នាំ២០ ស្ថិតនៅភូមិកណ្តាល ឃុំ ស្រុក ខេត្ត , វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ០៧០៤ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០ ស្ថិតនៅភូមិកណ្តាល ឃុំជម្ពូវន្ត ស្រុក ខេត្ត , វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ០៧០៤០៧០១- ១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៦ ស្ថិតនៅភូមិត្រពាំងវែង ឃុំត្រពាំងរាំង ស្រុកជុំគីរី ខេត្តកំពត, វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ០៧០៤០៧០១- ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៦ ស្ថិតនៅភូមិត្រពាំងវែង ឃុំត្រពាំងរាំង ស្រុកជុំគីរី ខេត្ត , វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ០៧០៤០៧០១- ៤ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៦ ស្ថិតនៅភូមិត្រពាំងវែង ឃុំត្រពាំងរាំង ស្រុកជុំគីរី ខេត្ត , វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ០៧០៤០៧០១- ៦ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០ ស្ថិតនៅភូមិត្រពាំងវែង ឃុំត្រពាំងរាំង ស្រុកជុំគីរី ខេត្ត ។

.តំកល់ទុកលេខ ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០ ។

.សេចក្តីព្រមព្រៀង និងអនុញ្ញាត ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០ ។

.សៀវភៅគ្រួសារចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩ ។

.សៀវភៅស្នាក់នៅចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០ ។

**សំអាងហេតុ**

១.ឈ្មោះគង់ ពិតជាបានទទួលមរណភាពនៅថ្ងៃទី០៩ ខែសីហា ឆ្នាំ២០ និងមានសេចក្តីចម្លងសំបុត្រមរណភាពលេខ០១/២០ ចុះថ្ងៃទី១៥ខែសីហាឆ្នាំ២០ ចេញដោយមន្ត្រីអត្រានុកូលដ្ឋាន ឃុំត្រពាំងវែង ប្រាកដមែន ។

២.ក្រោយពីឈ្មោះ បានទទួលមរណភាពពិតជាបានបន្សល់ទុកនូវ ទ្រព្យសម្បត្តិជាអចលនវត្ថុមានដីដែលមាន វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ០៧០៤០២០៣០ ចុះថ្ងៃទី១៥ខែកញ្ញា ឆ្នាំ២០ ស្ថិតនៅភូមិកណ្តាល ឃុំជម្ពូវន្ត ស្រុកជុំគីរី ខេត្តកំពត, វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ០៧០៤០២០៣ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០ ស្ថិតនៅភូមិកណ្តាល ឃុំជម្ពូវន្ត ស្រុកជុំគីរី ខេត្ត , វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ០៧០៤០៧០១- ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០ ស្ថិតនៅភូមិត្រពាំងវែង ឃុំត្រពាំងរាំង ស្រុក ខេត្ត , វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ០៧០៤០៧០១- ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០ ស្ថិតនៅភូមិ ត្រពាំងវែង ឃុំត្រពាំងរាំង ស្រុកជុំគីរី ខេត្ត , វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ០៧០៤០៧០១- ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០ ស្ថិតនៅភូមិត្រពាំងវែង ឃុំត្រពាំងរាំង ស្រុក ខេត្ត , វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ០៧០៤០៧០១

ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០ ស្ថិតនៅភូមិត្រពាំងវែង ឃុំត្រពាំងរាំង ស្រុក ខេត្ត ។ ដែលជាកម្មសិទ្ធិ របស់ឈ្មោះគង់ និងប្រពន្ធឈ្មោះដួង មុំ ពិតប្រាកដមែន ។

៣.តាមពាក្យសុំចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៧ តំកល់ទុកលេខចុះថ្ងៃទី១៤ខែមីនា ឆ្នាំ២០១៧ សេចក្ដីព្រមព្រៀង និងអនុញ្ញាត ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៧ សៀវភៅគ្រួសារចុះថ្ងៃ ទី២១ ខែធ្នូ ឆ្នាំ១៩៩៩ និងសៀវភៅស្នាក់នៅចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៥ ។ បានបញ្ជាក់ថា ឈ្មោះ មុំ ជាប្រពន្ធ និងកូនឈ្មោះ លីណា ឈ្មោះ សំបូរ ភេទប្រុស, ឈ្មោះ កុសល ភេទប្រុស, ឈ្មោះ បុត្រ ភេទប្រុស, ឈ្មោះ ម៉ូលីណា ភេទស្រី និងឈ្មោះ សុខលី ភេទស្រី ទាំង៦នាក់នេះជាទាយាទ និងជាសន្តតិជនរបស់សពឈ្មោះ ខ្វក មានសិទ្ធិទទួលមរតកនូវ ទ្រព្យមរតកដែលជាកម្មសិទ្ធិរបស់ឈ្មោះគង់ វ៉ាន់ថុន មាត្រា១១៤៩.១១៥៦ និងមាត្រា១១៦១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ ។

៤.តាមសំបុត្រអនុញ្ញាតពីក្រុមប្រឹក្សាញាតិចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៧ ឈ្មោះនាវ ណា ឈ្មោះ សំបូរ ភេទប្រុស ឈ្មោះ កុសល ភេទប្រុស ឈ្មោះ ភេទប្រុស ឈ្មោះ ម៉ូលីណា ភេទស្រី និងឈ្មោះ សុខលី ភេទស្រី បានឯកភាពព្រមព្រៀងគ្នាប្រគល់ ដីដែលមានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ០៧០៤០២០ ចុះថ្ងៃទី១៥ខែកញ្ញាឆ្នាំ២០ ស្ថិតនៅភូមិកណ្ដាល ឃុំជម្ពូវន្ត ស្រុកជុំ ខេត្ត , វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ០៧០៤០២០៣- ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០ ស្ថិតនៅភូមិកណ្ដាល ឃុំជម្ពូវន្ត ស្រុកជុំគីរី ខេត្ត , វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ០៧០៤០៧០១- ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០ ស្ថិតនៅភូមិត្រពាំងវែង ឃុំត្រពាំងរាំង ស្រុកជុំគីរី ខេត្ត , វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ០៧០៤០៧០១- ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៦ ស្ថិតនៅភូមិ ត្រពាំងវែង ឃុំត្រពាំងរាំង ស្រុកជុំគីរី ខេត្ត , វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ០៧០៤០៧០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០ ស្ថិតនៅភូមិត្រពាំងវែង ឃុំ ត្រពាំងរាំង ស្រុក ខេត្ត , វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ០៧០៤០៧០១- ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០ ស្ថិតនៅភូមិត្រពាំងវែង ឃុំត្រពាំងរាំង ស្រុកជុំគីរី ខេត្ត ។ ជាមរតករបស់សពឈ្មោះ ខាងលើឲ្យទៅឈ្មោះ មុំ ជាសន្តតិជនតែម្នាក់មានសិទ្ធិចាត់ចែងតាមការព្រមព្រៀង ធ្វើឡើងស្របតាមសេចក្ដីព្រមព្រៀងរវាង កូនរបស់សពទាំង៦នាក់ ដែលជាសន្តតិជន និងអនុញ្ញាតិ ពីក្រុមប្រឹក្សាញ្ញាតិ ហេតុនេះ គប្បីតុលាការសម្រេចទទួលស្គាល់ការទាមទារ របស់អ្នកដាក់ពាក្យសុំខាងលើ ។

**<u>សេចក្ដីសម្រេចបញ្ចប់</u>**

១.ទទួលស្គាល់ឈ្មោះ មុំ ជាសន្តតិជនបន្តមរតករបស់សពឈ្មោះ លើអចលនវត្ថុដែលមាន

ក.វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ០៧០៤០២០៣ ចុះថ្ងៃទី១៥ ខែកញ្ញា

ឆ្នាំ២០០៦ ស្ថិតនៅភូមិកណ្ដាល ឃុំជម្ពូវន្ត ស្រុក[illegible] ខេត្ត[illegible] ។

ខ.វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ០៧០៤០២០៣[illegible]ចុះថ្ងៃទី១៥ខែកញ្ញា ឆ្នាំ២០០៦ ស្ថិតនៅភូមិកណ្ដាល ឃុំជម្ពូវន្ត ស្រុកជុំ[illegible] ខេត្ត[illegible] ។

គ.វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ០៧០៤០៧០១-[illegible]ចុះថ្ងៃទី១៣ខែមីនា ឆ្នាំ២ ០០៦ ស្ថិតនៅភូមិត្រពាំងវែង ឃុំត្រពាំងរាំង ស្រុកជុំ[illegible] ខេត្ត[illegible] ។

ឃ.វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ០៧០៤០៧០១[illegible]ចុះថ្ងៃទី១៣ខែមីនា ឆ្នាំ២០០៦ ស្ថិតនៅ ភូមិ ត្រពាំងវែង ឃុំត្រពាំងរាំង ស្រុកជុំគីរី ខេត្ត[illegible] ។

ង.វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ០៧ ០៤០៧០១[illegible] ចុះថ្ងៃទី១៣ខែមីនា ឆ្នាំ២០០៦ ស្ថិតនៅភូមិត្រពាំងវែង ឃុំត្រពាំងរាំង ស្រុកជុំគីរី ខេត្ត[illegible] ។

ច.វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ០៧០៤០៧០[illegible]ចុះថ្ងៃទី១៣ខែមីនា ឆ្នាំ២០០៦ ស្ថិតនៅ ភូមិត្រពាំងវែង ឃុំត្រពាំងរាំង ស្រុកជុំគីរី ខេត្ត[illegible] ។

មានសិទ្ធិចាត់ចែងតាមច្បាប់តាមសេចក្ដីព្រមព្រៀងនិងអនុញ្ញាតពីក្រុមប្រឹក្សាញាតិចុះថ្ងៃទី ១៤ ខែមីនាឆ្នាំ២០១៧ តាមមាត្រា១១៦១ ចំណុច១នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ។

២.ប្រាក់ប្រដាប់ក្ដី ជាបន្ទុករបស់អ្នកប្ដឹង

ចៅក្រម

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្ត**
**កំពត**
**ដីកាលេខ: ១២**
ចុះថ្ងៃទី ២៨ ខែមីនា ឆ្នាំ២០១៨

# ដីកាសម្រេច

បានឃើញ សំណុំរឿងរដ្ឋប្បវេណីលេខ៣២ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៧

-អ្នកដាក់ពាក្យសុំៈឈ្មោះ ធុល ភេទស្រី អាយុ៥៨ឆ្នាំ ទីលំនៅបច្ចុប្បន្ននៅភូមិត្រពាំងមន្ត្រី ឃុំសំរោងក្រោម ស្រុកបន្ទាយមាស ខេត្ត ។

**ការទាមទារៈ**

សុំទទួលមរតកបន្តពីមតេកជន

**អង្គហេតុបញ្ជាក់ការទាមទារៈ**

ដើមចោទឈ្មោះងិន ធុល បានអះអាងថាៈ ខ្លួន និងប្តីឈ្មោះ ខូក មានដីមួយកន្លែងដែល មានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ០៧០២០៤០១- ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១២ ស្ថិតនៅភូមិត្រពាំងមន្ត្រី ឃុំសំរោងក្រោម ស្រុកបន្ទាយមាស ខេត្តកំពត នៅថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ១៩៩២ ប្តីរបស់ខ្លួនឈ្មោះ ខូក បានទទួលមរណភាព និងសេចក្តីចម្លងសំបុត្រមរណភាពលេខ០៥/ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១១ តាមផ្លូវច្បាប់រួចហើយ ដោយបន្សល់នូវអចលនៈទ្រព្យដីមានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ០៧០២០៤០១- ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១២ ស្ថិតនៅភូមិត្រពាំងមន្ត្រី ឃុំសំរោងក្រោម ស្រុក ខេត្ត ដោយកូនៗ របស់ខ្លួន មានឈ្មោះ ស្រីវន ភេទស្រី និងឈ្មោះ ប៊ុនថន ភេទប្រុស កូនខ្លួនទាំង២នាក់បានព្រមព្រៀងប្រគល់ដីមួយកន្លែងដែលមាន វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ០៧០២០៤០១- ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០ ស្ថិតនៅភូមិត្រពាំងមន្ត្រី ឃុំសំរោងក្រោម ស្រុកបន្ទាយមាស ខេត្ត មកឲ្យខ្លួន មានសិទ្ធិចាត់ចែងចាប់ពីនេះតទៅ ។

**វត្ថុតាងបញ្ជាក់មានៈ**

.សេចក្តីចម្លងសំបុត្រមរណភាពលេខ០៥/២០១១ ចុះថ្ងទី០២ ខែតុលា ឆ្នាំ២០១១

.វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ០៧០២០៤០១-០២១៨ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១២ ស្ថិតនៅភូមិត្រពាំងមន្ត្រី ឃុំសំរោងក្រោម ស្រុក ខេត្ត ។

.សេចក្តីព្រមព្រៀង និងអនុញ្ញាត ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៧ ។

.សៀវភៅគ្រួសារលេខ០៤០២០ ។

**សំអាងហេតុ**

១.ឈ្មោះ ខូក ពិតជាបានទទួលមរណភាពនៅថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ១៩៩២ និងមានសេចក្តីចម្លងសំបុត្រមរណភាពលេខ០៥/២០ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០ ចេញដោយមន្ត្រី

អគ្រានុកូលដ្ឋាន ឃុំសំរោងក្រោម ប្រាកដមែន ។

២.ក្រោយពីឈ្មោះ ខូក បានទទួលមរណភាពពិតជាបានបន្សល់ទុកនូវ ទ្រព្យសម្បត្តិជាអចលនវត្ថុ មានដីដែលមាន វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ០៧០២០៤០១- ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០ ស្ថិតនៅភូមិត្រពាំងមន្ត្រី ឃុំសំរោងក្រោម ស្រុកបន្ទាយមាស ខេត្ត ។ ដែលជាកម្មសិទ្ធិ របស់ឈ្មោះ ខូក និងប្រពន្ធឈ្មោះ ធុល ពិតប្រាកដមែន ។

៣.តាមពាក្យសុំចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៧ សៀវភៅគ្រួសារលេខ០៥០២០ និងសំបុត្រព្រមព្រៀង និងអនុញ្ញាតពីក្រុមប្រឹក្សាញាតិ ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៧ បានបញ្ជាក់ថាឈ្មោះ ធុល ជាប្រពន្ធ និងកូនឈ្មោះ ស្រីវន ភេទស្រី និងឈ្មោះ ប៊ុនថន ភេទប្រុស ទាំង២នាក់នេះជាទាយាទ និងជាសន្តតិជនរបស់សពឈ្មោះ ខូក មានសិទ្ធិទទួលមរតកនូវទ្រព្យមរតកដែលជាកម្មសិទ្ធិរបស់ឈ្មោះ ខូក មាត្រា១១៥៩.១១៥៦ និងមាត្រា១១៦១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ។

៤.តាមសំបុត្រអនុញ្ញាតពីក្រុមប្រឹក្សាញាតិចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៧ ឈ្មោះ ស្រីវន ភេទស្រី និងឈ្មោះ ប៊ុនថន ភេទប្រុស បានឯកភាពព្រមព្រៀងគ្នាប្រគល់ ដីដែលមានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ០៧០២០៤០១- ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១២ ស្ថិតនៅភូមិត្រពាំងមន្ត្រី ឃុំសំរោងក្រោម ស្រុក ខេត្ត ជាមរតករបស់សពឈ្មោះ ខូក ខាងលើឲ្យទៅឈ្មោះ ធុល ជាសន្តតិជនតែម្នាក់មានសិទ្ធិចាត់ចែងតាមការព្រមព្រៀងធ្វើឡើងស្របតាមសេចក្តីព្រមព្រៀងរវាង កូនរបស់សពទាំង២នាក់ ដែលជាសន្តតិជន និងអនុញ្ញាតិពីក្រុមប្រឹក្សាញាតិហេតុនេះ គប្បីតុលាការសម្រេចទទួលស្គាល់ការទាមទារ របស់អ្នកដាក់ពាក្យសុំខាងលើ ។

**<u>សេចក្តីសម្រេចបញ្ចប់</u>**

១.ទទួលស្គាល់ឈ្មោះ ធុល ជាសន្តតិជនបន្តមរតករបស់សពឈ្មោះ ខូក លើអចលនវត្ថុដែលមាន វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ០៧០២០៤០១- ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០ ស្ថិតនៅភូមិត្រពាំងមន្ត្រី ឃុំសំរោងក្រោម ស្រុក ខេត្ត មានសិទ្ធិចាត់ចែងតាមច្បាប់ តាមសេចក្តីព្រមព្រៀង និងអនុញ្ញាតពីក្រុមប្រឹក្សាញាតិចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ ២០១៧ ។ តាមមាត្រា១១៦១ ចំណុច១ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ។

២.ប្រាក់ប្រដាប់ក្តី ជាបន្ទុករបស់អ្នកប្តឹង

ចៅក្រម

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកំពត**

លេខ: ២៥៦ /១៦

# ដីកាសម្រេច

យើង ចៅក្រមនៃសាលាដំបូង ។

បានឃើញ ក្រមនីតិវិធីរដ្ឋប្បវេណី ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦ ។

បានឃើញ ក្រមរដ្ឋប្បវេណី ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី ០៤ ខែធ្នូ ឆ្នាំ២០០៧ ។

បានឃើញ ច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណី ដែលមិនមែនជាបណ្តឹង ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧០១/០១៣ ចុះថ្ងៃទី ១០ខែកក្កដា ឆ្នាំ២០១១ ។

បានឃើញ ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ដែលប្រកាសឲ្យប្រើ តាមព្រះរាជក្រមលេខ នស/រកម/០៥១១/០០៧ ចុះថ្ងៃទី ៣១ ខែឧសភា ឆ្នាំ២០១១ ។

បានឃើញ សំណុំរឿងរដ្ឋប្បវេណីពេ ចុះថ្ងៃទី ខែមិថុនា ឆ្នាំ២០ របស់សាលាដំបូង ។

បានឃើញ ពាក្យសុំ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៦ ។

**អ្នកដាក់ពាក្យសុំឈ្មោះ** ឈិន ភេទ អាយុ ៣ឆ្នាំ សញ្ជាតិខ្មែរ សព្វថ្ងៃរស់នៅភូមិ ឃុំ ស្រុក ខេត្ត ។

**ភាគីម្ខាងទៀត:**

ឈ្មោះ មុំ ភេទ អាយុ ៣ឆ្នាំ សញ្ជាតិខ្មែរ សព្វថ្ងៃរស់នៅភូមិ ឃុំ ស្រុក ខេត្ត ។

**ភស្តុតាង:**

បានឃើញ បង្កាន់ដៃក្បាលដីលេខ២ ចុះថ្ងៃទី ខែកុម្ភៈ ឆ្នាំ២០ ។

បានឃើញ បង្កាន់ដៃក្បាលដីលេខ២ ចុះថ្ងៃទី ខែកុម្ភៈ ឆ្នាំ២០ ។

បានឃើញ បង្កាន់ដៃក្បាលដីលេខ២ ចុះថ្ងៃទី ខែកុម្ភៈ ឆ្នាំ២០ ។

បានឃើញ បង្កាន់ដៃក្បាលដីលេខ២ ចុះថ្ងៃទី ខែកុម្ភៈ ឆ្នាំ២០ ។

បានឃើញបង្កាន់ដៃក្បាលដីលេខ២ ចុះថ្ងៃទី ខែកុម្ភៈ ឆ្នាំ២០ ។

បានឃើញ កិច្ចសន្យាចែកមរតកតាមការព្រមព្រៀង ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០ ។

បានឃើញ សំបុត្រមរណៈភាពលេខ១១ ចុះថ្ងៃទី១២ ខែកក្កដា ២០ ។

បានឃើញ លិខិតបញ្ជាក់ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០ ។

បានឃើញ សំបុត្របញ្ជាក់ទាយាទ ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០   ។

បានឃើញ លិខិតតំកល់ទុកចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០   ។

## សំអាងហេតុ

តាមលទ្ធផលនៃការសាកសួរ និងពិនិត្យភស្តុតាងដែលមានក្នុងសំណុំរឿង :

១.យោងតាមការអះអាងរបស់អ្នកដាក់ពាក្យសុំឈ្មោះ ឈិន   ភេទ   អាយុ  ៣ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅភូមិ   ឃុំ   ស្រុក   ខេត្ត   និង ភាគីម្ខាងទៀតឈ្មោះ  មុំ ភេទ   អាយុ  ៣ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅភូមិ   ឃុំ   ស្រុក   ខេត្ត   ព្រមទាំងភស្តុតាងជាឯកសារអាចឱ្យតុលាការជឿជាក់ថាឈ្មោះ   អ៊ុំ និងឈ្មោះ   ស៊ីវ ពិតជាបានទទួលមរណៈភាព ហើយមានដីដែលមានក្បាលដីលេខ២   លេខ២   លេខ២   លេខ២   និងលេខ២   ដែលមានទីតាំងស្ថិតនៅភូមិ   ឃុំ   ស្រុក   ខេត្ត   ប្រាកដមែន ។

២.តាមសំបុត្របញ្ជាក់ទាយាទចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០   របស់មេឃុំ   អាចឱ្យតុលាការជឿជាក់ថាឈ្មោះ ឈិន   និងឈ្មោះ  មុំ ពិតជាទាយាទរបស់ឈ្មោះ   អ៊ុំ និងឈ្មោះ   ស៊ីវ ប្រាកដមែន ។

៣.តាមការអះអាងរបស់អ្នកដាក់ពាក្យសុំ និងភាគីម្ខាងទៀត បានឯកភាពឱ្យទាយាទឈ្មោះ ឈិន   ទទួលដីចំនួន៥ប្លង់ដីដែលមានក្បាលដីលេខ២   លេខ២   លេខ២   លេខ២   និងលេខ២   ដែលមានទីតាំងស្ថិតនៅភូមិ   ឃុំ   ស្រុក   ខេត្ត   ដូចមានក្នុង កិច្ចសន្យាចែកមរតកតាមការព្រមព្រៀងចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០   ប្រាកដមែន ដូច្នេះគប្បីតុលាការ សម្រេចបែងចែកមរតកតាមការព្រម-ព្រៀងរបស់ភាគី ។

៤.ប្រាក់ប្រដាប់ក្តីអនុវត្តតាមបញ្ញត្តិមាត្រា ២២ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង។

## ហេតុដូច្នេះសម្រេច

១.ប្រគល់ដីដែលមានក្បាលដីលេខ២   លេខ២   លេខ២   លេខ២   និងលេខ   ដែលមានទីតាំងស្ថិតនៅភូមិ   ឃុំ   ស្រុក   ខេត្ត   ឱ្យទៅឈ្មោះ ឈិន   តាមការព្រមព្រៀងរបស់ភាគី ។

២.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់អ្នកដាក់ពាក្យសុំ ៕

កំពត,ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០

**ចៅក្រម**